ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- សម្ពោធជាផ្លូវការ អគារមរតកសង្គមរាស្ត្រនិយម សម្ដេចឪ-សម្ដេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៅភូមិអូរស្វាយ, ខេត្តស្ទឹងត្រែង
- ខួប ៥ឆ្នាំ ព្រះរាជបណ្ណាល័យប្អូនម៉ែ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា លេខ៣០៦ ខែមិថុនា ឆ្នាំ២០២៥

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា



សម្ដេចរាជបុត្រី ព្រះអនុជ នរោត្ដម អរុណរស្មី ឧត្ដមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ, សមាជិកាព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្ដេចព្រះមហាក្សត្រី នរោត្ដម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ យាងសម្ពោធអគាររមរតកសង្គមរាស្ត្រនិយម សម្ដេចឪ-សម្ដេចម៉ែ (បុរីអូរស្មាច់-សែនជ័យ) នៅថ្ងៃអាទិត្យ ទី១ ខែមិថុនា ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## មាតិកា

### សំបុត្រ

◆ សម្ពោធជាផ្លូវការ អគាររមរតកសង្គមរាស្ត្រនិយម សម្ដេចឪ-សម្ដេចម៉ែ (បុរីអូរស្មាច់-សែនជ័យ) នៅភូមិអូរស្មាច់, ខេត្តស្ទឹងត្រែង .................. ១
◆ ខួប ៥ឆ្នាំ ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ ........... ៨

### ផ្នែកឯកសារ

◆ របាយការណ៍សភាពការណ៍យោធាថៃ ចូលមកអុកឡុកព្រំដែនកម្ពុជា-ថៃ ក្នុងរបបខ្មែរក្រហម ...១០
◆ ម៉ៅ ផូវ អប់រំថា ៖«ឯងធ្វើបដិវត្តន៍នឹងគេដែរ ...១៣
◆ លីម ស៊ុន៖ អតីតទាហានឡាវ បម្រើការ ..... ១៦

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ អ្នកស្រាវជ្រាវវ័យក្មេងជ្រើសរើស ទីតាំង អគាររមរតកសង្គមរាស្ត្រនិយម សម្ដេចឪ-សម្ដេច.. ១៨
◆ ពេលវេលាកាន់តែខិតជិតដើម្បីជួយអ្នករស់រាន.... ២១
◆ ឆាកជីវិតប្រពន្ធ និងកូនរបស់មេក្រុម ......... ២៤
◆ ឌុល ថាត៖ អតីតអ្នកឃោសនានារីក្នុង ....... ២៧
◆ ទិន គាស រំឭកអំពីបទពិសោធន៍ស្ដីពីការជម្លៀសដោយបង្ខំទៅកាន់ភូមិភាគពាយ័ព្យ............ ៣០
◆ សំ សាបូរ៖ ក្លាយជាកូនចិញ្ចឹមមេភូមិ ......... ៣២
◆ សាត គិ (ជនជាតិដើមភាគតិចព័រ)៖ អតីតកងទ័ពកងពលលេខ៤ ការពារព្រំដែនថ្មដា .......... ៣៥
◆ ខ្ញុំធ្លាប់ឆ្លងកាត់ប្រាំសម័យកាលមកហើយ .... ៣៨
◆ សុខ ង្វួន៖ អតីតឈ្លបសង្កាត់.................. ៤២
◆ អែម សេង៖ ខ្ញុំជឿលើការមិនប្រមាថ......... ៤៤
◆ ឯកឧត្ដម ឧត្ដមសេនីយ៍ឯក ស៊ាម ហ៊ិ មេបញ្ជាការរងកងទ័ពជើងគោក បានរួមចំណែកអនុវត្ត ...... ៤៧
◆ ខ្សែភាពយន្តឯកសារ «កុមារកម្ពុជា» ......... ៥២
◆ សិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្តុលផ្សារ មកទស្សនកិច្ចសិក្សាអំពី.......... ៥៥
◆ សិស្សអនុវិទ្យាល័យថ្វាត មកអានឯកសារ និងស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅ ... ៥៨

### ផ្នែកវេទិកាពិភាក្សាសាធារណៈ

◆ វេទិកាសាធារណៈ ស្ដីពីដំណើរឆ្ពោះទៅរកភាពជាអ្នកដឹកនាំរបស់ក្មេងស្រី ......................... ៦១

### ផ្នែកស្រាវជ្រាវរកក្រួសារ

◆ បាត់ដំណឹងកូនដោយសារចូលធ្វើបដិវត្តន៍..... ៦៤
◆ អែម សុត ៖ នៅតែនឹកឃើញកូនស្រីដែលបាន បាត់ខ្លួន ......................................... ៦៦

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឱ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧ ៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឆាំង យុ, លី សុខឃាង, ស្រេង លីដា, ស្រ៊ាង លីហ៊ួរ, ស៊ាង ចិន្ដា, ចាន់ណារិទ្ធ, អេង សុខម៉េង, ដេង ពង្សរ៉ាស៊ី, ឈុំ រ៉ា, វី ស៊ីថា, សួត វិចិត្រ និង ភា រស្មី

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លីម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# សម្ពោធជាផ្លូវការ អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៅភូមិអូរស្វាយ, ខេត្តស្ទឹងត្រែង

**សោម ប៊ុនថន**



*ពិធីសម្ពោធអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ - សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៅថ្ងៃអាទិត្យ ទី១ ខែមិថុនា ឆ្នាំ២០២៥ ក្រោមកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជាសាខាខេត្តស្ទឹងត្រែង ជាមួយរដ្ឋបាលស្រុកបុរីអូរស្វាយសែនជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នេះគឺជាព្រះរាជដំណើរលើកដំបូងរបស់ សម្តេចរាជបុត្រី ព្រះអនុជ នរោត្តម អរុណរស្មី ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ, សមាជិកាព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះរាជតំណាងដ៏ខ្ពស់ខ្ពស់របស់ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ មកកាន់ភូមិអូរស្វាយ។ ព្រះរាជដំណើរនេះ គឺជាការផ្តល់កិត្តិយសសម្រាប់ប្រជាពលរដ្ឋក្នុងខេត្តស្ទឹងត្រែងទាំងមូល និងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលព្រះអង្គយាងជាអធិបតីក្នុងពិធីសម្ពោធជាផ្លូវការ «អគារមករតសង្គមរាស្ត្រនិយម សម្តេចឪ- សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)» សាខាថ្មីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងខេត្តស្ទឹងត្រែង។ ព្រះអង្គបាននាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខ និងក្តីនឹករឭកជាពន់ពេក ពីព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត មកដល់ប្រជាជនខេត្តស្ទឹងត្រែង និងប្រជាជនកម្ពុជាទាំងមូល។ ព្រះមហាក្សត្រី តែងតែខ្វាយខ្វល់ពីសុខទុក្ខរបស់ប្រជារាស្ត្ររបស់ទ្រង់ និងបួងសួងសុំឱ្យប្រជារាស្ត្ររបស់ទ្រង់មានសេចក្តីសុខ និងចម្រុងចម្រើន។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារ





ពិធីសម្ពោធអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៅថ្ងៃអាទិត្យ ទី១ ខែមិថុនា ឆ្នាំ២០២៥ ក្រោមកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តស្ទឹងត្រែង ជាមួយរដ្ឋបាលស្រុកបុរីអូរស្វាយសែនជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



កម្ពុជា និងព្រះរាជបណ្ណាល័យ ហ្វ៊ូងម៉ៃ បានសរសេររៀបរាប់ថា៖ ភូមិអូរស្វាយ មានទេសភាពដ៏ស្រស់ត្រកាល ស្ថិតនៅតាមបណ្តោយដងទន្លេមេគង្គជាប់នឹងព្រំដែន ឡាវ។ កាលពីសង្គមចាស់ ភូមិអូរស្វាយស្ថិតនៅក្នុងឃុំអូរស្វាយ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។ នៅឆ្នាំ១៩៦៤ សម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋបានយាងមកកាន់ភូមិនេះ។ ព្រះអង្គបានរៀបចំហេដ្ឋារចនាសម្ព័ន្ធនៅភូមិអូរស្វាយ និងបានសាងសង់សាលារៀន មន្ទីរពេទ្យ វត្តអារាម សួនច្បារ ស្តូប ប៉ុស្តិ៍នគរបាល មន្ទីរកសិកម្ម និងសហករណ៍លក់ដូរទំនិញជាច្រើនទៀត។ ព្រះអង្គបានប្រមូលប្រជាជន ក្រុមគ្រួសារមន្ត្រីកងទ័ពដែលចូលនិវត្តន៍មករស់នៅទីនេះ ហើយព្រះអង្គបានផ្តល់ប្រាក់ឧបត្ថម្ភ ផ្ទះ សម្បែង ដីធ្លី សត្វពាហនៈ ដើម្បីចិញ្ចឹម និងទ្រទ្រង់ជីវភាពគ្រួសារ។ ភូមិអូរស្វាយបានប្រែមុខមាត់ពីតំបន់ដាច់ស្រយាល ទៅជាបុរីតូចប្រឡូង និងគួរឱ្យទាក់ទាញនៅភាគឦសានប្រទេសកម្ពុជានាសម័យកាលនោះ។ ប៉ុន្តែប៉ុន្មានឆ្នាំក្រោយមក ភូមិនេះស្ទើរត្រូវបានបំភ្លេចចោល និងបាត់បង់ទាំងស្រុងក្នុងអំឡុងពេលសង្គ្រាមវៀតណាម, ការទម្លាក់គ្រាប់បែក និងការឡើងគ្រប់គ្រងអំណាចរបស់ខ្មែរក្រហម (ពីឆ្នាំ១៩៧៥-១៩៧៩)។

នៅឆ្នាំ២០១៩ ដោយសារព្រះទ័យសប្បុរស និងគាំទ្រពីព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ និងរាជរដ្ឋាភិបាលកម្ពុជា ភូមិអូរស្វាយបានលេចត្រដែតឡើងវិញ ដោយមានការសាងសង់សាលារៀន មន្ទីរពេទ្យ និងបន្ទប់ទឹកសាធារណៈ។ នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩ សម្តេចតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចេញអនុក្រិត្យស្តីពីការបង្កើតស្រុកបុរីអូស្វាយ-សែនជ័យ ដោយកាត់ភូមិ និងឃុំអូរស្វាយ ពីស្រុកថាឡាបរិវ៉ាត់ បញ្ចូលក្នុងស្រុកបុរីអូរស្វាយ-សែនជ័យ ហើយទីតាំងសាលាស្រុកបុរីអូរស្វាយ-សែនជ័យ គឺនៅឃុំអូរស្វាយ។

នៅឆ្នាំ២០២៤ ដោយសារមានការសព្វព្រះទ័យ និងព្រះរាជានុញ្ញាតពីព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ និងកិច្ចសហការពីរដ្ឋបាលខេត្តស្ទឹងត្រែង និងស្រុកបុរី

អូរស្វាយ-សែនជ័យ ព្រះរាជបណ្ណាល័យហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តស្ទឹងត្រែង ត្រូវបានសាងសង់ឡើង។ ហ្វូងម៉ែបានប្រសិទ្ធនាមអគារនេះថា «អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)»។ ការរៀបចំនិងសាងសង់បន្តបន្ទាប់រួមមាន៖ បណ្ណាល័យបណ្តែតទឹក, ផែរង់ចាំ, ទូកដឹកអ្នកដំណើរ ដើម្បីបម្រើដល់ការប្រើប្រាស់ និងទទួលសេវាសុខភាព និងការអប់រំរបស់សិស្សានុសិស្សអំពីប្រវត្តិសាស្ត្រកម្ពុជា ដែលរស់នៅតាមកោះឆ្ងាយៗនៃស្រុកបុរីអូរស្វាយ-សែនជ័យ និងផ្តល់ប្រយោជន៍ជាមូលដ្ឋានដល់ប្រជាជននៅក្នុងសហគមន៍ទាំងមូល។ ដំណាក់កាលទី១ នៃការងារអភិវឌ្ឍន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជានេះឧបត្ថម្ភដោយ ទីភ្នាក់ងារសម្របសម្រួលកិច្ចសហប្រតិបត្តិការរបស់ប្រទេសតួកគី។

នៅថ្ងៃអាទិត្យ ទី១ ខែមិថុនា ឆ្នាំ២០២៥ មជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តស្ទឹងត្រែង សហការជាមួយរដ្ឋបាលស្រុកបុរីអូរស្វាយសែនជ័យ បានរៀបចំពិធីសម្ពោធសមិទ្ធផលទាំងនេះ ដែលរួមមាន អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) មួយខ្នង, ផែរង់ចាំចំនួន៤ និង ទូកចម្លងចំនួន៤គ្រឿង ក្រោមអធិបតីភាព សម្តេចរាជបុត្រី ព្រះអនុជ នរោត្តម អរុណរស្មី ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ, សមាជិកាព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះរាជតំណាងដ៏ខ្ពស់ខ្ពស់របស់ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ, លោកជំទាវ អ៊ូយូ ខូចាអ៊ើសហ្វេ ឯកអគ្គរដ្ឋទូតសាធារណរដ្ឋតួកគី ប្រចាំកម្ពុជា, តំណាងទីភ្នាក់ងារសម្របសម្រួល និងសហប្រតិបត្តិការតួកគី, ឯកឧត្តម ដៃ ប៊ុនឈឿន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តស្ទឹងត្រែង, ឯកឧត្តមបណ្ឌិត នួន ពេជ្រនិមិត្ត រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ស្រុកបុរីអូរស្វាយសែនជ័យ, លោកជំទាវ ឡុង ភិរម្យ រដ្ឋលេខាធិការក្រសួងទេសចរណ៍, ឯកឧត្តម ឈាង ឡាក់ ប្រធានក្រុមប្រឹក្សាខេត្តស្ទឹងត្រែង, ឯកឧត្តម សរ សុពុត្រា អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង, លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងព្រះរាជបណ្ណាល័យហ្វូងម៉ែ, ឯកឧត្តមសមាជិកក្រុមប្រឹក្សា ចុះមូលដ្ឋានស្រុកបុរីអូរស្វាយសែនជ័យ, ឯកឧត្តមអភិបាលរង នៃគណៈអភិបាលខេត្ត ចុះមូលដ្ឋាន ស្រុកបុរីអូរស្វាយសែនជ័យ, លោកស្រី បួរ ខាំតង ប្រធានក្រុមប្រឹក្សាស្រុកបុរីអូរស្វាយសែនជ័យ, លោក លី មីណា អភិបាល នៃគណៈអភិបាល ស្រុកបុរីអូរស្វាយសែនជ័យ, ឯកឧត្តម លោក លោកស្រី ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ស្រុកបុរីអូរស្វាយសែនជ័យ, លោកស្នងការ មេបញ្ជាការ កងកម្លាំងប្រដាប់អាវុធទាំងបីប្រភេទ, លោកអភិបាលក្រុងស្រុក នៃខេត្តស្ទឹងត្រែង។

កម្មវិធីសម្ពោធ«អគារមរតកសង្គមរាស្រនិយម សម្តេចឪ-សម្តេចម៉ែ បុរីអូរស្វាយ-សែនជ័យ» នៅថ្ងៃនេះមានការនិមន្តនិងអញ្ជើញចូលរួមពីព្រះសង្ឃចំនួន៧អង្គ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និគមន៍ជនសង្គមរាស្ត្រនិយម អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសិស្សានុសិស្ស សរុបទាំងអស់ចំនួន៥០០នាក់។

សម្តេចរាជបុត្រី ព្រះអនុជ នរោត្តម អរុណរស្មី មានព្រះរាជបន្ទូលថា៖ «ក្នុងព្រះនាមព្រះអង្គ សូមថ្លែងអំណរគុណ និងកោតសរសើរយ៉ាងជ្រាលជ្រៅបំផុតចំពោះ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងព្រះរាជបណ្ណាល័យហ្វូងម៉ែ ចំពោះការលះបង់ និងទស្សនវិស័យក្នុងការបង្កើតសាខាមជ្ឈមណ្ឌលឯកសារកម្ពុជាដ៏សំខាន់នេះ នៅក្នុងខេត្តស្ទឹងត្រែង។ ព្រះអង្គមានព្រះរាជបន្ទូលបន្តទៀតថា «កន្លែងនេះគឺជាកេរដំណែលដ៏យូរអង្វែង ដែលគាំទ្រដល់និស្សិត អ្នកស្រាវជ្រាវ និងប្រជាពលរដ្ឋទាំងអស់ក្នុងការស្វែងយល់ពីប្រវត្តិសាស្ត្រវប្បធម៌ និងសិល្បៈ

សហសម័យដ៏សម្បូរបែបរបស់ប្រទេសកម្ពុជា»។

អ្នកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានចូលរួមក្នុងកម្មវិធីនេះ មានប្រសាសន៍ថា ពិធីសម្ពោធ «អគារមរតកសង្គមរាស្ត្រនិយម សម្ដេចឪ- សម្ដេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នេះ គឺជាការរីកចំណាំសហប្រតិបត្តិការរវាងប្រទេសតួកគី និងប្រទេសកម្ពុជា រួមជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីជួយសម្រាលដល់ប្រជាជននៅទីជនបទឆ្ងាយដាច់ស្រយាលតាមរយៈការផ្ដល់សេវាកម្មសង្គម ការអប់រំអំពីសុខភាព និងចំណេះដឹងអំពីប្រវត្តិសាស្ត្រកម្ពុជា។ សមិទ្ធផល និងកិច្ចការទាំងនេះជួយផ្សព្វផ្សាយដល់វិស័យទេសចរណ៍ និងទាក់ទាញភ្ញៀវទេសចរឱ្យមកកម្សាន្ត និង ទស្សនាតំបន់នេះដើម្បីជួយបង្កើនប្រាក់ចំណូលដល់ប្រជាជននៅក្នុងសហគមន៍»។

បន្ទាប់ពីចប់កិច្ចសហការដំណាក់កាលទី១ ជាមួយសមិទ្ធផលដែលបានកសាងរួចនៅឆ្នាំ២០២៥នេះ ព្រះរាជបណ្ណាល័យហ្វូងម៉ៃនៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងរដ្ឋបាលស្រុកបុរីអូរស្វាយ-សែនជ័យ ចាប់ផ្ដើមសិក្សាគម្រោងអភិវឌ្ឍន៍បុរីអូរស្វាយ-សែនជ័យ ដំណាក់កាលទី២ ដែលមានឈ្មោះថា «កែប្រែសណ្ឋានដីបន្សល់ទុកពីសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ទៅជាសណ្ឋានដីសន្តិភាព និងការអភិវឌ្ឍន៍»។ គម្រោងនេះរួមមាន៖ ការកសាងផ្លូវមាត់ទន្លេ, ផ្លូវលំហែហាត់ប្រាណក្នុងភូមិ, កសិដ្ឋានសហគមន៍ រោងពាណិជ្ជកម្មសហគមន៍, ផ្ទះលំហែសហគមន៍, សួនច្បារប្រវត្តិសាស្ត្រ, រូបចម្លាក់, បង្កាន់ដៃសុវត្ថិភាពប្រាំងទន្លេ និងស្លាកសញ្ញាសហគមន៍។ លោក ឆាំង យុ រំពឹងថា ទីតាំងប្រវត្តិសាស្ត្របែបនេះគួរត្រូវបានការពារដោយច្បាប់របស់រដ្ឋ។

ជាមួយនឹងទីតាំងតែមួយគត់នៅតាមព្រំដែនកម្ពុជា និង ឡាវ សហគមន៍បុរីអូរស្វាយ-សែនជ័យគឺជាសហគមន៍កោះដែលមានប្រវត្តិវប្បធម៌ដ៏សម្បូរបែប ជីវចម្រុះ និងបរិស្ថានទន្លេ-កោះ ដែលមានសក្ដានុពលយ៉ាងសំខាន់សម្រាប់ទេសចរណ៍កម្ពុជា និងបរទេស។







ពិធីសម្ពោធអគារមរតកសង្គមរាស្ត្រនិយម សម្ដេចឪ- សម្ដេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៅថ្ងៃអាទិត្យ ទី១ ខែមិថុនា ឆ្នាំ២០២៥ ក្រោមកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជាសាខាខេត្តស្ទឹងត្រែង ជាមួយរដ្ឋបាលស្រុកបុរីអូរស្វាយសែនជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សហគមន៍បុរីអូរស្វាយ-សែនជ័យ មានកោះចំនួនប្រាំមួយ (កោះនីមួយៗមានភូមិរបស់ខ្លួន) កំពង់ផែ និងមន្ទីរពេទ្យតូចមួយដែលសាងសង់ដោយសម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។ ដោយសារសហគមន៍ភាគច្រើនគឺជាកោះ និងមានទីតាំងស្ថិត

នៅតំបន់ដាច់ស្រយាលតាមព្រំដែន ដែលជាទូទៅសហគមន៍នេះត្រូវនៅឯកោពីប្រភពធនធាន សេវាសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធ ដាច់ទាក់ទងជាមួយប្រទេសកម្ពុជា និងតំបន់អភិវឌ្ឍន៍នានា។ បើទោះបីជាសហគមន៍នេះមានភាពលេចធ្លោជាបន្ទាយកងទ័ពប្រវត្តិសាស្ត្រដែលបង្កើតឡើងដោយសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋក៏ដោយ ប្រវត្តិសាស្ត្ររបស់តំបន់នេះមិនទាន់មានឯកសារច្បាស់លាស់នៅឡើយ ហើយសម្រាប់ហេតុផលនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងសិក្សាលទ្ធភាពនៃការកំណត់តំបន់នេះ ជាតំបន់ការពារដោយរាជរដ្ឋាភិបាលកម្ពុជា។

សហគមន៍បុរីអូរស្វាយ-សែនជ័យ មានសារសំខាន់សម្រាប់ហេតុផលបីយ៉ាងគឺ៖ ទី១) ក្នុងនាមជាអតីតបន្ទាយកងទ័ពមួយរបស់សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ សម្រាប់ការពារព្រំដែនកម្ពុជា ដែលព្រះរាជវង្សានុវង្សកម្ពុជាចាត់ទុកថាជាទីតាំងប្រវត្តិសាស្ត្រដ៏សំខាន់មួយ ហើយដែលមានរូបសំណាកអតីតព្រះមហាក្សត្រ ហើយសហគមន៍បុរីអូរស្វាយ-សែនជ័យ មានសំណង់វប្បធម៌ដទៃទៀត និងប្រវត្តិសាស្ត្រផ្ទាល់ និងជាកេរដំណែលរបស់សម្តេចព្រះ នរោត្តម សីហនុ (ព្រះបរមរតនកោដ្ឋ) ក្នុងនាមជាអ្នកបង្កើតប្រទេសកម្ពុជាសម័យទំនើប។ ទី២) កងទ័ពចាស់ៗសម័យសង្គមរាស្ត្រនិយមមួយចំនួនដែលមកពីក្រៅសហគមន៍បុរីអូរស្វាយ-សែនជ័យ បានបន្តរស់នៅក្នុងតំបន់នេះជាមួយក្រុមគ្រួសាររបស់ខ្លួន។ ទី៣) សហគមន៍នេះមានទឹកទន្លេដ៏ស្រស់ស្អាតបរិស្ថានបរិសុទ្ធ និងមានជីវចម្រុះដ៏សម្បូរបែប ធ្វើឱ្យសហគមន៍នេះមានភាពកាន់តែលេចធ្លោ និងមានតម្លៃជាតំបន់អេកូទេសចរណ៍ និងទទួលបាននូវការការពារដោយអនុសញ្ញាអន្តរជាតិ ជាមួយនឹងឱកាសពាណិជ្ជកម្មបន្ថែមតាមរយៈការដាំដុះ និងពាណិជ្ជកម្មកាហ្វេនៅជាប់ជាមួយព្រំដែន ឡាវ។

ភ្ញៀវទេសចរជាតិ និងអន្តរជាតិនឹងចាប់អារម្មណ៍សហគមន៍បុរីអូរស្វាយ-សែនជ័យ ដោយសារជាស្នាព្រះហស្តរបស់សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ មកកសាងក្នុងតំបន់នេះដំបូង ហើយបានបន្សល់នូវសំណង់វប្បធម៌ និងប្រវត្តិសាស្ត្រ និងស្តូបបុរីអូរស្វាយរបស់ព្រះអង្គ។ ភ្ញៀវទេសចរបរទេសនឹងត្រូវបានទាក់ទាញទៅកាន់បរិស្ថាន និងជីវចម្រុះបន្ថែមពីលើតំបន់ដែលស្ថិតនៅតាមបណ្តោយព្រំដែនកម្ពុជា និង ឡាវ។ កោះមួយក្នុងចំណោមកោះជាច្រើនក្នុងស្រុកបុរីអូរស្វាយសែនជ័យ ដែលអ្នកស្រុកក្នុងតំបន់នេះហៅថា «កោះទន្សាយ» មានឆ្នេរខ្សាច់ពណ៌សក្បុសដូចសំឡីគួរជាទីទាក់ទាញ។ គួររំឭកដែរថា ឃុំអូរស្វាយក្នុងខេត្តស្ទឹងត្រែង គឺជាផ្នែកមួយនៃតំបន់រ៉ាមសារ ដែលជាតំបន់សើមដែលមានសារសំខាន់ជាអន្តរជាតិ។ តំបន់រ៉ាមសារស្ទឹងត្រែង គ្របដណ្តប់លើដងទន្លេមេគង្គប្រវែង ៣៧ គីឡូម៉ែត្រ និងមានភូមិចំនួន ២១ ដែលមានប្រជាជនជាង ១៣.០០០ នាក់។ ឃុំអូរស្វាយ ស្ថិតនៅក្នុងតំបន់ការពារនេះ។ អនុសញ្ញារ៉ាមសារ ដែលត្រូវបានគេស្គាល់ជាផ្លូវការថាជា «អនុសញ្ញាស្តីពីតំបន់ដីសើមនៃសារសំខាន់អន្តរជាតិជាពិសេសជាជម្រកសត្វទឹក» គឺជាសន្ធិសញ្ញាអន្តរជាតិដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៧១ ដើម្បីលើកកម្ពស់ការអភិរក្ស និងការប្រើប្រាស់ដីសើមប្រកបដោយភាពឆ្លាតវៃ។ អនុសញ្ញានេះត្រូវបានដាក់ឈ្មោះតាមទីក្រុង រ៉ាមសារប្រទេសអ៊ីរ៉ង់ ជាកន្លែងដែលវាត្រូវបានចុះហត្ថលេខា។ អនុសញ្ញានេះមានគោលបំណងបញ្ឈប់ការបាត់បង់ដីសើមទូទាំងពិភពលោក និងធានាការគ្រប់គ្រងប្រកបដោយនិរន្តរភាពរបស់ខ្លួនតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការបង្កើតគោលនយោបាយ។

វិស័យទេសចរណ៍មិនមែនជាមធ្យោបាយសម្រាប់សហគមន៍ក្រីក្រ និងដាច់ស្រយាលនោះទេ ប៉ុន្តែវាគឺជាមធ្យោបាយមួយដើម្បីកែលម្អសេដ្ឋកិច្ចសង្គមរបស់សហគមន៍ដែលសក្តានុពលសម្រាប់ទេសចរណ៍នៅតែមិនទាន់ត្រូវបានប្រើប្រាស់។ ទេសចរណ៍អាច

បង្កើតឱកាសការងារដោយផ្ទាល់ក្នុងវិស័យផ្សេងៗ ដូចជាបង្កើតប្រាក់ចំណូលតាមរយៈការលក់ផលិតផល និងសេវាកម្មក្នុងស្រុកជូនភ្ញៀវទេសចរជុំវិញការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងការលើកកម្ពស់ការអភិរក្សវប្បធម៌ ដែលទាំងអស់នេះអាចរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងកំណើនសេដ្ឋកិច្ចនៅក្នុងសហគមន៍។

មជ្ឈមណ្ឌលឯកសារកម្ពុជាសាខាខេត្តស្ទឹងត្រែងសហការជាមួយរដ្ឋបាលស្រុកបុរីអូរស្វាយ-សែនជ័យ បានធ្វើការស្រាវជ្រាវលើគម្រោង«ការអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌ និងទេសចរណ៍បរិស្ថាន» ប្រកបដោយនិរន្តរភាពនៅក្នុងសហគមន៍ទន្លេ-កោះចំនួន៦ តាមបណ្ដោយព្រំដែនកម្ពុជា និង ឡាវ ដែលប្រជាជនស្គាល់ថា បុរីអូរស្វាយ-សែនជ័យ។

សម្ដេចរាជបុត្រី ព្រះអនុជ នរោត្តម អរុណរស្មី មានព្រះរាជបន្ទូលថា៖ ពិធីសម្ពោធ «អគាររមរតសង្គមរាស្ត្រនិយម សម្ដេចឪ-សម្ដេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)» គឺជាការលើកតម្កើងនូវសមិទ្ធផលដ៏មានតម្លៃនៃសម័យសង្គមរាស្ត្រនិយម តំណាងឱ្យព្រឹត្តិការណ៍ដ៏សំខាន់ក្នុងការបន្តកិច្ចខិតខំប្រឹងប្រែងរបស់ជាតិយើង ដើម្បីលើកកម្ពស់ការសិក្សាស្រាវជ្រាវ ការអប់រំ និងសិល្បៈ។

លោក ឆាំង យុ បានសរសេររៀបរាប់សេចក្ដីបញ្ចប់ថា ៖ «ក្នុងអំឡុងខែធ្លាក់ខ្យល់នៅកម្ពុជា ទឹកទន្លេមេគង្គបានប្រែពណ៌ ហាក់ដូចជាប្រាប់យើងថារដូវវស្សាកំពុងមកដល់ ហើយយើងនៅតែមានភាពភ្ញាក់ផ្អើលជាមួយនឹងពន្លឺដ៏ចែងចាំងដែលនៅតែបន្តរះរាំលើផ្ទៃទឹកនៅពេលថ្ងៃរះ និងពេលថ្ងៃលិច ក្នុងតំបន់បុរីអូរស្វាយ-សែនជ័យ។ ខ្សាច់ពណ៌សដូចដុំពពកលើមេឃនៅលើកោះទន្សាយ រួមទាំងប្រជាជនដែលរស់នៅជុំវិញប្រជុំកោះទាំងនោះ គឺអស្ចារ្យខ្លាំងណាស់ ហើយរដូវធ្លាក់ខ្យល់នៅទីនេះ ហាក់ដូចជាខ្យល់នៅលើកំពូលអគារនានិទាឃរដូវទីក្រុងប៉ារីសដូច្នេះដែរ»។



ពិធីសម្ពោធអគាររមរតកសង្គមរាស្ត្រនិយម សម្ដេចឪ-សម្ដេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៅថ្ងៃអាទិត្យ ទី១ ខែមិថុនា ឆ្នាំ២០២៥ ក្រោមកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជាសាខាខេត្តស្ទឹងត្រែង ជាមួយរដ្ឋបាលស្រុកបុរីអូរស្វាយសែនជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)









*ពិធីសម្ពោធអគាររមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៅថ្ងៃអាទិត្យ ទី១ ខែមិថុនា ឆ្នាំ២០២៥ ក្រោមកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តស្ទឹងត្រែង ជាមួយរដ្ឋបាលស្រុកបុរីអូរស្វាយសែនជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# ខួប ៥ឆ្នាំ ព្រះរាជបណ្ណាល័យហ្លួងម៉ែ

ឆាំង យុ



សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ សូមព្រះរាជានុញ្ញាតក្រាបថ្វាយបង្គំសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម គម្រប់ ៨៩ ព្រះវស្សា យាងចូល ៩០ ព្រះវស្សា នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥។

ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ រចនាឡើងក្នុងនាមជាបូជនីយដ្ឋានពហុវិស័យ ដែលតំណាងឱ្យសាមគ្គីភាព និងការបង្ហាញថ្នាក់ជាតិរបស់កម្ពុជា។ មជ្ឈមណ្ឌលឯកសារកម្ពុជា ប្តេជ្ញាចំពោះការបង្កើតបូជនីយដ្ឋាននេះ ដើម្បីជាកេរដំណែលថ្វាយចំពោះសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល និងស្រ្តីកម្ពុជាជារួម។





*សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ក្នុងនាមជាតង្វាយថ្វាយចំពោះសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ គឺជានិមិត្តរូបនៃព្រះរាជតួនាទីដ៏មានឥទ្ធិពលប៉ុន្តែប្រកបដោយភាពសាមញ្ញរបស់ព្រះអង្គ ក្នុងព្រះរាជកិច្ចត្រួសត្រាយផ្លូវដើម្បីស្តារឡើងវិញនូវស្ថិរភាពរបស់ព្រះរាជាណាចក្រកម្ពុជា, បំភ្លឺសេចក្តីសង្ឃឹមជាថ្មីម្តងទៀត ព្រមទាំងព្រះរាជកាយវិការសន្តោសប្រោសព្រំចំពោះភាពប្រសើរថ្លៃថ្លា និងតម្លៃមនុស្សជាតិនៅក្នុងសង្គមកម្ពុជា ក៏ដូចជារំលេចអំពីភាពចាំបាច់នៃសុច្ចរិតភាពក្នុងការរក្សានូវសម្ព័ន្ធភាពល្អប្រសើរជាមួយសង្គមខាងក្រៅ នៅក្នុងបរិបទចម្រូងចម្រាសនៃពិភពលោកសព្វថ្ងៃ។ បូជនីយដ្ឋាននេះ នឹងបំពេញតួនាទីជាការក្រើនរំឭកចំពោះព្រះរាជតួនាទីដ៏សំខាន់ជានិរន្តរបស់ព្រះអង្គ ដែលជាកត្តាជំរុញស្មារតីសម្រាប់មនុស្សជំនាន់ក្រោយ ចំពោះការតស៊ូយ៉ាងស្វិតស្វាញរបស់ប្រជាជាតិនេះ ក្នុងដំណើរសះស្បើយ និងស្តារឡើងវិញរបស់ខ្លួន។

នៅក្នុងកិច្ចខិតខំប្រឹងប្រែងឥតស្រាកស្រាន្ត និងយ៉ាងប្តូរផ្តាច់របស់ខ្លួន ដែលតែងតែប្រព្រឹត្តទៅយ៉ាងស្ងប់ស្ងាត់ ស្ត្រីកម្ពុជាបានរែកពុនបន្ទុកក្នុងការរក្សាស្ថិរភាព កសាងឡើងវិញ និងផ្តល់អានុភាពដល់សង្គមកម្ពុជា នៅក្នុងយុគសម័យដ៏ខ្មៅងងឹតតាមរយៈការផ្តល់កំណើតនិងបីបាច់ថែរក្សាកូនចៅ និងកសាងគ្រួសារដែលទទួលរងភាពខ្ទេចខ្ទាំ ថ្វីត្បិតតែមិនមែនជាកំហុសរបស់ខ្លួនយ៉ាងណាក្តី។ ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ នឹងជានិមិត្តរូបនៃសេចក្តីប្តេជ្ញាតស៊ូរបស់ស្ត្រីកម្ពុជា ក្នុងការបង្កើតជាថ្មីនូវទំនៀមទម្លាប់ពីបុរាណកាលនៃតម្លៃនិងវប្បធម៌របស់កម្ពុជា, ពង្រីកឱកាសសេដ្ឋកិច្ច និងអភិរក្សកេរដំណែលនៃសហគមន៍ដ៏រឹងមាំ។ ស្ត្រីកម្ពុជា តំណាងឱ្យភាពអង់អាច និងសុទិដ្ឋិនិយមរបស់កម្ពុជា ដែលជានិមិត្តរូបដ៏ប្រពៃដែលព្រះរាជបណ្ណាល័យ ហ្វូងម៉ែ ព្យាយាមរក្សានិងរំលេចចេញដោយមោទកភាព។

# របាយការណ៍សភាពការណ៍យោធាថៃ ចូលមកអុកឡុកព្រំដែនកម្ពុជា-ថៃ ក្នុងរបបខ្មែរក្រហម
## ទូរលេខ ៦០៖ គោរពជូនគណៈ ៨៧០ ជាទីស្នេហា និងរឭក

*ដកស្រង់ចេញពីឯកសារទូរលេខ D០១៧៨៩*

*មីន សាណាស់*



*កងទ័ពបដិវត្តន៍ខ្មែរក្រហមប្រចាំនៅច្រកព្រំដែនប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ចាប់ដៃជាមួយ ចច គ្រីម នៅលើស្ពានទ១ច្រកព្រំដែនប៉ោយប៉ែតរវាងកម្ពុជា និងថៃ ត្រូវបានខ្មែរក្រហមបិទទាំងស្រុងបន្ទាប់ពីឡើងគ្រប់គ្រងអំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

សូមរាយការណ៍អំពីសភាពការណ៍គ្រប់ផ្នែកមួយចំនួនដូចខាងក្រោមនេះ៖

អំពីសភាពការណ៍ខ្មាំងខាងក្រៅ៖ អំពីសភាពការណ៍នៅតាមព្រំដែនថៃ ក្នុងប៉ុន្មានថ្ងៃនេះខ្មាំងថៃមានការអុកឡុកយើង តាមព្រំដែនជាបន្តបន្ទាប់ដូចតទៅនេះ

**១. ថ្ងៃ២៧ ខែ៨** ខ្មាំងថៃវាយចូលមកដីយើង ១កងអនុសេនាធំ ចម្ងាយពីព្រំដែន១គីឡូម៉ែត្រកន្លះនៅមុខផ្កាមរមាស យើងបានប្រយុទ្ធជាមួយវារយៈ១ម៉ោង វាបាក់ទ័ពរត់ទៅវិញអស់ ខ្មាំងមានងាប់និងរបួសមួយចំនួន។ បន្ទាប់មកវាដឹកទ័ពមកបន្ថែមទៀតមួយចំនួនច្រើនយើងវាយវាម្តងទៀតវាថយទៅវិញអស់។ យើងយកបានសម្ភារវាមួយចំនួន មានគ្រាប់អ៊ែកែង អឹម៧៩ មួយចំនួន និងមួក ពីដុងទឹក កាំបិតខ្លះៗ ខាងយើងបានបន្ថែមកងទ័ព៥០នាក់ ទៅត្រៀមកន្លែងប្រយុទ្ធខាងមុខៗ

**៧. នៅថ្ងៃបន្ទាប់** ខាងកើតត្រពាំងគោ ជាប់និងផ្កាមរមាស មានយន្តហោះធុនមិចហោះលើភូមិចំនួនពីរដង។

**៣. ថ្ងៃ៣០ ខែ៨** មានយន្តហោះខ្មាំងធុនមិចហោះលើព្រំដែនយើងខាងក្បាលស។

**៤. ថ្ងៃទី៣១ ខែ៨** កងទ័ពយើងបានឃើញដានខ្មាំងមកពីភូមិសិទ្ធិសេរីភាពទៅជើង យើងតាមវាទាន់បានបាញ់វា វាបាញ់តបយើងវិញ យើងដេញបាញ់វាវារត់ចូលព្រៃបាត់។ សុំបញ្ជាក់ អំពីសភាពការណ៍ខ្មាំងចូលដីយើងមាន៣ខែ្សក្នុងមួយខែ្សៗ ១កងអនុសេនាធំ ក្រោយពេលដែលយើងបាញ់វា វារត់ដកថយវិញ មានយន្តហោះកន្ទុំរុយ១គ្រឿង ចុះនៅមុខកន្លែងប្រយុទ្ធ តែមិនដឹងវាចុះដាក់ទ័ពឬ ចុះយកខ្មោចវាទេ។ ក្នុងពេលជាមួយគ្នានោះ មានយន្តហោះស្កាបកាត់ ២គ្រឿង ហោះក្រឡឹងលើគ្នាវា នឹងលើកន្លែងប្រយុទ្ធសារចុះសារឡើង។ សរុបមកអំពីសភាពការណ៍ខ្មាំងនៅតាមព្រំដែនថៃបច្ចុប្បន្ននេះខុសប្លែកពីមុន ដោយពីមុនវា ប្រើចារកម្មវាឱ្យចូលទឹកដីយើង ឥឡូវនេះ វាប្រើខាងយោធាឱ្យអុក ឡុកព្រំដែនយើង តែយោធាវាគ្មានលទ្ធភាពវាយយើងដោយជិហរទេ វាត្រៀមវាយយើងជាវិធីឈ្លប វាការពារខ្លាចយើងទៅវាយវាតែប៉ុណ្ណោះ។

**៥. វិធានការ ៖** យើងណែនាំខាងយោធាការពារព្រំដែនឱ្យយកចិត្តទុកដាក់និងប្រុងប្រយ័ត្នជាប់ ទាំងការយាមល្បាត ទាំងបង្កើនការចាក់ចម្រូងតាមមុខសញ្ញានីមួយៗ ធានាអះអាង បានក្នុងការការពារ ក៏ដូចជាការវាយសម្រុកខ្មាំងឱ្យបានជាបន្តបន្ទាប់ ទាំងខ្មាំងយោធា ក៏ដូចជាខ្មាំងចារកម្ម។

**អំពីសភាពការណ៍ខ្មាំងខាងក្នុង៖** នៅតាមមូលដ្ឋាននៅតាមមន្ទីរក្រសួង និងយោធាយើងបានរកឃើញខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងជាបន្តបន្ទាប់ ទាំងការតាមដានសកម្មភាពក្បត់ប្រឆាំងបដិវត្តន៍ទាំងតាមចម្លើយ។ ឯពួកខ្មាំងជារដ្ឋការនិងប៉ូលីស ទាហានចាស់ យើងរកឃើញជាបន្តបន្ទាប់។ ចំពោះខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងបើប្រៀបធៀបពីមុនឥឡូវនេះយើងកាន់ថមថយចុះបណ្តើរៗហើយ មាននៅសល់ដៃជើងវាបន្តិចបន្តួចៗតទៅទៀតជាវិធានការយើងបន្តការបោសសម្អាតខ្មាំង ទាំងនោះជាបន្តបន្ទាប់។ ដំណោះស្រាយក្នុងការចលនាប្រយុទ្ធគ្រប់ផ្នែក ពិសេសយកចលនាបង្កបង្កើនផលជាគន្លឹះដើម្បីរកខ្មាំង គឺរកក្នុងសមរភូមិប្រយុទ្ធសម្រិតសម្រាំង និងបោសសម្អាត។

**សភាពការណ៍ប្រជាជន៖** ទាំងនយោបាយ សតិអារម្មណ៍ ចាត់តាំងគ្មានអ្វីប្រែប្រួលទេ ភាគច្រើនទូទាំងភូមិភាគ មានការប្រយុទ្ធបង្កបង្កើនផលយ៉ាងខ្លាំងក្លាតាមមាគ៌ាបង្កបង្កើនផលតែក៏នៅមានមួយចំនួនតិចតួចនៅបំភ្លៃសមាគ៌ាបង្កបង្កើនផល នៅមានប្រឆាំងបដិវត្តន៍តាមវិធីស្របច្បាប់តាម ទម្លាប់ចាស់និងតាមរបៀបរបបចាស់ តាំងពីរភ្ជួររាស់ ដក ស្ទូងសាបព្រួស នៅរឹងរូសចចេសមិនព្រមតាមមាគ៌ាបង្កបង្កើនផល។ វិធានការយើងអប់រំបំពាក់មាគ៌ាបង្កបង្កើនផលច្រើនលើកច្រើនដងហើយ យើងបែងចែកអ្នកមិនទាន់យល់និងអ្នកប្រឆាំង ទន្ទឹងនឹងនេះយើងមានវិធានការទៅតាមការជាក់ស្តែង។

**សភាពការណ៍យោធាយើង៖** ក្រោយពីបានសម្រិតសម្រាំងនិងអប់រំបំពាក់នយោបាយ សតិអារម្មណ៍ចាត់តាំងជាបន្តបន្ទាប់មក យុទ្ធជនយើងមានការប្រយុទ្ធទាំងនយោបាយ សតិអារម្មណ៍ និងចាត់តាំងទាំងសមរភូមិការពារព្រំដែន ទាំងសមរភូមិបង្កបង្កើនផលបានខ្លាំងក្លាភាគច្រើន។ ឯភាគតិចតួចដែលជាដៃជើងខ្មាំងបង្កប់ពីមុន ក៏នៅមានសេសសល់ខ្លះៗកាលពីថ្ងៃ៣១ ខែ៨ មានឈ្មោះអាហាយ ជាសមាជិកកងអនុសេនាតូច រត់ទៅថៃ វាយកកាំភ្លើងបានពីរដើមជាប់ទៅជាមួយ កាំភ្លើងខ្លីមួយដើម កាំភ្លើងអឹម៧៩ មួយដើម និងត្រីវិស័យមួយ។ ឯមួយចំនួនទៀតសមាសភាពអាក្រក់ និងសេរីយើងដកចេញពីកងទ័ពឱ្យមកបង្កបង្កើនផលនៅក្រោយ ហើយទន្ទឹមនឹងនេះ យើងមានវិធានការអប់រំ និងសម្រិតសម្រាំងជាបន្តបន្ទាប់។ ព្រមជាមួយនេះត្រៀមលក្ខណៈសម្បត្តិជ្រើសរើសទាំងយុទ្ធជនចាស់ ទាំងយុទ្ធជន

ថ្មីដែលល្អនៅខាងក្រោយឱ្យទៅជំនួសយុទ្ធជនដែលត្រូវសម្រិតសម្រាំងនៅឯសមរភូមិការពារខាងមុខ។

**សភាពការណ៍បង្កបង្កើនផលគ្រប់ស្រុកទូទាំងភូមិភាគ៖** មកដល់ថ្ងៃនេះស្រុកមួយចំនួនតិចស្ទូងបាន២ភាគរយហើយ ឯស្រុកចំនួនច្រើន ស្រុកខ្លះបានពី៣០ភាគរយ ៤០ភាគរយ ៥០ភាគរយ ៦០ភាគរយហើយ បើសរុបទូទៅក្នុងភូមិភាគបាន៤០ភាគរយហើយ។ សព្វថ្ងៃកំពុងបន្តការប្រយុទ្ធបង្កបង្កើនផលយ៉ាងខ្លាំងក្លា។ បើពិនិត្យដើមរដូវនៃការដកស្ទូងមួយចំនួនតិចមិនសូវល្អ មូលហេតុរាំងស្ងួត ភ្លៀងធ្លាក់រអាក់រអួល។ ស្ទូងក្រោយភាគច្រើនសន្ទូងមានដើមល្អមកពីមានទឹកគ្រប់គ្រាន់ មានកន្លែងខ្លះទឹកជន់លិចសន្ទូង តែមិនមានឱ្យអន្តរាយធំដុំទេមានខូចខាតតែបន្តិចបន្តួចទេ។

**ជីវភាពប្រជាជន៖** ក្រោយពីអង្គការចែកស្រូវជូនប្រជាជនតំបន់៤៤ រួមជារួម ដំឡូង ពោតក្តួច និងបន្លែបង្ការត្រី- សាច់ ការដោះស្រាយជីវភាពបានធូរស្រាលហើយបង្កើនការវាយសំរុកបង្កបង្កើនផលក៏បានខ្លាំងក្លា ការឈឺថ្កាត់ក៏ស្បើយ។ តែបើពិនិត្យការខ្វះខាតមានទំហំធំ ដូច្នេះក៏មិនអាចឆ្លងកាត់ខែ៩ នេះរួចបានដែរ។ បើដល់ខែ១០ ទើបទាន់ស្រូវចម្ការ។ ឯស្រូវ ពោត សណ្តែក ដែលធ្វើឆ្លងកាត់ពីដើមឆ្នាំនោះត្រូវរាំងស្ងួតខូចខាតអន្តរាយអស់។ ចំពោះតំបន់១០៣ មានដំឡូង ពោត ចេករួមជារួម និងស្រូវយកពីស្រុកដែលមានទៅចែកស្រុកខ្វះ ទូទាត់ទៅដោះស្រាយរួច។ តំបន់៤៤ ដែលមានសភាពការណ៍ខ្វះខាត ដូច្នេះស្រុកដែលមានការខ្វះខាតជាងគេមានការលួចស្រូវ លួចដកដំឡូង និងកាប់ផ្លែចេក តែចំនួននេះមានតិចតួចទេ ហើយក៏សុទ្ធតែមិនសូវធ្លាប់ខិលខូចពីមុនដែរ។

ជូនពរសុខសប្បាយ និងជ័យជម្នះ!

ថ្ងៃទី៤ - ៩

ភូមិភាគ ៨០១ សែ

ទទួលថ្ងៃទី៦-៩-៧៧ ម៉ោង០៧ ០០

ចម្លងជូន៖ អ៊ំ អ៊ំនួន បងវ៉ាន់ បងវន បងខៀវ មន្ទីរឯកសារ



ជនបរទេសហុចកញ្ចប់បារីឱ្យកងទ័ពបដិវត្តន៍ខ្មែរក្រហមប្រចាំនៅច្រកព្រំដែនប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ពីខាងទឹកដីថៃ ដែលខណ្ឌដោយលួសបន្លា។ ច្រកព្រំដែនប៉ោយប៉ែតរវាងកម្ពុជា និងថៃ ត្រូវបានខ្មែរក្រហមបិទទាំងស្រុងបន្ទាប់ពីឡើងគ្រប់គ្រងអំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ម៉ៃ ផូរ អប់រំថា ៖«ឯងធ្វើបដិវត្តន៍នឹងគេដែរ ម៉េចក៏នៅតែរហាមអញ្ជឹង?»

*លី សុខឃាង*



*កងទ័ពបដិវត្តន៍ខ្មែរក្រហមនៅភូមិភាគបូព៌ាដែលរត់គេចខ្លួនពីការតាមចាប់របស់មជ្ឈិមបក្សលាក់ខ្លួននៅក្នុងចម្ការកៅស៊ូ ក្នុងខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

«ឯងធ្វើបដិវត្តន៍នឹងគេដែរ ម៉េចក៏នៅតែរហាមអញ្ចឹង? ធ្វើបដិវត្តន៍ កុំខ្ជះពេក កុំធ្វើក្រពេក បដិវត្តន៍អ្នកណា គេធ្វើដូចឯងនោះ?» ចំណែកឯការប្រើប្រាស់សម្ភារផ្សេងៗវិញ ម៉ៃ ផូរ ក៏បានណែនាំ យឿន ថា៖ «បើខូច ត្រូវផ្លាស់ភ្លាម កុំធ្វើប្ញករហាមពេក»។ នេះគឺជាសម្ដីរបស់ ម៉ៃ ផូរ ដែលជាគណៈស្រុកមេមត់ ទៅកាន់ ពេជ្រ យឿន ដើម្បីជំរុញឱ្យធ្វើសកម្មក្បត់បដិវត្តន៍។ ពេជ្រ យឿន គឺជាអ្នកបើកឡានឱ្យ ម៉ៃ ផូរ។

នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៧៧ ពេជ្រ យឿន ត្រូវបានចាប់ខ្លួននិងសួរចម្លើយ ដោយមានស្នាមផ្ដិតមេដៃនៅផ្នែកខាងក្រោមបង្អស់ និងផ្នែកខាងលើបង្អស់នៃចម្លើយសារភាពមានអក្សរថា «ក្រសួងសន្តិសុខតំបន់២១»។ ចម្លើយសារភាពរបស់ ពេជ្រ យឿន មានសង្ខេបដូចខាងក្រោម៖

ពេជ្រ យឿន ហៅ ជុំ ដួង ប្ញ សី អាយុ៣០ឆ្នាំ មានទីកន្លែងកំណើតនៅភូមិខ្ពប ឃុំរំចេក ស្រុកមេមត់ ខេត្តកំពង់ចាម។ យឿន បានរស់នៅជាមួយឪពុកម្ដាយ និងប្រកបរបរកសិកម្ម។ ឪពុករបស់ យឿន មានឈ្មោះ ពេជ្រ ជុំ មានវ័យ៥០ឆ្នាំ និងម្ដាយឈ្មោះ ខៀវ យិន ធ្វើការងារនៅក្នុងសហករណ៍ភូមិខ្ពប។ យឿន មានប្អូនស្រីម្នាក់ឈ្មោះ គង់ ជា មានអាយុ១៨ឆ្នាំ និងធ្វើការនៅក្នុងកងចល័តឃុំរំចេក។

នៅក្នុងជំនាន់បារាំង ក្រុមគ្រួសាររបស់ យឿន ត្រូវបានជម្លៀសពីភូមិខ្ពប ទៅកាន់ភូមិកំពង់ស្រែ ឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ អស់រយៈពេល៣ឆ្នាំ។

យឿន និងក្រុមគ្រួសារបានវិលត្រឡប់មកភូមិកំណើតវិញ បន្ទាប់ពីមានសន្ធិសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៤។ ពីរឆ្នាំក្រោយមក យឿន បានចាប់ផ្តើមចូលរៀនសូត្រនៅសាលាវត្តខ្ពបអស់រយៈពេល៤ឆ្នាំ មុនពេលត្រឡប់មកជួយការងារស្រែចម្ការរបស់ឪពុកម្តាយវិញ។

បន្ទាប់ពីឈប់រៀន យឿន បានទទួលការអប់រំអំពីគោលជំហរបដិវត្តន៍ពីសំណាក់ សុង, រី, និង ស៊ីម ហើយក៏បានសម្រេចចិត្តចូលធ្វើបដិវត្តន៍នៅក្នុងឆ្នាំ១៩៦៧។ ភារកិច្ចចម្បងរបស់ យឿន គឺផ្តល់ព័ត៌មានពីភូមិខ្ពប ទៅកាន់កម្លាំងនៅក្នុងព្រៃ។ នៅក្នុងឆ្នាំ១៩៦៨ យឿនបានរត់ចូលព្រៃ និងបម្រើការជា «កងការពារសម្ងាត់ប្រចាំនៅមូលដ្ឋានខ្ពប» របស់បដិវត្តន៍។ យឿន បាននិយាយថា ខ្មាំងបានវាយកម្ទេចមូលដ្ឋានបដិវត្តន៍ ដោយបានសម្លាប់ និងចាប់ខ្លួនជនបដិវត្តន៍ស្ទើរតែទាំងអស់។ យឿន និងសមមិត្ត ឈឿន ដែលទទួលបន្ទុកផ្នែកសេដ្ឋកិច្ចស្រុកមេមត់ រងរបួស និងរួចផុតពីការស្លាប់ និងចាប់ខ្លួន។ យឿន និង ឈឿន បានបន្តភ្ជាប់ខ្សែរយៈជាមួយមូលដ្ឋាននៅភូមិញ៉ោរ ឡើងវិញ ដោយមានការទទួលស្គាល់ពីឈ្មោះ ចាន់ និង ម៉ែ ដូរ ដែលជាគណៈស្រុកមេមត់ នៃខេត្តកំពង់ចាម។

នៅចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ យឿន ត្រូវបានចាត់តាំងឱ្យធ្វើការងារជាច្រើនរួមមាន៖ កងការពាររបស់ ម៉ែ ដូរ, អនុប្រធានមន្ទីរស្រុកមេមត់ទទួលផ្នែករោងពុម្ព, លេខាសម្ព័ន្ធយុវកកស្រុកមេមត់, ប្រធាននយោបាយ «ក» នៃយោធាស្រុកមេមត់, បញ្ជាការរួម «ឃ» និងភ័ស្តុភាររបស់សេនាធិការយោធាតំបន់២១, អនុប្រធាននយោបាយឃ-៣១ និងគណៈបញ្ជាការឃ-៥៩។ ចាប់ពីឆ្នាំ១៩៧៥ យឿន ត្រូវបានចាត់តាំងឱ្យធ្វើជាប្រធាននយោបាយឃ-៧៥ និងអនុប្រធាននយោបាយ «ង» នៃតំបន់២១។

យឿន បានឆ្លើយសារភាពថា ម៉ែ ដូរ បានអប់រំ និងបំពាក់បំប៉នខ្លួនឱ្យមានជំហរក្បត់បក្ស តាមរយៈការជំរុញឱ្យមានទឹកចិត្តស្រឡាញ់ភាពសម្បូរបែបហ៊ឺហារុងរឿង និងសេរីនិយមជាមួយស្រីៗជាដើម។ ម៉ែ ដូរ ក៏បានប្រាប់ យឿន ថា៖ «ឯងធ្វើបដិវត្តន៍នឹងគេដែរ ម៉េចក៏នៅតែរហាមអញ្ចឹង? ធ្វើបដិវត្តន៍ កុំខ្វះពេក កុំធ្វើក្រពេក បដិវត្តន៍អ្នកណាគេធ្វើដូចឯងនោះ?»។ ចំណែកឯការប្រើប្រាស់សម្ភារផ្សេងៗវិញ ម៉ែ ដូរ បានណែនាំ យឿន ថា៖ «បើខូច ត្រូវផ្លាស់ភ្លាម កុំធ្វើប៉ុករហាមពេក»។ ដូច្នេះហើយ យឿន ត្រូវបានបំផុសឱ្យកសាងទំនុកចិត្តជាមួយមហាជន និងប្រមែប្រមូលកម្លាំងក្បត់ឱ្យបានច្រើន។ កម្លាំងក្បត់ត្រូវឈរលើសមាសភាពអនុធន នាយទុនអ្នកបច្ចេកទេស ឬអ្នកឆាប់យល់ការងារ។

យឿនបានរាយការណ៍ទៅ ម៉ែ ដូរ ស្តីពីសភាពការណ៍ល្អ និងអាក្រក់នៅក្នុងអង្គភាព និងកិច្ចការផ្សេងៗនៅតាមព្រំដែន ដែលយួនបញ្ជ្រាបគិញចូលមកកម្ពុជា និងបាញ់ប្រោះរាល់ថ្ងៃនៅក្នុងទឹកដីកម្ពុជា។ យឿនក៏បានរៀបរាប់ទៀតថា ប្រជាជនភាគច្រើនថ្នាំងថ្នាក់ជាមួយអង្គការ ទាក់ទងនឹងការខ្វះខាតអាហារ និងការរត់គេចខ្លួនចូលទៅក្នុងប្រទេសវៀតណាម។

បន្ទាប់ពី ម៉ែ ដូរ ត្រូវបានផ្ទេរពីគណៈស្រុកមេមត់ ទៅជាកាន់រោងចក្រចម្ការកៅស៊ូជប់។ ជាជំនួសវិញ យឿន ចាប់ផ្តើមទាក់ទងភ្ជាប់ខ្សែជាមួយ បូរ ដែលជាលេខាស្រុកពាមជីលាំង ចាប់ពីខែកុម្ភៈ ឆ្នាំ១៩៧៧។ តែទោះជាយ៉ាងណាក៏ដោយ យឿន នៅតែបន្តផែនការចាស់ដដែល និងបង្កើនភាពប្រុងប្រយ័ត្នលើសកម្មភាពនានា។ យឿនបានឆ្លើយសារភាពទៀតថា ការប្រជុំលើផែនការក្បត់ជាមួយ «បូរ» បានផ្តោតលើបញ្ហាទំនាស់រវាងកម្មសិទ្ធិឯកជន និងសមូហភាព ព្រមទាំងបញ្ហាមុខមាត់ បុណ្យស័ក្តិ និងតួនាទី។

ក្រៅពីនេះទៀត យឿន បានឆ្លើយសារភាពទាក់ទងនឹងសកម្មភាពជាមួយ ជនជាតិយួន ចំនួនបីដង តាមរយៈប្រូក ចាន់មូល, បឹងប្រូង និងក្រាញ់។ យឿន បាននិយាយថា អ្វីដែលគួរកត់សម្គាល់គឺខ្លឹមសារនៃការពិភាក្សា ដែលភាគីកម្ពុជាស្នើថា៖ «បើសិនណាជាឃើញប្រជាជនកម្ពុជា ដែលរត់ឆ្លងចូលដីវៀតណាម ឱ្យទទួលគ្រប់គ្រង និងជួយលាក់បំពួនផង»។ យឿនបានបញ្ជាក់ថា ភាគីវៀតណាមបានយល់ស្របតាមការស្នើសុំ ហើយយឿន ក៏បានប្រាប់

បន្តស្តីពីតួលេខ និងទីតាំងឈរជើងរបស់កងទ័ពកម្ពុជា ព្រមទាំងអាវុធតូចធំផង។

យឿនបានឆ្លើយសារភាពទាក់ទងនឹងសកម្មភាពរបស់ សាត និង សាន ដែលបើកផ្លូវឱ្យយួនចូលមកស៊ើបការណ៍ពីប្រទេសកម្ពុជា។ សាន ក៏បានទទួលអាវុធធុន «អាអ៊ែរ» ចំនួន៥ដើមពី ឌិន យ៉ាំងសា និងយល់ព្រមឱ្យយួនចូលតាមច្រកទាហោត និងភូមិប្រីដោយសារ សាន បានទទួលខុសត្រូវលើមុខព្រួញនោះ។ យឿនបានឆ្លើយទៀតថា បើករណីបែកការណ៍កម្លាំងទាំង ឡាយត្រូវរត់ចូលក្នុងទឹកដីយួនដែលយួននឹងរង់ចាំទទួល។ ផ្នែកខាងក្រោមបង្អស់នៃចម្លើយសារភាព បញ្ជាក់ថា «បញ្ចប់ការសួរនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៧៧ នៅម៉ោង៦ព្រឹក»។

**កំណត់ចំណាំ៖ អត្ថបទដែលដកស្រង់ចេញពីចម្លើយសារភាពឯកសារ J០០៣១៨ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាង ធ្ងន់ធ្ងរពីកងសួរ ចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ ពេជ្រ យឿន ហៅ ជុំ ដួង បុសី ពិតប៉ុណ្ណាណានោះទេ។**



កងទ័ពបដិវត្តន៍ខ្មែរក្រហមនៅភូមិភាគបូព៌ា ដែលរត់គេចខ្លួនពីការតាមចាប់របស់មជ្ឈិមបក្សលាក់ខ្លួននៅក្នុងចម្ការកៅស៊ូក្នុងខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# លីម ស៊ុន ៖ អតីតទាហានឡាវ បម្រើការជាភ្នាក់ងារយួននៅក្នុងរបបខ្មែរក្រហម

លី សុខឃាង



កិច្ចប្រជុំរណសិរ្សរួបរួម ឡាវ-កម្ពុជា-វៀតណាម នៅឆ្នាំ១៩៥០។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចម្លើយសារភាពរបស់ លីម ស៊ុន ឬ បាក់ លីម បានបង្ហាញឱ្យឃើញពីប្រវត្តិសកម្មភាព និងផែនការរបស់វៀតណាមនៅក្នុងប្រទេស ឡាវ និងកម្ពុជា នៅមុនពេល និងក្នុងអំឡុងនៃរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។ លីម ស៊ុនបានរៀបរាប់អំពីការក្តាប់ស្ថានការណ៍កងទ័ព ការគ្រប់គ្រងនៅតាមទីក្រុង និងជនបទរបស់ខ្មែរក្រហម ព្រមទាំងជីហរមហាជននៅក្នុងប្រទេសទាំងពីរ ដើម្បីរាយការណ៍ជូន ង្វៀង ធីបេ ដែលមានឋានៈជាស័ក្តិ៤ របស់វៀតណាម ប្រចាំនៅភាគខាងត្បូងប្រទេស ឡាវ។ លីម ស៊ុន ត្រូវបានចាត់តាំងឱ្យជ្រៀតចូលកម្ពុជាពីប្រទេស ឡាវ នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨។ ស៊ុន ត្រូវបានចាប់ខ្លួនក្នុងរយៈពេលបីថ្ងៃក្រោយមក ដោយត្រូវទទួលរងនូវការសួរចម្លើយ ដោយ អឿន, ខឿន និង ខុន ដែលមានហត្ថលេខារបស់អ្នកសួរចម្លើយ និងកាលបរិច្ឆេទថ្ងៃទី៩ ខែមករា ឆ្នាំ១៩៧៨។

### ក. ប្រវត្តិរបស់ លីម ស៊ុន

ចម្លើយសារភាពរបស់ លីម ស៊ុន បញ្ជាក់ថា ស៊ុន មានស្រុកកំណើតនៅក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម និងរៀបរាប់អំពីការសិក្សារៀនសូត្រនៅចន្លោះឆ្នាំ១៩៥៥ ដល់ ឆ្នាំ១៩៥៩។ ស៊ុន ធ្លាប់បានរៀនសូត្រនៅសាលាកម្ពុជបុត្រ ដែលជាសាលាឈ្មួលនៅក្នុងទីក្រុងភ្នំពេញ។ ស៊ុន បានចាប់ផ្តើមប្រកបរបររកស៊ីវិញ បន្ទាប់ពីខ្លួនប្រឡងធ្លាក់ឌីប្លូម។

នៅក្នុងឆ្នាំ១៩៦២ ស៊ុន និងមិត្តភក្តិរបស់ខ្លួនចំនួនបីនាក់ឈ្មោះ ចាន់ថន, សារ៉ាន់ និង ដេង ប៉ាន

ធ្វើដំណើរចូលក្នុងប្រទេស ឡាវ។ ប៉ូលីស ឡាវ បាន ឃាត់ខ្លួនទុកនៅក្នុងប្រទេស ឡាវ និងអនុញ្ញាតឱ្យ ផេង តែម្នាក់គត់ត្រឡប់មកកម្ពុជាវិញ។ មួយឆ្នាំ ក្រោយមក ស៊ិន បានចូលបម្រើក្នុងជួរកងទ័ព ឡាវ នៅក្នុងខេត្តប៉ាកសេ។ នៅក្នុងឆ្នាំ១៩៦៥ ស៊ិន បាន ចាប់ផ្តើមការងារជាគ្រូបង្រៀនភាសាបារាំងនៅ ក្នុងសាលាឯកជន ឡាវថាវិន នៅទីក្រុងប៉ាកសេ។ នៅចន្លោះឆ្នាំ១៩៧០ និង ១៩៧២ ស៊ិន មាន ទំនាក់ទំនងការងារផ្សេងៗជាមួយជនជាតិបារាំង ចំនួនពីរនាក់គឺ៖ ឌុយ ប៉ុយដា និង ហង់រី ហ្វាម៉ង់។

ហង់រី ហ្វាម៉ង់បានបញ្ចូល ស៊ិន ឱ្យធ្វើជាភ្នាក់ងារ ហ្វ្រង់ហ្វេស នៅក្នុងខែសីហា ឆ្នាំ១៩៧៦។ នៅចុង ឆ្នាំដដែល ហង់រី ហ្វាម៉ង់ ក៏បានណែនាំ ស៊ិនឱ្យស្គាល់ ស័ក្តិ៤ ង្វៀង ធីបេ ដែលជាមេបញ្ជាការកងទ័ពយួន ប្រចាំនៅភាគខាងត្បូងប្រទេស ឡាវ។ ង្វៀង ធីបេ ក៏បានចាត់តាំង ស៊ិន ឱ្យតាមដានពិនិត្យ និងរាយ ការណ៍ថាតើប្រជាជន ឡាវចូលចិត្តវៀតណាមឬទេ ហើយថាតើមានបក្សណាខ្លះប្រឆាំងនឹងវៀតណាម។ បន្ទាប់មក ហង់រី ហ្វាម៉ង់ ក៏បានចាត់តាំងនិងបញ្ជូន ស៊ិនឱ្យជ្រៀតចូលកម្ពុជា តាមការណែនាំរបស់ ង្វៀង ធីបេ នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨។

## ខ. ការជ្រៀតចូលកម្ពុជានៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨

នៅក្នុងប្រទេសកម្ពុជា ស៊ិន ទទួលភារកិច្ច ស៊ើបការណ៍អំពីបញ្ហាសំខាន់ចំនួនបី។ ទីមួយ) ស៊ិនត្រូវ ស៊ើបការណ៍អំពីប្រជាជនវៀតណាមដែលនៅ សេសសល់នៅក្នុងប្រទេសកម្ពុជា។ ទីពីរ) ស៊ិន ត្រូវ ស៊ើបការណ៍អំពីចំនួនកងពលរបស់ខ្មែរក្រហមរបៀប នៃការដាក់ពង្រាយកងទ័ពនៅតាមព្រំដែន និងចំណុច ឈរជើងរបស់កងទ័ព ព្រមទាំងទីតាំងកាំភ្លើងធំ និងរថក្រោះដងៗ ទីបី) ស៊ិន ត្រូវស្វែងរកនិងភ្ជាប់ ទំនាក់ទំនងជាមួយខ្សែបណ្តាញចំនួនបួននាក់ទៀត រួមមាន៖ សុក ដែលធ្លាប់ជាគ្រូបង្រៀននៅឃុំជើង កើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល, ហេង និង វ៉េង ដែលជាអ្នកលក់ដូរ និងរស់នៅភូមិឃុំជាមួយ សុក ដែរ, និង កែវ ខាំ ដែលជាជនជាតិ ឡាវនៅទីរួមខេត្ត ស្ទឹងត្រែង ដើម្បីស៊ើបការណ៍ពីរបៀបនៃការគ្រប់គ្រង របស់ខ្មែរក្រហមនៅតាមទីក្រុង និងជនបទ ព្រមទាំង ឃោសនាបំបែកបំបាក់ប្រជាជនពីបដិវត្តន៍ និងកម្ទេច កម្មាភិបាលនៅតាមភូមិឃុំ។

## គ. ផែនការយួនក្នុងការវាយកាន់កាប់ខេត្តស្ទឹងត្រែង នៅដើមឆ្នាំ១៩៧៨

ស៊ិន បានរៀបរាប់ថា ខណៈដែលមេបញ្ជាការ កងទ័ពយួន ត្រាន់ វ៉ាន់ទៀង បានដឹកនាំនិងដាក់ ពង្រាយកងទ័ពយួនចំនួន១ម៉ឺននាក់នៅទល់មុខខេត្ត ស្ទឹងត្រែង ង្វៀង ធីបេ ក៏បានប្រើប្រាស់កម្លាំងទ័ព យួនចំនួន៥ពាន់នាក់ ដើម្បីបើកការវាយឆ្មក់។ កងទ័ពយួនមានសព្វាវុធជាច្រើនដូចជារថក្រោះ ចំនួន៤០គ្រឿង កាំភ្លើងធំចំនួន៣០ដើម កាំភ្លើងធុន ១០៥ ចំនួន១០ដើម កាំភ្លើងធុន ១០៨ ចំនួន ២០ ដើម និងយន្តហោះ២០៦គ្រឿង ដែលទទួលពី សូវៀត។ ការវាយឆ្មក់ត្រូវបានគាំទ្រដោយរថក្រោះ និងកាំភ្លើង ១០៥ ដែលដាក់ពង្រាយពីខេត្តអាត់តាពើ រហូតដល់ខេត្តស្ទឹងត្រែង។ យួនមានបំណងវាយយក ខេត្តស្ទឹងត្រែងឱ្យបាននៅត្រឹមខែកុម្ភៈ ឬខែមីនា ឆ្នាំ១៩៧៨។

ផ្នែកចុងក្រោយនៃចម្លើយសារភាពរបស់ ស៊ិន បានរៀបរាប់អំពីចំនួនកងទ័ពយួនចំនួន៦ម៉ឺននាក់ នៅក្នុងប្រទេស ឡាវ។ ភាគច្រើននៃមូលដ្ឋានកងទ័ព យួនគឺនៅក្នុងព្រៃ ហើយកងទ័ពយួនជួយការពារ ឡាវ នៅតាមព្រំដែនខ្មែរ ឡាវ ចាប់ពីខេត្តសញ្ញៈបូរី រហូតដល់ខេត្តអាត់តាពើ និងខេត្តសារ៉ាវ៉ាន់។ ស៊ិន ត្រូវ បានចាប់ខ្លួន និងសួរចម្លើយនៅថ្ងៃទី៩ ខែមករា ឆ្នាំ១៩៧៨ ដោយមានហត្ថលេខា និងឈ្មោះអ្នក សួរចម្លើយ អឿន, ខឿន និង ខុន។

***កំណត់ចំណាំ៖ អត្ថបទដែលដកស្រង់ចេញពី ចម្លើយសារភាពឯកសារ J០០១៨៥ រាល់ចម្លើយ សារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខ ស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និង ធ្វើ ទារុណកម្មយ៉ាង ធ្ងន់ធ្ងរពីកងសួរ ចម្លើយរបស់ ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ លីម ស៊ិន ឬ បាក់ លីម ពិត ប៉ុយ៉ាងណានោះទេ។***

# អ្នកស្រាវជ្រាវវ័យក្មេងជ្រើសរើសទីតាំង អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ដើម្បីសិក្សាស្រាវជ្រាវស្តីពី «បញ្ហាប្រឈមដែលបណ្តាលឱ្យសិស្សបោះបង់ការសិក្សាក្នុងមូលដ្ឋាន»

ស្រេង លីជា



អ្នកស្រាវជ្រាវវ័យក្មេងមកកាន់អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ដើម្បីពិភាក្សា និងសិក្សាស្រាវជ្រាវស្តីពី «បញ្ហាប្រឈមដែលបណ្តាលឱ្យសិស្សបោះបង់ការសិក្សាក្នុងមូលដ្ឋាន»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីទទួលបានវគ្គបណ្តុះបណ្តាលស្តីពី «យេនឌ័រ និងភាពជាអ្នកដឹកនាំរបស់ស្ត្រី» រៀបចំដោយអង្គការនារីដើម្បីសន្តិភាព សាខាខេត្តស្ទឹងត្រែង នាពេលកន្លងមក, អ្នកស្រាវជ្រាវវ័យក្មេង ដែលជាសិស្សនៃវិទ្យាល័យបុរីអូរស្វាយ-សែនជ័យ សម្រេចជ្រើសរើសអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៃព្រះរាជបណ្ណាល័យ ហ្វូងម៉ែ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ជាទីកន្លែងសិក្សាស្រាវជ្រាវ និងពិភាក្សាទៅលើប្រធានបទ៖ «បញ្ហាប្រឈមដែលបណ្តាលឱ្យសិស្សមានការបោះបង់ការសិក្សា» នៅស្រុកបុរីអូរស្វាយ-សែនជ័យ ខេត្តស្ទឹងត្រែង។ កិច្ចការងារស្រាវជ្រាវខាងលើ គឺដឹកនាំដោយលោក ហឿយ ហាង បុគ្គលិកសម្របសម្រួលនៃអង្គការនារីដើម្បីសន្តិភាព សាខាខេត្តស្ទឹងត្រែង ដើម្បីផ្តល់ឱកាសដល់អ្នកស្រាវជ្រាវវ័យក្មេង ស្វែងយល់អំពីបញ្ហាប្រឈម និងចូលរួម



អ្នកស្រាវជ្រាវវ័យក្មេងមកកាន់អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ- សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ដើម្បីពិភាក្សា និងសិក្សាស្រាវជ្រាវស្តីពី «បញ្ហាប្រឈមដែលបណ្តាលឱ្យសិស្សបោះបង់ការសិក្សាក្នុងមូលដ្ឋាន»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្វែងរកដំណោះស្រាយទៅលើកត្តាដែលសិស្សានុសិស្សសម្រេចចិត្តបោះបង់ការសិក្សា។

ជាកិច្ចស្វាគមន៍លោក ស្រេង លីដា បុគ្គលិកប្រចាំការនៃមជ្ឈមណ្ឌលឯកសារខេត្តស្ទឹងត្រែង បានទទួលស្វាគមន៍អ្នកស្រាវជ្រាវវ័យក្មេង ព្រមទាំងធ្វើបទបង្ហាញអំពីវត្ថុបំណង, សកម្មភាព និងបេសកកម្មនាពេលអនាគតនៃទីតាំងអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ- សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)។ លោក ស្រេង លីដា លើកឡើងថា អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ- សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) មិនត្រឹមតែជាមជ្ឈមណ្ឌលស្រាវជ្រាវ ផ្សព្វផ្សាយអំពីប្រវត្តិសាស្ត្រ និងវប្បធម៌នោះទេ ប៉ុន្តែថែមទាំងជាមជ្ឈមណ្ឌលសហគមន៍ បុស្សាលសហគមន៍ ដែលអាចឱ្យសិស្សានុសិស្ស, លោកគ្រូ អ្នកគ្រូ, ប្រជាពលរដ្ឋរស់នៅតាមបណ្តាកោះ អ្នកសិក្សាស្រាវជ្រាវជាតិ និងអន្តរជាតិ ប្រើប្រាស់ទៀតផង។ បន្ទាប់មក អ្នកស្រាវជ្រាវវ័យក្មេងបានធ្វើដំណើរទៅកាន់បន្ទប់បណ្ណាល័យដែលតម្កល់ទុកសៀវភៅដ៏សម្បូរបែប និងមានមាតិកាជាច្រើនទាក់ទងប្រធានបទស្រាវជ្រាវនេះ។



លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តស្ទឹងត្រែង បានលើកឡើងថា៖ «ទីតាំងអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ- សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ពិតជាផ្តល់ភាពងាយស្រួលក្នុងកិច្ចការស្រាវជ្រាវរបស់អ្នកស្រាវជ្រាវវ័យក្មេង។ អ្នកស្រាវជ្រាវអាចប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវរួមមាន៖ ការអានឯកសារដើម និងឯកសារបន្ទាប់បន្សំ

នៅក្នុងបណ្ណាល័យ ឬការធ្វើការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធើណែត ដែលយើងបានបំពាក់សេវាអ៊ីនធើណែតល្បឿនលឿនសម្រាប់អ្នកស្រាវជ្រាវទាំងអស់ដែលមកកាន់ទីនេះ។ បន្ថែមទៅលើការស្រាវជ្រាវដោយការអានឯកសារ ឬសៀវភៅ និងតាមប្រព័ន្ធអ៊ីនធើណែត, អ្នកស្រាវជ្រាវវ័យក្មេង គួរតែពិនិត្យមើលទៅលើភូមិសាស្ត្រ នៃស្រុកបុរីអូរស្វាយ-សែនជ័យ ដែលមានកោះជាច្រើន និងហ៊ុមព័ទ្ធទៅដោយ ទន្លេមេគង្គ។ មួយវិញទៀត អ្នកស្រាវជ្រាវអាចចុះអនុវត្តការស្រាវជ្រាវនៅមូលដ្ឋានផ្ទាល់ ដើម្បីជួបជាមួយសិស្ស និងឪពុកម្ដាយតាមផ្ទះ ដើម្បីស្វែងយល់អំពីស្ថានភាព និងបញ្ហាប្រឈមដែល ទាំងឪពុកម្ដាយ និងសិស្ស កំពុងតែជួបប្រទះ»។

កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជា បានសហការជាមួយរដ្ឋបាលស្រុកបុរីអូរស្វាយ-សែនជ័យ ក្នុងការរៀបចំទូកចម្លងសហគមន៍ និងផែរង់ចាំសរុបចំនួន៤ ដើម្បីសម្រួលដល់ការធ្វើដំណើរតាមផ្លូវទឹកដោយមិនគិតកម្រៃសម្រាប់សិស្ស និងអ្នកភូមិរស់នៅតាមកោះនៅក្នុងស្រុកបុរីអូរស្វាយសែនជ័យ។ ចំណុចនេះគឺជាការរួមចំណែកមួយដើម្បីសម្រួលដល់ជីវភាពប្រជាជនក្នុងសហគមន៍ សម្រួលដល់ការធ្វើដំណើររបស់សិស្សានុសិស្សដើម្បីស្វែងរកការអប់រំ និងសេវាសង្គម ជាពិសេសសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ សិស្សមួយចំនួនដែលរស់នៅកោះញ្ញោ កំពុងជួបបញ្ហាគ្មានលទ្ធភាពធ្វើទូកឆ្លងដើម្បីមករៀននៅវិទ្យាល័យបុរីអូរស្វាយសែនជ័យ។ ការដាក់ដំណើរការទូកចម្លងសហគមន៍ដោយមិនគិតកម្រៃនេះ មិនត្រឹមតែជួយសម្រួលដល់ការធ្វើដំណើរតាមផ្លូវទឹកប៉ុណ្ណោះទេ ប៉ុន្តែក៏លើកទឹកចិត្តដល់សិស្សទាំងអស់នៅកោះញ្ញោឱ្យបន្តការសិក្សាថែមទៀតផង។

បន្ទាប់ពីទទួលបានការណែនាំ, ការអានឯកសារ និងសៀវភៅ និងការប្រើប្រាស់ប្រព័ន្ធអ៊ីនធើណែតសម្រាប់ស្រាវជ្រាវ, អ្នកស្រាវជ្រាវវ័យក្មេង ទទួលបានការយល់ដឹងបឋមអំពីកត្តារួមចំណែកដែលបណ្ដាលឱ្យមានការបោះបង់ការសិក្សានៅមូលដ្ឋាន រួមមាន៖ បញ្ហាទឹកជំនន់, កង្វះខាតមធ្យោបាយធ្វើដំណើរតាមផ្លូវទឹកសម្រាប់សិស្សដែលរស់នៅតាមកោះ, កម្រិតជីវភាពរស់នៅ និងបញ្ហាប្រឈមផ្សេងៗនៅក្នុងសហគមន៍ទៀត។



អ្នកស្រាវជ្រាវវ័យក្មេងមកកាន់អគារមរតកសង្គមរាស្ត្រនិយម សម្ដេចឪ-សម្ដេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ដើម្បីពិភាក្សា និងសិក្សាស្រាវជ្រាវស្ដីពី «បញ្ហាប្រឈមដែលបណ្ដាលឱ្យសិស្សបោះបង់ការសិក្សាក្នុងមូលដ្ឋាន»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ពេលវេលាកាន់តែខើចដើម្បីជួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលកាន់តែចាស់ទ្រុឌទ្រោម

សោម ប៊ុនថន







អ្នកស្ម័គ្រចិត្តកម្ពុជាប្រចាំនៅខេត្តស្វាយរៀង ចុះជួបសួរសុខទុក្ខ និងសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរនៅតាមភូមិឃុំដែលខ្លួនរស់នៅ នៅឆ្នាំ២០២១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា បានចេញសេចក្ដីអំពាវនាវឱ្យមានការខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការចងក្រងឯកសារប្រវត្តិសាស្ត្រផ្ទាល់មាត់ និងធ្វើឱ្យស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានប្រសើរឡើង ដោយលើកឡើងថា ពេលវេលាកាន់តែខើច ខណៈចំនួនប្រជាជនដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមកាន់តែចាស់ទ្រុឌទ្រោម និងមានអ្នកស្លាប់ជាបន្តបន្ទាប់។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានលើកឡើងថា ទោះបីជាយុត្តិធម៌សម្រាប់ជនរងគ្រោះក្នុងរបបខ្មែរក្រហម មិនអាចសម្រេចបានពេញលេញតាមការចង់បានរបស់ប្រជាជនទាំងអស់យ៉ាងណាក៏ដោយ ប៉ុន្តែវាចាំបាច់ណាស់ក្នុងការថែរក្សារឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងការថែរក្សាសុខភាពរបស់គាត់ឱ្យប្រសើរឡើងសម្រាប់ការផ្សះផ្សាជាតិ ការទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រ និងការអភិវឌ្ឍន៍ប្រទេសនាពេលអនាគត។

លោក ឆាំង យុ បានបន្តថា «អំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលបានបំផ្លាញភាពជាមនុស្សជាតិរបស់ប្រជាជនកម្ពុជា»។ មជ្ឈមណ្ឌលឯកសារកម្ពុជាចង់ស្តារភាពជាមនុស្សជាតិរបស់ប្រជាជនកម្ពុជាទាំងអស់ មិនត្រឹមតែជនរងគ្រោះប៉ុណ្ណោះទេ ថែមទាំងអ្នកដែលធ្លាប់ប្រព្រឹត្តអំពើឃោរឃៅថែមទៀតផង»។

ចាប់តាំងពីឆ្នាំ២០១៧មក មជ្ឈមណ្ឌលឯកសារកម្ពុជាបានពង្រីកការងាររបស់ខ្លួនលើសពីការចងក្រងឯកសារប្រវត្តិសាស្ត្រផ្ទាល់មាត់ ដើម្បីរួមបញ្ចូលការងារផ្នែកសុខភាពដែលជាគោលដៅចម្បងដើម្បីលើកកម្ពស់ស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឱ្យបានប្រសើរឡើង ជាពិសេសអ្នកដែលរស់នៅតាមសហគមន៍ដាច់ស្រយាល។ កិច្ចខិតខំប្រឹងប្រែងទាំងនេះរួមមានការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាសុខភាពសាធារណៈ និងការកែលម្អលទ្ធភាពទទួលបានការថែទាំផ្នែកវេជ្ជសាស្ត្រជាមូលដ្ឋាន។ ការស្រាវជ្រាវក៏ត្រូវបានធ្វើឡើងដើម្បីវាយតម្លៃស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងតំបន់ដែលជារឿយៗស្ថិតនៅក្រៅពីលទ្ធភាពនៃការផ្តួចផ្តើមឱ្យមានការអភិវឌ្ឍន៍។

នៅឆ្នាំ២០២០ មជ្ឈមណ្ឌលឯកសារកម្ពុជាបានជ្រើសរើស «អ្នកស្ម័គ្រចិត្តកម្ពុជា» ឬហៅកាត់ជាភាសាអង់គ្លេសថា «CamboCorps» ដើម្បីចុះទៅសួរនាំអំពីសុខភាព និងរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៩០,០០០នាក់ ដែលរស់នៅតាមតំបន់ដាច់ស្រយាល ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ជាពិសេសអំឡុងពេល និងក្រោយពេលរាតត្បាតនៃជំងឺកូវីដ-១៩។ កម្មវិធីសុខភាពនិងប្រវត្តិសាស្ត្រនេះបានរកឃើញជំងឺទូទៅមួយចំនួន ដែលតែងតែកើតឡើងចំពោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម មានដូចជា៖ ជំងឺលើសឈាម ជំងឺបេះដូង ជំងឺទឹកនោមផ្អែម ជំងឺសួតរ៉ាំរ៉ៃ ជំងឺរបេង និងមហារីកសុដន់។

ជាច្រើនឆ្នាំក្រោយមក នៅពេលដែលក្រុមការងារត្រឡប់ទៅសួរសុខទុក្ខអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងនោះវិញ គឺភាគច្រើនគាត់លែងនៅជាមួយយើងទៀតហើយ។ «នេះមិនមែនជាការប្រមាថជីវិតនោះទេ ប៉ុន្តែជាក្តីបារម្ភសម្រាប់ជាតិ ដែលថាមនុស្សជំនាន់ក្រោយនឹងលែងមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីប្រាប់ដោយផ្ទាល់អំពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា»។

លោក ឆាំង យុ បានសង្កត់ធ្ងន់លើភាពបន្ទាន់នៃការថែរក្សារឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម មិនត្រឹមតែសម្រាប់គោលបំណងទុកជាឯកសារតែប៉ុណ្ណោះទេ ប៉ុន្តែវាគឺជាទម្រង់នៃយុត្តិធម៌ និងការផ្សះផ្សាជាតិ។ លោក ឆាំង យុ បានបន្តថា «យើងជឿជាក់ថា យើងកំពុងបន្តការងារយុត្តិធម៌សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទោះបីជាយើងបានដឹងតាំងពីដំបូងថា សោកនាដកម្ម និងភាពអយុត្តិធម៌ដែលប្រជាជនកម្ពុជាទទួលរងក្នុងរបបខ្មែរក្រហមគឺធំធេង ដែលគ្មានអ្វីអាចជំនួស ឬផ្តល់សំណងដល់គាត់បានឡើយ»។ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាជំហានដ៏សំខាន់មួយឆ្ពោះទៅមុខក្នុងការជួយ និងគាំទ្រដល់អ្នករស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍»។ ការបាត់បង់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម មានអត្ថន័យជ្រាលជ្រៅសម្រាប់មនុស្សជំនាន់ក្រោយ ដែលអាចធំឡើងដោយមិនដឹងថាមានការកាប់សម្លាប់ដែលបានកើតឡើងនៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នៅពេលដែលប្រជាជនកម្ពុជាជិត២លាននាក់បានបាត់បង់ជីវិតក្រោមរបបឃោរឃៅខ្មែរក្រហម។

លោក ឆាំង យុ បានលើកឡើងថា «នៅក្នុងប្រទេសកម្ពុជាមានអ្នករស់នៅឆ្លងកាត់របបខ្មែរក្រហម និងអ្នកដែលកើតក្រោយទសវត្សរ៍ឆ្នាំ១៩៩០»។ «យុវជនដែលកើតក្រោយអតីតកាលដ៏លំបាករបស់កម្ពុជាតែងតែមានគំនិតបើកចំហ ជឿជាក់ និងសុទិដ្ឋិនិយមចំពោះអនាគត និងការទំនាក់ទំនងជាមួយពិភពលោក ជាងមនុស្សជំនាន់មុន ដែលនៅតែដិតដាមជាមួយអតីតកាល»។

លោក ឆាំង យុ បានមើលឃើញពីក្តីសង្ឃឹម និងទំនួលខុសត្រូវរបស់យុវជនជំនាន់ក្រោយ។ «ពេលវេលាដើម្បីដឹកនាំរបស់យុវជនជំនាន់ក្រោយគឺឥឡូវនេះ ហើយវាជាបន្ទុកសម្រាប់មនុស្សជំនាន់មុនក្នុងការបង្ហាត់បង្រៀន និងរំឭកយុវជនជំនាន់ក្រោយ អំពីអតីតកាលដែលលំបាកលំបិន»។ «ប៉ុន្តែក៏ផ្តល់ឱ្យយុវជនទាំងនេះនូវភាពក្លាហាន ដែលជាអនាគតពិតប្រាកដដែលយុវជនជំនាន់ក្រោយស្រមៃទៅដល់ ដើម្បីសម្រេចបំណងផ្ទាល់ខ្លួន»។

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៥ និងបានខិតខំប្រឹងប្រែងដើម្បីចងក្រងឯកសារអំពីសម័យខ្មែរក្រហម ដោយបានផ្តល់នូវភស្តុតាងសំខាន់ៗជាច្រើនលើសលុបសម្រាប់ប្រើប្រាស់ក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងការលើកកម្ពស់ការអប់រំ និងការផ្សះផ្សាជាតិ។













អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តស្វាយរៀង នៅឆ្នាំ២០២១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឆាកជីវិតប្រពន្ធនិងកូនរបស់មេក្រុម សហករណ៍ទួលព្រាំ

**ស្រ៊ាង លីហួរ**

តាមរយៈប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង ដែលធ្វើឡើងនៅឆ្នាំ១៩៧៨ ញៀប ផុំ ភេទប្រុស អាយុ៣៦ឆ្នាំជាជនជាតិខ្មែរមានកម្ពស់១.៥៧ម៉ែត្រ។ ផុំ មានតួនាទីមុនរបបខ្មែរក្រហមជាប្រជាជនចាស់ នៅភូមិវាលស្រីស្រណោះ និងជាមេក្រុមសហករណ៍ ទួលព្រាំ តំបន់៤ ក្នុងរបបខ្មែរក្រហម។ ផុំ កើតនៅភូមិទួលព្រាំ ឃុំទួលព្រាំ ស្រុកមោងឫស្សី តំបន់បាត់ដំបង។ គាត់មានឪពុកឈ្មោះ ថ្វាង ញៀប និងម្តាយឈ្មោះ អោ ភឹម ជាកសិករនៅទួលព្រាំ។ គាត់មានប្រពន្ធឈ្មោះ ម៉ិល ហ៊ាង មានស្រុកកំណើតនៅភូមិតាពៅ ស្រុកគីរីវង់ ខេត្តតាកែវ។ ក្នុងរបបខ្មែរក្រហម ប្រពន្ធផុំ រស់នៅសហករណ៍កាច់រទេះ តំបន់៤ និងមានកូនបីនាក់ ក្នុងនោះស្រីពីរនាក់។ ផុំ ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅភូមិភាគពាយ័ព្យ នាថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៧៨។

នៅឆ្នាំ២០០៦ បន្ទាប់ពីអានប្រវត្តិរូបអ្នកទោស ដែលបន្សល់ទុកនៅមន្ទីរសន្តិសុខស-២១ អ្នកស្រាវជ្រាវពីមជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះសាកសួរទាក់ទងនឹងប្រវត្តិរបស់ ញៀប ផុំ តាមរយៈការសម្ភាសន៍ជាមួយប្រពន្ធឈ្មោះ ម៉ិល ហ៊ាង អាយុ៦៧ឆ្នាំ។ ប្រពន្ធ ផុំ រស់នៅភូមិទួលព្រាំ ឃុំកកោះ ស្រុកមោងឫស្សី ខេត្តបាត់ដំបង និងមានទីកន្លែងកំណើតនៅភូមិអាងខ្មៅ ឃុំកំពែង ស្រុកគីរីវង់ ខេត្តតាកែវ។ ប្រពន្ធផុំ មានឪពុកឈ្មោះ ម៉ិល, ម្តាយឈ្មោះ ហឿង និងមានកូនបីនាក់ ឈ្មោះ ណៃ (ប្រុស), សុខា និងសុខខៃ។




ប្រវត្តិរូបរបស់ ញៀប ផុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ផុំ ជាកូនកសិករ មានបងប្អូនប្រាំនាក់ ក្នុងនោះស្រីពីរនាក់ ឈ្មោះ លឿម, ងួន, ទឿន, ផុំ និងផិន។ កាលពីកុមារភាព ផុំ បានជួយធ្វើស្រែឪពុកម្តាយ, នេសាទ, ឃ្វាលគោ និងបួសអស់រយៈពេលបីវស្សានៅវត្តទួលព្រាំ។ បន្ទាប់ពីសឹក ផុំ បានទៅធ្វើការស៊ីឈ្នួលបើកត្រាក់ទ័រ អស់រយៈពេលពីរឆ្នាំ។ នៅទីនេះ ផុំ បានជួប ហ៊ាង ដែលជាអ្នកធ្វើការជាមួយ

និងរៀបការក្រោមការផ្សំផ្គុំរបស់ចៅកែម្ចាស់ផ្ទះ។ ពីរឆ្នាំក្រោយមក ផុាំ និងប្រពន្ធបាននាំកូនអាយុ១ឆ្នាំ ត្រឡប់មករស់នៅជាមួយឪពុកម្តាយក្នុងភូមិ ដោយប្រកបរបរធ្វើស្រែចម្ការ, លក់នំបញ្ចុក និងធ្វើកន្ទេល រហូតមានលទ្ធភាពសាងសង់ផ្ទះផ្ទាល់ខ្លួន។

នៅឆ្នាំ១៩៧០ បន្ទាប់ពីមានរដ្ឋប្រហារនៅទីក្រុងភ្នំពេញ ក៏ស្រាប់តែមានការទម្លាក់គ្រាប់បែកក្នុងភូមិកើតឡើង។ ក្រោយមកដោយភាពភ័យខ្លាច ផុាំ និងប្រពន្ធ ត្រូវរស់នៅតាមលេណដ្ឋាន និងបានគេចខ្លួនទៅរស់នៅព្រៃនាម ជិតបឹងទន្លេសាប ដែលគ្រប់គ្រងដោយចលនាខ្មែរក្រហម។ នៅព្រៃនាម ផុាំ ត្រូវទៅធ្វើស្រែប្រវាស់ដៃនៅវាលស្រីស្រណោះ ចំណែកប្រពន្ធត្រូវអង្គការចាត់តាំងឱ្យបុកស្រូវ។ នៅឆ្នាំ១៩៧៣ ខ្មែរក្រហមជ្រើសរើស ផុាំ ធ្វើជាយោធា និងបញ្ជូនទៅធ្វើប្រយុទ្ធជាមួយ ទាហាន លន់ នល់។ ចំណែក ប្រពន្ធនិងកូនត្រូវបញ្ជូនទៅរស់នៅសហករណ៍កាច់រទេះ។

ក្រោយពីខ្មែរក្រហមបានឡើងកាន់អំណាចជាផ្លូវការនៅឆ្នាំ១៩៧៥ ផុាំ បានត្រឡប់មកធ្វើជាមេក្រុមសហករណ៍ទួលព្រាំ ដោយមានភារកិច្ចដឹកនាំប្រជាជនធ្វើស្រែ, ធ្វើនង្គ័ល និងដឹកជញ្ជូនសម្ភារ ដូចជាធ្យូង, ខស និងអង្ក្រាម។ ចំណែកប្រពន្ធ ផុាំ ត្រូវឡើងធ្វើជាប្រធានក្រុមតម្បាញ ដោយដឹកនាំប្រជាជនមូលដ្ឋានដែលមានអាយុចន្លោះពី២០ដល់៣០ឆ្នាំ រវៃអំបោះ, ត្បាញក្រមា, ស្បៃ និងសំពត់ស។ ផុាំ និងប្រពន្ធកូន ត្រូវរស់នៅតាមកន្លែងការងាររៀងៗខ្លួន។ នៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានរកឃើញថា បងរបស់ ផុាំ ឈ្មោះ លឿម ដែលជាប្រជាជន១៧មេសា ធ្លាប់ធ្វើជាទាហាន លន់ នល់ នៅឃុំកកោះ។ នៅម៉ោង៨យប់ លឿម ត្រូវបានខ្មែរក្រហមនាំខ្លួនយកទៅ ក្រោយពីធ្វើអត្តឃាតដោយលេបគ្រាប់ស្នែងមិនបានសម្រេច។

ប្រពន្ធផុាំ និយាយថា នៅសហករណ៍កាច់រទេះ ប្រជាជនមូលដ្ឋាន និងប្រជាជន១៧មេសា ដែលខ្មែរក្រហមជម្លៀសពីក្រុងភ្នំពេញ និងបាត់ដំបង ត្រូវរស់នៅដាច់ដោយឡែកៗ ប្រជាជនមូលដ្ឋាន ទទួលបានបាយពីរវែក ចំណែកប្រជាជន១៧មេសា បានបាយមួយវែកប៉ុណ្ណោះ។ ប្រជាជន១៧មេសាត្រូវខ្មែរក្រហមតាមដាន និងលត់ដំ ហើយខ្មែរក្រហមចាប់ខ្លួន និងដឹកប្រជាជន១៧មេសាតាមរទេះគោយកទៅខ្នងភ្នំដោយមិនឃើញត្រឡប់មកវិញនោះទេ។

កូនផុាំ ដែលធ្វើការក្នុងកងកុមារ បាននិយាយថា នៅវេលាម៉ោង៤ល្ងាច ខ្មែរក្រហម បានចាប់ប្រជាជនបណ្តើរជាជួរ ដើម្បីឱ្យទៅជីករណ្តៅ នៅ សាលាស្តៅ ឃុំកំពង់ព្រាង ស្រុកសង្កែ ខេត្តបាត់ដំបង។ កូនផុាំ បន្តថា ក្នុងមួយរណ្តៅ គឺមានសាកសពពី៤០ ទៅ៥០នាក់។ ចំណែកកូនក្មេង ត្រូវខ្មែរក្រហមចាប់បោះឡើង និងចាក់ចំពុះទុងកាំភ្លើងពីក្រោម។

នៅឆ្នាំ១៩៧៧ ការហូបចុកនៅសហករណ៍ត្រូវប្តូរពីបាយមកជាបបររាវៗលាយជាមួយត្រកួន ដំឡូង និងមាន់ទាចិញ្ចឹមជុំវិញផ្ទះ គឺត្រូវប្រមូលទុកជាសមូហភាពទាំងអស់។ ប្រពន្ធផុាំ បន្តទៀតថា ស្រូវទាំងជង្រុកត្រូវដឹកចេញគ្មានសល់ បណ្តាលឱ្យបងប្រុសផុាំម្នាក់ទៀត ឈ្មោះ ផួន រួមទាំងបងប្អូនប្រពន្ធផុាំស្លាប់ដោយសារហូបចុកមិនគ្រប់គ្រាន់។

នៅឆ្នាំ១៩៧៨ នាម៉ោង៩ព្រឹក ខ្មែរក្រហមបានមកប្រាប់ ផុាំ និងប្រពន្ធកូនឱ្យរៀបចំសម្ភារដើម្បីទៅធ្វើការនៅកន្លែងផ្សេងទៀត។ ផុាំ ត្រូវបានខ្មែរក្រហមចាប់ចងបញ្ជូនឡើងរទេះសេះ ចំណែកប្រពន្ធកូនបញ្ជូនឡើងរទេះមួយផ្សេងទៀត។ នៅពេលនោះ ខ្មែរក្រហមសួរកូនស្រីផុាំថា៖ «មីអូនៗ ហែង ទៅជិះរទេះសេះជាមួយប៉ាហ្អី?», កូនស្រីផុាំ ឆ្លើយថា៖ «ខ្ញុំថាខ្ញុំនៅជាមួយម៉ែខ្ញុំ» ដោយសារកូនស្រីផុាំធ្លាប់ឃើញខ្មែរក្រហមសម្លាប់អ្នកធ្វើការជាមួយឪពុកប៉ុន្មានថ្ងៃមុន។ ចាប់តាំងពីពេលនោះមក ប្រពន្ធផុាំមិនហ៊ានសួរនាំខ្មែរក្រហមពីដំណឹងប្តីរបស់ខ្លួនទេ។

ប្រពន្ធ និងកូនផុាំ ត្រូវឃុំឃាំងនៅមន្ទីរឃុំឃាំងសាលាក្រៅអស់រយៈពេលមួយឆ្នាំ។ ប្រពន្ធនិងកូនផុាំ ត្រូវធ្វើការដូចជាធ្វើស្រែ, ស្ទូងស្រូវ, ជីកដី និង

លើកភ្លឺស្រែ។ នៅសាលាក្រៅ អ្នកទោសត្រូវបែកជាពីរប្រភេទ គឺអ្នកទោសកម្រិតស្រាល និងកម្រិតធ្ងន់ៗ អ្នកទោសកម្រិតស្រាលហូបបាយ ចំណែកអ្នកទោសកម្រិតធ្ងន់ហូបបបរ។ នៅសាលាក្រៅ កូនផុំនិយាយថា បានឃើញខ្មែរក្រហមប្រើប្រាស់ដំបង, កាំភ្លើង បុចំពុះ ទុងចាក់សម្លាប់អ្នកទោសក្នុងសភាពអាក្រាតកាយ មុនទម្លាក់ចូលរណ្តៅ។ ប្រជាជនទាំងប្រុសទាំងស្រី ទាំងចាស់ទាំងក្មេងជាច្រើននាក់ត្រូវបានខ្មែរក្រហមសម្លាប់នៅទីនោះ។ មនុស្សទាំងរថយន្ត ត្រូវតម្រង់ជាជួររង់ចាំសេចក្តីស្លាប់ ក្រោមការបញ្ជាពីប្រធានមន្ទីរឈ្មោះ តាកង។

នៅចុងឆ្នាំ១៩៧៨ ប្រពន្ធនិងកូនផុំ ត្រូវបានខ្មែរក្រហមបញ្ជូនទៅព្រែកតូច ខេត្តកំពង់ឆ្នាំង។ នៅពេលធ្វើដំណើរតាមកាណូត ប្រពន្ធនិងកូនផុំ បានរួមដំណើរជាមួយគ្រួសារមួយមកពីកំពង់គរ។ ប្រពន្ធផុំ បានលួចប្តូរសំបុត្រជាមួយគ្រួសារមួយនេះ ធ្វើឱ្យខ្មែរក្រហមច្រឡំសំបុត្រ និងទុកឱ្យប្រពន្ធនិងកូនផុំឱ្យរស់រានមានជីវិត។ ប្រពន្ធនិងកូនផុំ ធ្វើការនៅព្រែកតូច ដោយត្រូវក្រងស្បូវ, ប្រមូលលាមកគោសម្រាប់ធ្វើជី និងទូលជីទៅបាចក្នុងស្រែ។ កូនផុំ ត្រូវក្រងស្បូវចំនួន១៥កណ្តាប់ក្នុងមួយថ្ងៃ ទើបបានបបរមួយកាសម្រាប់ហូប។

នៅខែធ្នូ ឆ្នាំ១៩៧៨ ថ្ងៃមួយនាម៉ោង៣យប់ ប្រពន្ធនិងកូនផុំ បានរត់ចេញពីភូមិទៅពួននៅព្រៃដែលមានចម្ងាយ៩គីឡូម៉ែត្រពីព្រែកតូច និងគេចទៅអន្លង់វិល រហូតជួបកងទ័ពវៀតណាមតាមផ្លូវនៅឆ្នាំ១៩៧៩។ នៅរបបខ្មែរក្រហម បងប្អូនផុំពីរនាក់រួមទាំងផុំត្រូវបានស្លាប់។ ចំណែកប្រពន្ធផុំ បាត់បង់បងប្អូនប្រាំមួយនាក់។



កម្មាភិបាលខ្មែរក្រហមនៅសហករណ៍កំពុងបររទេះសេះ។ (ហុនណា បឺយស្រ្តម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឌុល ថាត៖ អតីតអ្នកឃោសនានារីក្នុងភូមិស្វាយឃ្លាំង ឱ្យកាត់សក់ខ្លី និងជាប្រធានក្រុមសេដ្ឋកិច្ច ភូមិភាគបូព៌ា

***មីន សាណាស់***

អតីតជានារីអង្គការបដិវត្តន៍ខ្មែរក្រហម ដែលបានទទួលភារកិច្ចជាជំនួយការយុវជនឃុំស្វាយឃ្លាំង និងជាអ្នកឃោសនាឱ្យស្ត្រីជនជាតិចាមក្នុងឃុំស្វាយឃ្លាំងកាត់សក់ខ្លី ដើម្បីងាយស្រួលធ្វើស្រែចម្ការ ដូចជា ដកសំណាប ឬស្ទូងស្រូវជូនអង្គការបដិវត្តន៍ជាដើម។ ឌុល ថាត មានចិត្តសប្បាយរីករាយក្នុងការចែករំលែករឿងរ៉ាវរបស់ខ្លួន ដែលធ្លាប់ជ្រុលខ្លួនចូលរួមបម្រើការឱ្យរបបខ្មែរក្រហម ដើម្បីចងក្រងជាឯកសារ ទុកបង្រៀនដល់យុវជនជំនាន់ក្រោយ មុនពេលគាត់ស្លាប់។ ថាត បានបន្ថែមទៀតថា រឿងរ៉ាវនៃការឆ្លងកាត់ក្នុងរបបខ្មែរក្រហមបានផ្ទុកក្នុងខ្លួនរបស់គាត់ជាច្រើនឆ្នាំកន្លងមកហើយ។ នៅពេលដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាមកសួរនាំ គាត់ពិតជាសប្បាយរីករាយក្នុងការចែករំលែកបទពិសោធន៍ជាអ្នកបដិវត្តន៍។ ការចែករំលែករបស់គាត់ក៏ជាចំណែកមួយក្នុងការជួយទប់ស្កាត់ អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍ និងរារាំងកុំឱ្យមានអំពើឃោរឃៅកើតឡើងសារជាថ្មី។



ប្រវត្តិរូបរបស់ ឌុល ថាត។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ឌុល ថាត ឈ្មោះហៅក្រៅ ឌុល អាន ភេទស្រី កើតខែធ្នូ ឆ្នាំ១៩៥៤ នៅភូមិព្រែកក្រើង ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម (បច្ចុប្បន្នខេត្តត្បូងឃ្មុំ)។ ក្រោយរបបខ្មែរក្រហមខ្ញុំផ្លាស់ទីលំនៅ មករស់នៅក្នុងភូមិទី៤ ឃុំរកាខ្នុរ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ ដា ឌុល (ស្លាប់ក្នុងឆ្នាំ១៩៨៧) និងម្តាយឈ្មោះ ឈុន ស៊ីម ដែលក្នុងឆ្នាំ១៩៧៤ ទទួលភារកិច្ចជាប្រធាននារីស្នេហាជាតិភូមិ (ស្លាប់នៅឆ្នាំ១៩៧៩ ដោយការលួចបាញ់ ពេលចលាចលនៅក្នុងព្រៃជប់)។ ខ្ញុំមានបងប្អូនបង្កើតចំនួន៨នាក់ ក្នុងនោះគឺមានប្រុស

ចំនួន៤នាក់។ ខ្ញុំជាកូនទីពីរក្នុងគ្រួសារ។ ក្នុងរបបខ្មែរក្រហមបងប្រុសរបស់ខ្ញុំឈ្មោះ ជា ឡឿន ហៅ ជា ធី ជាយោធាភូមិភាគបូព៌ា និង ប្អូនប្រុសឈ្មោះ ជា ផល បានបាត់ខ្លួនរហូតមកដល់បច្ចុប្បន្ន។ ចំណែកប្អូនស្រីចំនួនពីរនាក់ទៀតឈ្មោះ អៀន និង ថេនបានស្លាប់ដោយការលួចបាញ់ ពេលចលាចលក្នុងឆ្នាំដើម១៩៧៩ នៅក្នុងព្រៃដប់ខណៈពេលនៅមើលថែទាំម្ដាយរបស់ខ្ញុំដែលគាត់មានជំងឺដើរមិនរួច។

រំឭកកាលពីកុមារភាព ដោយសារគ្រួសាររបស់ខ្ញុំមានជីវភាពក្រលំបាក ខ្វះខាតខ្លាំង ខ្ញុំត្រូវបង្ខំចិត្តឈប់រៀនក្នុងថ្នាក់ទី១២ចាស់ ក្រោយពីបានចូលរៀនក្នុងសាលារយៈពេលពីរខែ។ បន្ទាប់ពីឈប់រៀន ខ្ញុំត្រូវត្រឡប់មកមើលថែទាំប្អូនៗ ជាពិសេសប្អូនស្រីពៅរបស់ខ្ញុំឈ្មោះ ថេន ដែលត្រូវបៅទឹកដោះគោកំប៉ុង ព្រោះម្ដាយខ្ញុំចេញទៅលក់បបរនៅផ្សារព្រែកច្រើង ចំណែកឪពុកខ្ញុំត្រូវទៅស៊ីឈ្នួលរត់រទេះកង់។ ដោយសារជីវភាពក្នុងគ្រួសារលំបាក និងឈឺចាប់ចំពោះវណ្ណៈជិះជាន់លើកម្មករ កសិករក្រីក្រ ព្រមទាំងស្ដាប់តាមអង្គការដឹកនាំ ខ្ញុំក៏ចូលបដិវត្តន៍នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧២ តាមរយៈឈ្មោះ មាក ដែលមានតួនាទីជាយុវជនឃុំ។ ចូលបម្រើបដិវត្តន៍ដំបូង អង្គការឱ្យមេជ្រូកមកខ្ញុំចិញ្ចឹម។ នៅពេលមេជ្រូកកើតកូន ខ្ញុំមានតួនាទីចែករំលែកមេជ្រូកឬកូនជ្រូកទៅកាន់យុវនារីផ្សេងទៀតក្នុងភូមិឱ្យចិញ្ចឹមដើម្បីជួយសម្រួលជីវភាពគ្រួសារប្រចាំថ្ងៃ។ ក្រៅពីនោះ ខ្ញុំមានភារកិច្ចជួយបង្រៀនយុវនារីជនជាតិចាមជាពិសេសចាមនៅស្វាយឃ្លាំងក្នុងភូមិទី៦ ឱ្យបេះស្ទូងស្រូវ និង ដកសំណាប។

នៅខែកញ្ញា ឆ្នាំ១៩៧៤ ដោយសារអង្គការឃើញជីវភាពគ្រួសារខ្ញុំខ្វះខាត មានបងប្អូនច្រើន មានវណ្ណៈជាកសិករក្រ ដើរស៊ីឈ្នួល និងធ្វើស្រែចម្ការ ប៉ុន្តែក៏ជាក្រុមគ្រួសារមានគុណសម្បត្តិ ព្រោះមានកូនប្រុសឈ្មោះ ជា ឡឿន ហៅជា ធី ចេញទៅធ្វើកងទ័ពភូមិភាគតាំងពីឆ្នាំ១៩៧២។ ចំណុចទាំងអស់នេះបញ្ជាក់ថាគ្រួសារខ្ញុំព្រមលះបង់ជូនអង្គការ ទើបអង្គការថ្នាក់ឃុំ ជ្រើសរើសខ្ញុំឱ្យចូលធ្វើជានារីឃុំ ចំណែកម្ដាយរបស់ខ្ញុំមានតួនាទីជាប្រធាននារីស្នេហាជាតិភូមិ។ ការជ្រើសរើសពីអង្គការឃុំ ក៏ជាបំណងរបស់ខ្ញុំ ដែលចង់ចូលធ្វើការក្នុងជួរបដិវត្តន៍។ កាលនោះប្រធានឃុំស្វាយឃ្លាំងមានឈ្មោះ តា ឡុង មានតួនាទីក្ដាប់ឃុំទាំងមូល។ ខ្ញុំត្រូវផ្លាស់ពីផ្ទះទៅរស់នៅទីតាំងឃុំផ្ទាល់ ដែលពេលនោះមានមិត្តនារីភូមិផ្សេងទៀតចំនួនបីនាក់ទៀតឈ្មោះ ស៊ុន, សុភី និង សេង។ ក្រោយពីបានចូលធ្វើការ ភារកិច្ចនារីឃុំរបស់ខ្ញុំ និងនារីបីនាក់ទៀត គឺអង្គការឱ្យចុះទៅស្នាក់នៅក្នុងភូមិជនជាតិចាម។ ខ្ញុំដឹកនាំយោសនានារីជនជាតិចាមក្នុងឃុំស្វាយឃ្លាំង ដោយបង្ហាញពីភាពងាយស្រួលរបស់ខ្ញុំដែលមានសក់ខ្លី និងស្នើឱ្យនារីចាម ក្មេងៗក្រមុំកាត់សក់ខ្លី ព្រោះសក់វែងវាពិបាកក្នុងការបង ឬ បួងសក់ និងសក់ខ្លីមានភាពងាយស្រួលពេលចុះស្ទូងមិនលំបាក។ នៅពេលនោះគឺនារីៗជនជាតិចាម ព្រមកាត់សក់តាមខ្ញុំ។ ក្មេងក្រមុំមួយចំនួន នាំគ្នាមកឱ្យខ្ញុំកាត់សក់ទាំងយប់ក៏មាន។ ដោយហេតុនេះ នាំឱ្យឪពុកម្ដាយ និងថ្នាក់ដឹកនាំក្នុងភូមិកើតមានសេចក្ដីមិនពេញចិត្ត បូកផ្សំជាមួយការបាត់ខ្លួនរបស់ថ្នាក់ដឹកនាំសាសនាធំៗ តួន (គ្រូបង្រៀន) បុរសៗក្នុងភូមិស្វាយឃ្លាំងក៏នាំគ្នាឡើងបះបោរជាមួយកម្លាំងខ្មែរក្រហម។ តែជាសំណាងល្អរបស់ខ្ញុំ មុនកើតហេតុនៃការបះបោរ គឺមានបុរសជនជាតិចាមម្នាក់មកប្រាប់ឱ្យក្រុមរបស់ខ្ញុំចេញពីភូមិ ដោយគាត់ថែមទាំងរករទេះសេះដឹកក្រុមខ្ញុំចេញពីភូមិ។ ប៉ុន្តែជាអកុសល យុវជនខាងផ្នែកវប្បធម៌ម្នាក់ឈ្មោះ ចែត បានភ្លេចរបស់ ហើយត្រឡប់ទៅយកវិញម្នាក់ឯង ក៏ត្រូវកម្លាំងបះបោរកាប់សម្លាប់។

ក្រោយមក សកម្មភាពបះបោរ ត្រូវបានបង្ក្រាបដោយកងទ័ពស្រុក។ បន្ទាប់មកកងទ័ពខ្មែរក្រហមបានបង្ជនជាតិចាមជាច្រើនខ្សែវែងៗ ក្នុងមួយខ្សែមានមនុស្សប្រហែលជាពី២០ ទៅ៣០នាក់ យកចេញទៅ។ ខ្ញុំមិនដឹងថាកងទ័ពយកទៅសម្លាប់ ឬ យក

ទៅឃុំឃាំងនៅទីណានោះឡើយ។ ខ្ញុំលែងបានរស់នៅភូមិចាម ក៏ផ្លាស់ដូរមករស់នៅភូមិខ្ពបរកា ដែលមានតែប្រជាជនខ្មែរ។ ស្ថិតនៅទីតាំងភូមិខ្ពបរកា ខ្ញុំត្រូវចុះជួយប្រជាជនស្ទូងស្រូវ។ បានរយៈពេលជាងមួយខែ ដោយសារអង្គការឃើញអំពីសីលធម៌រស់នៅរបស់ខ្ញុំក្រោយពីចូលបដិវត្តន៍ ចេះសុភាពរាបសារ មានសីលធម៌ល្អ ប្រយុទ្ធដាច់ខាតលើការកិច្ចដែលបក្សប្រគល់ឱ្យ ទើបអង្គការដំឡើងឱ្យធ្វើជាប្រធានក្រុមមន្ទីរសេដ្ឋកិច្ច នៅភូមិភាគបូព៌ា ក្នុងខែតុលា ឆ្នាំ១៩៧៥។

នៅចុងឆ្នាំ១៩៧៥ អង្គការចាត់តាំងឈ្មោះខ្ញុំ និងយុវជនក្នុងស្រុកក្រូចឆ្មារប្រហែលជា២០០នាក់ ឱ្យឡើងទៅធ្វើយោធានៅទីក្រុងភ្នំពេញ។ ប៉ុន្តែមុននឹងខ្ញុំអាចឡើងទៅក្រុងភ្នំពេញ អង្គការតម្រូវឱ្យខ្ញុំមកលត់ដំ ហ្វឹកហាត់ក្បួនយោធា ឱ្យចេះផ្នែកវិន័យយោធា នៅទីតាំងវត្តមេបុណ្យ ស្ថិតក្នុងភូមិចក ខេត្តព្រៃវែង រយៈពេលមួយខែសិន។ ដល់ពេលមកដល់ភ្នំពេញ ដំបូងអង្គការឱ្យខ្ញុំនៅខាងភូមិមង្គលជ័យ ស្រុកកៀនស្វាយ និងអង្គការបន្តឱ្យយុវជនទាំងអស់លត់ដំបន្ថែមទៀត។ ពាក្យលត់ដំរបស់អង្គការ គឺឱ្យយុវជនចុះស្ទូងស្រូវ និងធ្វើស្រែ។ ក្រោយមកទើបអង្គការជ្រើសរើសខ្ញុំឱ្យទៅធ្វើការនៅក្រសួងកសិកម្ម ជិតទឹកថ្លា។ ប្រធានក្រសួងកសិកម្មដំបូងឈ្មោះ នួន ជា ដែលគ្រប់គ្នាហៅថាតា នួន ជា (មិនមែន នួន ជា អនុលេខាបក្សទេ)។ ក្រោយមកអង្គការដក នួន ជា ចេញ ក៏មានប្រធានគ្រប់គ្រងថ្មីឈ្មោះ តាសារ៉ាត។ នៅក្នុងក្រសួងកសិកម្មផ្នែកនារីមានឈ្មោះ លី (ស្រី) គឺជាអ្នកអប់រំ ចំណែកយុវជនគឺមានឈ្មោះ មួន។ ខ្ញុំធ្លាប់ជួប នួន ជា និង ខៀវ សំផន នៅពេលមានសន្និបាតបក្សនៅស្តាតអូឡាំពិក។ ខ្ញុំចាំសំដីរបស់ ខៀវ សំផន និយាយថា «ការអប់រំអ្នកខាងផ្នែកកសិកម្មឱ្យខំធ្វើស្រែ គឺដើម្បីជាគំរូល្អដល់ប្រជាជន។ ឱ្យប្រជាជនខំប្រឹងប្រែង និងឱ្យប្រជាជនឃើញថាយើងជាកម្លាំងស្នូល»។

នៅខែមករា ឆ្នាំ១៩៧៦ អង្គការបានចាត់តាំងខ្ញុំឱ្យធ្វើជាគណៈកងអនុសេនាតូច ប្រចាំកសិដ្ឋានអង្គរជ័យរហូតដល់ឆ្នាំ១៩៧៨។ នៅឆ្នាំ១៩៧៨ អង្គការផ្លាស់ខ្ញុំឱ្យមកធ្វើការនៅតំបន់ទឹកថ្លា ផ្នែករោងចក្រក្រឡឹង ដោយមូលហេតុរោងចក្ររបស់អង្គការគឺខ្វះកម្មករ។ បន្ទាប់ពីឆ្នាំ១៩៧៧ អង្គការចាប់ផ្តើមធ្វើប្រវត្តិរូបបដិវត្តន៍របស់យុវនារី និងយុវជនជាញឹកញាប់។ រាល់ពេលធ្វើប្រវត្តិរូប ខ្ញុំមិនបានកុហកអង្គការឡើយ។

នៅដើមឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា សហការជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាម បានវាយរំដោះប្រទេសកម្ពុជាពីទិសខាងកើត និងសង្គ្រោះប្រជាជនបានជាបន្តបន្ទាប់។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពបានវាយរំដោះទីក្រុងភ្នំពេញ ហើយថ្ងៃនេះបានក្លាយជាថ្ងៃប្រវត្តិសាស្ត្រនៃការរំដោះជាតិ។ រណសិរ្សនេះ បានបង្កើតរបបថ្មីឈ្មោះថា «សាធារណរដ្ឋប្រជាមានិតកម្ពុជា»។ ប៉ុន្តែខ្ញុំ ត្រូវរត់ភៀសខ្លួនតាមកងទ័ពខ្មែរក្រហមទៅរស់នៅព្រំដែនថៃរហូតដល់ឆ្នាំ១៩៩២ ទើបត្រឡប់មកស្រុកកំណើតវិញ។



យុទ្ធនារីបដិវត្តន៍ខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ទីន គាស រំឭកអំពីបទពិសោធន៍ស្តីពីការជម្លៀសដោយបង្ខំទៅកាន់ភូមិភាគពាយ័ព្យក្នុងរបបខ្មែរក្រហម

**ស៊ាង ចិន្តា**



ទីន គាស អាយុ៦១ឆ្នាំ សព្វថ្ងៃរស់នៅភូមិទី១៣ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ទីន គាស អាយុ៦១ឆ្នាំ កើតនិងរស់នៅភូមិទី១៣ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំប្រកបរបរធ្វើស្រែចម្ការ និងជាប្រជានេសាទ។ ខ្ញុំមានប្តីឈ្មោះ ញ៉ា និងមានកូនប្រុសស្រីចំនួន ២នាក់។ ឪពុកខ្ញុំឈ្មោះ ទីន និងម្តាយឈ្មោះ ម៉ាស ហើយខ្ញុំជាកូនទី៥ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន ៦នាក់។ កាលពីក្មេង ខ្ញុំចូលរៀននៅសាលាបឋមសិក្សាកោះសូទិន ប៉ុន្តែរៀនមិនបានប៉ុន្មានផង ក៏មានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែងដោយលោក លន់ នល់ នាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ មិនយូរប៉ុន្មានបន្ទាប់ពីរដ្ឋប្រហារ អ្នកភូមិបាននាំគ្នាចូលរួមបាតុកម្ម និងដង្ហែក្បួនចូលទៅកាន់ទីរួមខេត្តកំពង់ចាម។

នៅឆ្នាំ១៩៧១ និងឆ្នាំ១៩៧២ ខ្ញុំបន្តរស់នៅក្នុងភូមិជាមួយឪពុកម្តាយខ្ញុំដដែល ប៉ុន្តែបានឈប់រៀន ពីព្រោះនៅពេលនោះមានការប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម។ សង្គ្រាមនេះបានផ្ទុះឡើងកាន់តែខ្លាំងឡើងៗ។ នៅថ្ងៃមួយ កងទ័ពខ្មែរក្រហមបានបើកការប្រយុទ្ធជាទ្រង់ទ្រាយធំនៅលើទឹកដីកោះសូទិន ដែលអូសបន្លាយរយៈពេល៧ថ្ងៃ៧យប់។ ខ្ញុំ និងគ្រួសាររត់ភៀសខ្លួនទៅខាងដីហែ ដែលជាតំបន់រំដោះរបស់ខ្មែរក្រហម ជាទីតាំងដែលមានសុវត្ថិភាព។

នៅចុងឆ្នាំ១៩៧៤ កងទ័ពខ្មែរក្រហមបានរំដោះភូមិសាស្ត្រជាច្រើន និងដាក់កម្លាំងហ៊ុមព័ទ្ធទីរួមខេត្តកំពង់ចាម។ គ្រួសារខ្ញុំបានវិលត្រឡប់មកភូមិវិញ ដែលនៅពេលនោះមានសភាពស្ងប់ស្ងាត់ដូចធម្មតា។ អ្នកភូមិទាំងអស់ រួមទាំងគ្រួសាររបស់ខ្ញុំ ត្រូវបានអង្គការដាក់ចូលធ្វើការនៅក្នុងកងប្រវាស់ដៃ ដើម្បីធ្វើស្រែចម្ការ និងប្រមូលផលស្រូវដើម្បីចែកគ្នាហូប។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានវាយកាន់កាប់ទីក្រុងភ្នំពេញ និងជម្លៀស

ប្រជាជនដោយបង្ខំចេញពីទីក្រុងទៅកាន់ទីជនបទនានា។ ប្រហែល៣-៤ខែក្រោយមក គ្រួសាររបស់ខ្ញុំ និងអ្នកភូមិជាច្រើនគ្រួសារផ្សេងទៀត ត្រូវបានខ្មែរក្រហមជម្លៀសទៅភូមិភាគពាយ័ព្យ គឺខេត្តបាត់ដំបង។ ខ្ញុំលឺខ្មែរក្រហមនិយាយភូតកុហកថា ការចេញទៅនេះ គឺទៅរស់នៅបរទេស (បណ្ដាប្រទេសដែលកាន់សាសនាអ៊ិស្លាម)។ ទោះបីជាដឹងថា នេះគឺជាការនិយាយភូតកុហកក៏ដោយ គ្រួសារខ្ញុំគ្មានជម្រើសអ្វីនោះឡើយ។ ខ្មែរក្រហមជម្លៀសគ្រួសាររបស់ខ្ញុំ និងអ្នកភូមិ ដោយការដឹកតាមរទេះគោទៅមាត់ទន្លេ ដើម្បីបន្តជិះកាណូត។ ការធ្វើដំណើរនាគ្រានោះ គឺពិបាកណាស់។ ម្ដាយរបស់ខ្ញុំដែលទើបតែសម្រាលកូនបានធ្លាក់ខ្លួនឈឺទាស់តាមផ្លូវ។ នៅពេលដែលទៅដល់ខេត្តបាត់ដំបង ខ្មែរក្រហមបានរៀបចំបែងចែកឱ្យជនជាតិចាមចំនួន២០គ្រួសារ រស់នៅតាមភូមិនីមួយៗ។

នៅពេលនោះ ខ្ញុំបានបែកបាក់ចេញពីឪពុកម្ដាយ និងបងប្អូន។ បងប្រុសបងស្រីរបស់ខ្ញុំចំនួន២នាក់ ដែលបានចូលបដិវត្តន៍នៅឆ្នាំ១៩៧១ ត្រូវបានចាប់ខ្លួន និងសម្លាប់ចោល។ ចំណែកឯជីតារបស់ខ្ញុំបានស្លាប់ដោយសារតែអត់ឃ្លាន។ មុនពេលជីតារបស់ខ្ញុំស្លាប់ គឺគាត់ស្រែករកអាហារហូប។ ខ្ញុំត្រូវបានដាក់ឱ្យធ្វើការងារនៅកងកុមារ ដូចជា ដើរដកស្មៅ ដើររើសអាចម៍គោ និងកាត់ទន្ទ្រានខែត្រធ្វើជីធម្មជាតិសម្រាប់ដាក់ស្រែ។ ខ្ញុំក៏មិនមានអាហារហូបគ្រប់គ្រាន់ គឺមានតែបបររាវបីពេលក្នុងមួយថ្ងៃ។ ដោយសារតែសេចក្ដីស្រេកឃ្លាន ខ្ញុំបានលួចពោតអង្ករ និងរើសខ្យង-ខ្ចៅហូប។ ដោយសារការលួចរបស់ខ្ញុំ ទើបឈ្លបចាប់ខ្លួនយកទៅធ្វើទារុណកម្ម។ ឈ្លបបានវាយខ្ញុំជាមួយដងកាំភ្លើង និងចាប់ក្បាលខ្ញុំជ្រមុជចូលក្នុងទឹកភ្លឺស្រែ។ ជាកុសលផលបុណ្យមិនអស់អាយុ ទើបខ្ញុំអាចនៅរស់រានមានជីវិតរហូតមកដល់សព្វថ្ងៃ។ ទោះបីជាខ្ញុំមិនស្លាប់ ប៉ុន្ដែខ្ញុំនៅតែមានអារម្មណ៍ភិតភ័យ និងនៅតែដិតដាមចំពោះការធ្លាប់ឃើញខ្មែរក្រហមយកប្រជាជនទៅសម្លាប់ចោល។

នៅពេលដែលឃើញខ្មែរក្រហមបន្តសម្លាប់ប្រជាជនកាន់តែច្រើនឡើង ខ្ញុំក៏សម្រេចចិត្តគេចចេញពីតំបន់រស់នៅ ដោយត្រូវហែលឆ្លងស្ទឹងមកស្វែងរកឪពុកម្ដាយ។ ខ្ញុំដឹងថាខ្មែរក្រហមពិតជាចេញតាមរកចាប់ខ្លួនខ្ញុំប៉ុន្ដែនៅពេលនោះ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានចូលមកដល់ដើម្បីរំដោះប្រជាជនចេញពីការកាប់សម្លាប់របស់ខ្មែរក្រហម។ ខ្ញុំបានជួបជុំជាមួយឪពុកម្ដាយ និងវិលត្រឡប់មករស់នៅភូមិកំណើតវិញ។ អ្វីដែលខ្ញុំចងចាំមិនភ្លេចនោះគឺ ខ្មែរក្រហមបានសម្លាប់បងស្រីរបស់ខ្ញុំដែលកំពុងតែមានផ្ទៃពោះ។ ខ្ញុំពិតជាស្រណោះបងស្រីខ្ញុំណាស់ ហើយបច្ចុប្បន្ន ខ្ញុំក៏មានបញ្ហាសុខភាពខ្វះៗដែរ។



ប្រជានេសាទសហគមន៍ជនជាតិចាមនៅក្នុងឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សំ សាបួរ៖ ក្លាយជាកូនចិញ្ចឹមមេភូមិ ក្នុងតំបន់ពាយ័ព្យ

**មីន សាណាស់**



*សំ សាបួរ គឺជាមន្ត្រីបម្រើការងារផ្នែកហិរញ្ញវត្ថុនៃមជ្ឈមណ្ឌលគុរកោសល្យភូមិភាគខេត្តព្រៃវែង បច្ចុប្បន្នរស់នៅភូមិទី២ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅឆ្នាំ១៩៧៨ បន្ទាប់ពីមានព្រឹត្តការណ៍ សោ ភឹម ប្រធានភូមិភាគបូព៌ា ត្រូវចោទប្រកាន់ថាក្បត់អង្គការមជ្ឈិមបក្ស គ្រួសារខ្ញុំក៏ត្រូវអង្គការខ្មែរក្រហមជម្លៀសដោយបង្ខំទៅកាន់ភូមិភាគពាយ័ព្យ ហើយត្រូវធ្វើដំណើរចេញពីភូមិបឹងវែង ឃុំដំរីពួន ឆ្ពោះមកឃុំអង្គរទ្រេត រួចឡើងជិះកាណូតមកកាន់ច្បារអំពៅ ក្រុងភ្នំពេញ ដើម្បីបន្តដំណើរតាមផ្លូវរថភ្លើងបន្ត។ គ្រួសារខ្ញុំត្រូវអង្គការបាត់តាំងឱ្យចុះនៅតំបន់ស្វាយដូនកែវ ខេត្តពោធិ៍សាត់។ ពេលចុះពីលើរថភ្លើង អង្គការបានបែងចែកសមាជិកគ្រួសារខ្ញុំតាមផ្នែកផ្សេងៗគ្នា។ បងប្រុស បងស្រីខ្ញុំដែលមិនទាន់មានគ្រួសារត្រូវចូលក្នុងកងចល័តស្រួច និងបងស្រីខ្ញុំពីរនាក់ដែលមានគ្រួសារហើយត្រូវទៅធ្វើការក្នុងសហករណ៍។ ចំណែកខ្ញុំត្រូវចូលក្នុងកងកុមារ ដែលត្រូវបែកពីម្តាយរបស់ខ្ញុំ។ ជាសំណាងល្អសម្រាប់ខ្ញុំ ពេលធ្វើការក្នុងកងកុមារចល័តមានមេភូមិដែលគ្មានកូនបានយកខ្ញុំធ្វើជាកូនចិញ្ចឹម។ ចាប់ពីពេលនោះមក ខ្ញុំមានអាហារហូបគ្រប់គ្រាន់ ថែមទាំងអាចលួចបាយ ម្ហូបយកទៅឱ្យ មិត្តភក្តិ និងពូរបស់ខ្ញុំដែលធ្លាប់រស់នៅក្នុងភូមិបឹងវែង។

ខ្ញុំឈ្មោះ សំ សាបូរ អាយុ៥៥ឆ្នាំ (នៅក្នុងឆ្នាំ២០២០) មានមុខងារជាមន្ត្រីបម្រើការងារផ្នែកហិរញ្ញវត្ថុនៃមជ្ឈមណ្ឌលគុរុកោសល្យភូមិភាគខេត្តព្រៃវែង។ ខ្ញុំកើតនៅភូមិវាល (បច្ចុប្បន្នភូមិទី៧) ឃុំកំពង់លាវ ស្រុកព្រៃវែង ខេត្តព្រៃវែង។ បច្ចុប្បន្នខ្ញុំរស់នៅភូមិទី២ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។ ខ្ញុំមានបងប្អូនចំនួន៨នាក់ ក្នុងនោះមានស្រី៤នាក់។ ខ្ញុំជាកូនពៅក្នុងគ្រួសារ។ ក្នុងរបបខ្មែរក្រហម ឪពុករបស់ខ្ញុំ និងបងខ្ញុំចំនួន៥នាក់ ត្រូវខ្មែរក្រហមយកទៅសម្លាប់។

រំឭកកាលពីកុមារភាព ខ្ញុំចូលរៀននៅសាលាបឋមសិក្សាព្រៃវែងក្រុង។ ក្នុងឆ្នាំ១៩៧០ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០ សង្គមចាស់ ក៏ឈប់រៀន ប៉ុន្តែកាលនោះសាលារៀនខ្ញុំនៅមានគ្រូបង្រៀនធម្មតា។ ក្រោយពីមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីដំណែងក្នុងថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដោយលោកសេនាប្រមុខ លន់ នល់ ប្រទេសកម្ពុជាក៏ផ្លាស់ប្តូរទៅជារបបថ្មីឈ្មោះរបបសាធារណរដ្ឋខ្មែរ។ ចាប់តាំងពីពេលនោះមក កងទ័ពខ្មែររំដោះ ឬខ្មែរក្រហមក៏លេចមុខលេចមាត់ឡើងនៅតាមមូលដ្ឋាន ស្របជាមួយកងទ័ពវៀតកុង ក៏ចូលមកតាមភូមិឃុំមួយចំនួនក្នុងខេត្តព្រៃវែង។ បន្ទាប់ពីនោះក្រុងព្រៃវែងមានសភាពតូចជាងមុន ព្រមទាំងមានការហ៊ុមព័ទ្ធទៅដោយកម្លាំងកងទ័ពខ្មែរក្រហម និងវៀតកុង នៅជុំវិញខេត្ត។ នៅតាមព្រំប្រទល់នីមួយៗក៏មានការយាមល្បាតដោយកងស៊ុយត្រាយ មិនតែប៉ុណ្ណោះតែងតែការប្រយុទ្ធប្រទាយប្រទង់គ្នារវាងទាហាន លន់ នល់ និងខ្មែរក្រហមជាប់ជាកិច្ច។

ចាប់តាំងពីពេលនោះមក ប្រជាជនមិនអាចធ្វើដំណើរចេញចូលដោយសេរីបានទៀតបានឡើយ។ រីឯមធ្យោបាយធ្វើដំណើរគឺមានតែមួយគត់គឺយន្តហោះ។ ប្រជាជនដែលមានដីស្រែនៅជិតៗទីរួមខេត្តអាចទៅធ្វើស្រែបានដូចធម្មតា តែក៏ប្រឈមជាមួយការផ្លោងគ្រាប់បែកចូលបណ្តាលឱ្យមានប្រជាជនស្លាប់។ ប្រជាជនមានតែអង្ករបរិភោគ ចំពោះគ្រឿងទេស និងថ្នាំសង្កូវសម្រាប់ព្យាបាលគឺគ្មានឡើយ ជាហេតុធ្វើឱ្យមានការលំបាកក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ ស្ថានភាពនៅពេលនោះ គឺត្រូវពឹងពាក់លើយន្តហោះដឹកជញ្ជូនស្បៀង។ ក្នុងរយៈពេលមួយខែម្តង យន្តហោះដឹកជញ្ជូនស្បៀង តែងតែហោះមកទម្លាក់សម្ភារតាមឆ័ត្រយោង ប៉ុន្តែក្រោយមកទៀត មានការរារាំងពីកងទ័ពខ្មែរក្រហម។

នៅចុងឆ្នាំ១៩៧០ ឪពុកម្តាយខ្ញុំឃើញថាស្ថានភាពរស់នៅក្នុងខេត្តកាន់តែចលាចល និងហាក់គ្មានសុវត្ថិភាពចំពោះកូនស្រីៗ គាត់ក៏សម្រេចចិត្តនាំកូនចៅរត់ទៅរស់នៅជាមួយកូនប្រុសច្បងរបស់គាត់នៅភូមិបឹងវែង ឃុំដំរីពួន ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។ បងប្រុសខ្ញុំគាត់គឺជាអ្នកស៊ើបការណ៍យកព័ត៌មានពីកងកម្លាំងខ្មែរក្រហមទៅរាយការណ៍ឱ្យទាហាន លន់ នល់ និងយកពីទាហានលន់ នល់ ទៅរាយការណ៍ឱ្យកងទ័ពខ្មែរក្រហមនៅមូលដ្ឋាន។ គ្រួសារខ្ញុំរស់នៅក្នុងភូមិបឹងវែង រហូតខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

ក្នុងឆ្នាំ១៩៧៥ បន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជម្នះ បងប្រុសច្បងខ្ញុំ រួមទាំងប្រពន្ធកូន ត្រូវអង្គការចាប់យកទៅសម្លាប់នៅទីតាំងភូមិទឹកថ្លា ស្រុកស្វាយអន្ទរ។ គ្រួសារខ្ញុំត្រូវស្ថិតក្នុងបញ្ជីតាមដានពីឈ្លបភូមិ។ ដល់ឆ្នាំ១៩៧៧ អង្គការក៏ចាប់យកឪពុកខ្ញុំយកទៅសូត្រាមួយទៀត ដោយសម្អាងថាគាត់ជាអ្នកមាន ចំណេះដឹងជាសង្ឃធ្លាប់ធ្វើជាចៅអធិការវត្តពោធិ៍រៀងជំនាន់មុន។

ឆ្នាំ១៩៧៨ គ្រួសារខ្ញុំទាំងអស់ត្រូវបានអង្គការជម្លៀសឱ្យចាកចេញពីភូមិបឹងវែង ឃុំដំរីពួន ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង យកមកដាក់នៅត្រង់ចំណុចកំពង់ចម្លងអ្នកលឿង រួចបង្ខំគ្រួសារសាច់ញាតិខ្ញុំ និងប្រជាជនក្នុងភូមិភាគបូព៌ាឯទៀតឡើងលើកាណូត។ ពេលកាណូតដាក់ប្រជាជនជម្លៀសគ្រប់ចំនួនហើយ កម្មាភិបាលខ្មែរក្រហម ចាប់ផ្តើមចែកក្រមាដែលមានក្រឡាពណ៌ខៀវលាយស ព្រមទាំងមានចែក

បាយ និងត្រីកាម៉ុងចំហុយឱ្យហូប ទាំងខ្ញុំនិងអ្នកឯទៀតខំប្រឹងហូបៗ រហូតមានអ្នកស្លាប់ដោយសារឆ្អែតពេកៗ កាណូតមកដល់ទីក្រុងភ្នំពេញនៅចំណុចច្បារអំពៅ អង្គការឱ្យឡើងលើប្រាំង និងដើរសំដៅទៅចំណតរថភ្លើងដើម្បីបន្តដំណើរទៅតំបន់ដីខ្សាញ់ (ភូមិភាគពាយ័ព្យ)។ រថភ្លើងចេញទៅដល់ចំណតស្វាយ ដូនកែវ ខេត្តពោធិ៍សាត់ អង្គការក៏បញ្ជាឱ្យប្រជាជនចុះ ព្រមទាំងមានការបែងចែកជាប្អូនក្រុម មានដូចជា កងកុមារ កងយុវជន កងយុវនារី និងក្រុមអ្នកមានគ្រួសារហើយ ត្រូវនៅមួយក្រុមកងចាស់ៗមួយក្រុមទៀត។

ពេលនោះសមាជិកក្រុមគ្រួសារខ្ញុំមានគ្នាចំនួន៨នាក់ត្រូវបែកគ្នាក្រោមការចង្អុលបង្ហាញពីកងទ័ពខ្មែរក្រហមទៅគោលដៅខុសៗគ្នា។ នេះជាពេលវេលាដែលខ្ញុំចងចាំ និងមិនអាចបំភ្លេចបានជាទីបំផុតសម្រាប់រូបខ្ញុំនិងគ្រួសារ ព្រោះត្រូវជាប់មានឈ្មោះថាជាពួកខ្មាំងរបស់អង្គការ ត្រូវធ្វើការជូនអង្គការ តែហូបមិនបានគ្រប់គ្រាន់ៗ ហេតុនេះខ្ញុំ និងកងកុមារឯទៀតមានតែលួចទៅគាស់មើមរកា បេះផ្លែគរខ្ចីៗយកមកដុតហូបដើម្បីបំពេញក្រពះៗ រយៈពេលពីរខែក្រោយមកខ្ញុំ ត្រូវបានដូរទៅរស់នៅភូមិមួយទៀត ដែលមានគ្រួសារមេភូមិខ្មែរក្រហម ទទួលយកខ្ញុំទៅចិញ្ចឹម ព្រោះគាត់គ្មានកូនៗ នេះជាពេលវេលារីករាយជាទីបំផុតក្នុងរបបខ្មែរក្រហមសម្រាប់ខ្ញុំ ពីព្រោះខ្ញុំមានអាហារបរិភោគគ្រប់គ្រាន់ មានសម្លៀកបំពាក់របស់ប្រើប្រាស់ ហើយក៏មិនបានទៅធ្វើការជាមួយក្មេងឯទៀតៗ មួយវិញទៀតក្នុងនាមជាកូនចិញ្ចឹមរបស់មេភូមិ ខ្ញុំបានលួចបាយម្ហូបពីផ្ទះមកជួយដល់មិត្តភក្តិ និងពូរបស់ខ្ញុំដែលជម្លៀសពីភូមិភាគបូព៌ាដែលកំពុង អត់ឃ្លាន ដោយសារការបង្អត់អាហារពីខ្មែរក្រហម។

ចុងឆ្នាំ១៩៧៨ ខ្ញុំសម្រេចចិត្តដើរស្វែងរកបងៗនិងម្តាយរបស់ខ្ញុំៗ ប៉ុន្តែខ្ញុំទទួលដំណឹងថា បងប្រុសបងស្រីរបស់ខ្ញុំត្រូវឈ្លបខ្មែរក្រហមយកទៅសម្លាប់ៗ ក្នុងចន្លោះពីឆ្នាំ១៩៧៥ ដល់១៩៧៩ សមាជិកគ្រួសារខ្ញុំចំនួន៧នាក់ ត្រូវស្លាប់ក្រោមស្នាដៃខ្មែរក្រហម ហើយខ្ញុំក្លាយជាក្មេងកំព្រាឪពុកម្តាយ។



កុមារកំពុងរែកដីនៅក្នុងរបបខ្មែរក្រហមៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សាត គិ (ជនជាតិដើមភាគតិចព័រ)៖ អតីតកងទ័ពកងពលលេខ៨ ការពារព្រំដែនថ្មដា

ចាន់ ណារិទ្ធ

នៅក្នុងឆ្នាំ១៩៧៥ គិ ត្រូវបានខ្មែរក្រហមជ្រើសរើសឱ្យចូលបម្រើកងទ័ពខ្មែរក្រហម ស្ថិតក្នុងកងពលលេខ៨ ដែលមានតួនាទីការពារព្រំដែនថ្មដា ខេត្តពោធិ៍សាត់។ គិ បាននិយាយរៀបរាប់ពីបទពិសោធន៍ដែលធ្លាប់រស់នៅឆ្លងកាត់ក្នុងរបបខ្មែរក្រហមដូចខាងក្រោម៖

ឈ្មោះ សាត គិ ភេទប្រុស អាយុ៨២ឆ្នាំ កើតនៅឆ្នាំ១៩៤៣ ក្នុងភូមិទួលគ្រួស ឃុំស្រែតាំងយ៉ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ បច្ចុប្បន្នរស់នៅភូមិព្រែក១ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ គិ មានឪពុកឈ្មោះ ហួត សាត ( ស្លាប់ )។ ចំណែកម្តាយឈ្មោះ ហ៊ុ ឡាន ( ស្លាប់ ) ។ គិ មានបងប្អូនចំនួន ៥នាក់ ( ប្រុស២នាក់ និងស្រី៣នាក់) គិ ជាកូនទី៤ នៅក្នុងគ្រួសារ។ ប្រពន្ធ គិ ឈ្មោះ ស៊ុប ស៊ុម អាយុ ៧៧ឆ្នាំ។ គិ មានកូនចំនួន៤នាក់ ក្នុងនោះមានប្រុសម្នាក់។ កូនៗរបស់ គិ ទាំងអស់មានគ្រួសារហើយ។

កាលពីក្មេង គិ ចូលរៀនបានត្រឹមថ្នាក់ទី១១ ( សង្គមចាស់ ) នៅសាលាក្នុងភូមិទួលគ្រួស។ គ្រូបង្រៀន គិ ឈ្មោះ គ្រូធឿង និង គ្រូតេង គឺជាទាហានរបស់សម្តេចព្រះបាទ នរោត្តម សីហនុ ដែលបានបោះទីតាំងការពារនៅក្នុងភូមិទួលគ្រួស ហើយត្រូវបានអង្គភាពចាត់តាំងឱ្យធ្វើជាគ្រូបង្រៀនក្មេងៗនៅក្នុងសាលាភូមិទួលគ្រួស។ មូលហេតុដែល គិ ឈប់រៀនដោយសារតែអាយុច្រើន និងគ្មានអ្នកជួយធ្វើការងារម្តាយ ព្រោះឪពុកបានស្លាប់តាំងពី គិ អាយុ ១៣ឆ្នាំ។ បន្ទាប់ពីឈប់រៀនបានប្រហែលកន្លះឆ្នាំ គិ បានសម្រេចចិត្តសុំម្តាយចូលបួស នៅវត្តទួលគ្រួស



សាត គិ អាយុ៨២ឆ្នាំ សព្វថ្ងៃរស់នៅភូមិព្រែក១ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ( បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា )

បានរយៈពេល១១វស្សា។ ដោយសារតែឃើញម្តាយពិបាកគ្មានអ្នកជួយធ្វើការងារស្រែចម្ការ គិបានសម្រេចចិត្តសឹក និងដើម្បីត្រឡប់មកជួយការងារម្តាយវិញ។

នៅឆ្នាំ១៩៦៩ ម្តាយរបស់ គិ បានរៀបចំឱ្យ គិ មានប្រពន្ធ។ បន្ទាប់ពីរៀបការបានរយៈពេលមួយឆ្នាំ ក៏ចាប់ផ្តើមមានរដ្ឋប្រហារទម្លាក់ សម្តេចព្រះបាទ នរោត្តម សីហនុ ចេញពីតំណែងនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដោយលោក នល់ លន់។ ខណៈពេល

នោះនៅតាមស្រុកផ្សេងៗ ចាប់ផ្តើមមានភាពច្របូកច្របល់ ស្រុកខ្លះមានការធ្វើបាតុកម្មទាមទារឱ្យសម្តេចព្រះ នរោត្តម សីហនុ ឡើងគ្រប់គ្រងប្រទេសវិញ។ ប៉ុន្តែនៅក្នុងភូមិទួលគ្រួស ឃុំស្រែតាំងយ៉ មិនមានហេតុការណ៍អ្វីកើតឡើងនោះទេ ប្រជាជននៅតែបន្តប្រកបរបរធ្វើស្រែចម្ការបានធម្មតា។

នៅឆ្នាំ១៩៧២ កងទ័ពខ្មែរក្រហមប្រហែលជា១០នាក់ បានធ្វើដំណើរចូលមកក្នុងភូមិទួលគ្រួស ហើយកងទ័ពខ្មែរក្រហមបានធ្វើការឃោសនាប្រាប់ប្រជាជនដែលជាជនជាតិដើមភាគតិចព័រឱ្យចូលរួមចលនាតស៊ូជាមួយកម្លាំងខ្មែរក្រហម។ អ្នកដឹកនាំកងទ័ពខ្មែរក្រហមចូលមកឃោសនាដំបូងឈ្មោះ ហ៊ូ នឹម និង យ៉ន។

នៅចុងឆ្នាំ១៩៧៤ ហ៊ូ នឹម និង យ៉នបានដឹកនាំកងទ័ពបដិវត្តន៍ខ្មែរក្រហមជាច្រើននាក់ធ្វើដំណើរចូលមកដល់ភូមិទួលគ្រួសម្តងទៀត និងបានគ្រប់គ្រងភូមិទួលគ្រួសបានទាំងស្រុង។ បន្ទាប់មក ហ៊ូ នឹម និង យ៉ន ចាប់ផ្តើមលុបបំបាត់ចោលទំនៀមទំលាប់ ប្រពៃណី ឡើងអ្នកតា និងលុបបំបាត់ភាសារបស់ជនជាតិដើមភាគតិចព័រ។ ខ្មែរក្រហមបានគំរាមថា «បើហ៊ាននិយាយភាសាព័រ ឱ្យតែខ្មែរក្រហមស្តាប់ឮ នឹងចាប់យកទៅសម្លាប់»។

ក្រោយទទួលបានជ័យជម្នះទៅលើកងទ័ពឧត្តមសេនីយ៍ លន់ នល់ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យ៉ន បានប្រាប់ប្រជាជនឱ្យខំប្រឹងធ្វើស្រែ ដើម្បីចែកស្រូវគ្នាហូប។ ចំណែកការងារផ្សេងៗគឺធ្វើធម្មតាមិនទាន់មានការបង្ខិតបង្ខំឱ្យធ្វើការងារហួសកម្លាំងនោះឡើយ។ នៅពាក់កណ្តាលឆ្នាំ១៩៧៥ យ៉នបានចាប់ផ្តើមបង្កើតសហករណ៍នៅក្នុងភូមិទួលគ្រួស និងប្រាប់ប្រជាជនទាំងអស់ឱ្យប្រមូលស្រូវអង្ករដែលបានចែក និងសម្ភាររបស់របរយកមកទុកក្នុងសហករណ៍រួម ដើម្បីហូបរួម និងធ្វើការងាររួមគ្នា។ បន្ទាប់មកទៀត យ៉ន បានបែងចែកឱ្យមានកងកុមារ កងយុវជន និងកងមនុស្សចាស់។ សម្រាប់កងកុមារ យ៉ន ប្រើឱ្យដើរកាប់ទន្ទ្រានខែត្រ រើសអាចម៍គោ និងកាប់ដីដំបូក ដើម្បីលាយបញ្ចូលគ្នាធ្វើជីដាក់ស្រែ។ រីឯកងយុវជនត្រូវបាន យ៉ន ប្រើឱ្យរែកដី និងលើកទំនប់នៅកំពុងឃ្លោង ស្ថិតក្នុងភូមិទួលគ្រួស។ ចំណែកកងមនុស្សចាស់ត្រូវឱ្យនៅមើលក្មេងតូចៗនៅក្នុងសហករណ៍ ធ្វើទ្រូ និងត្បាញកញ្ជើ ដើម្បីទុកប្រើប្រាស់នៅក្នុងសហករណ៍។

ក្នុងអំឡុងពេលជាមួយគ្នា គិ មានអាយុ៣២ឆ្នាំ ត្រូវបាន យ៉ន ជ្រើសរើសឱ្យចូលបម្រើកងទ័ពខ្មែរក្រហម រួចបានបញ្ជូនឱ្យទៅចូលរួមជាមួយកងពលលេខ១៨ ដែលមានតួនាទីការពារព្រំដែនថ្មដា។ កងពលលេខ១៨ មានអ្នកគ្រប់គ្រងឈ្មោះ ខួយ មកពីខេត្តបាត់ដំបង។ ចំពោះរបបអាហារនៅពេល គិ មកយាមត្រង់ព្រំដែនថ្មដា គឺហូបបានគ្រប់គ្រាន់មិនមានការខ្វះខាតអ្វីឡើយ។

នៅឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានសហការជាមួយកងទ័ពវៀតណាម បានធ្វើដំណើរតាមផ្លូវលេខជាតិ៥៦ ចូលមកវាយដល់ព្រំដែនថ្មដា។ បន្ទាប់មក ខួយ បានបញ្ជាឱ្យកងទ័ពទាំងអស់ប្រមូលកម្លាំង ដើម្បីចុះមកទប់ទល់ជាមួយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាម។ ដោយសារកងទ័ពទាំងពីរមានកម្លាំងច្រើនមិនអាចទប់ទល់បាន គិ បានទម្លាក់អាវុធចោល រួចរត់ជាមួយប្រពន្ធចេញពីថ្មដា ត្រឡប់មកស្រុកកំណើតក្នុងភូមិទួលគ្រួសវិញ។ ចំណែកកងទ័ពខ្មែរក្រហមដទៃទៀតបានរត់គេចខ្លួនចូលទៅរស់នៅក្នុងទឹកដីថៃ។ នៅពេលរត់មកដល់ស្រុកកំណើត គី និងប្រពន្ធបានឃើញប្រជាជនប្រហែល៧គ្រួសារកំពុងស្នាក់នៅបណ្តោះអាសន្ននៅក្នុងភូមិទួលគ្រួស។ បន្ទាប់ពីស្នាក់នៅភូមិទួលគ្រួសបានមួយសប្តាហ៍ គិ និងប្រពន្ធ ត្រូវបានកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមកៀរឱ្យចុះទៅរស់នៅភូមិព្រែក១ ដែលស្ថិតនៅក្នុងស្រុកភ្នំក្រវាញ។ ក្រោយពេលចូលមករស់ភូមិព្រែក១ដំបូង កងទ័ពវៀតណាមបានចែកពោតក្រហមឱ្យ គិ សម្រាប់ជាអាហារ។ កន្លះខែ

ក្រោយមក គិ និងប្រពន្ធបានរានដីសម្រាប់សាងសង់ផ្ទះស្នាក់នៅ ធ្វើស្រែ និងដាំបន្លែបន្តិចបន្តួចដើម្បីចិញ្ចឹមជីវិតបន្តទៀត។ នៅពេលទំនេរពីការងារស្រែចម្ការ គិ តែងតែដើរបរបាញ់សត្វដើម្បីយកមកផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារបន្ថែម។ គិ និងប្រពន្ធរស់នៅភូមិព្រែក១ រហូតដល់ខ្មែរក្រហមចូលសមាហរណកម្មជាមួយរាជរដ្ឋាភិបាល ទើបសម្រេចចិត្តមករស់នៅភូមិកំណើតវិញ។ គិ បាននិយាយបន្តថា នៅពេលដែលធ្វើដំណើរត្រឡប់មករស់នៅស្រុកកំណើតវិញ គិ មានការលំបាកជាខ្លាំង ព្រោះតាមផ្លូវធ្វើដំណើរសម្បូរទៅដោយគ្រាប់មីនមិនទាន់ផ្ទុះ។ សម្រាប់ដីភូមិ និងដីស្រែនៅក្នុងភូមិទួលគ្រួស គិ និងប្រពន្ធបានចែកឱ្យកូនៗសម្រាប់បង្កបង្កើនផលនៅទីនោះ។ ចំណែក គិ និងប្រពន្ធបាននាំគ្នាត្រឡប់មកធ្វើស្រែនៅភូមិព្រែក១វិញ ហើយបានបន្តរស់នៅក្នុងភូមិព្រែក១រហូតមកដល់សព្វថ្ងៃ។



ជនជាតិដើមភាគតិចព័រនៅស្រុកវាលវែង ខេត្តពោធិ៍សាត់ ចូលរួមពិធីបុណ្យឡើងអ្នកតា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# ខ្ញុំធ្លាប់ឆ្លងកាត់ប្រាំសម័យកាលមកហើយ ហេតុនេះទំព័រចុងក្រោយនៃជីវិតខ្ញុំ គឺសុំបម្រើសាសនា

**មីន សាណាស់**

គ្រួសារខ្ញុំស្នាក់នៅក្នុងខុមស្វីកនាជាយក្រុងភ្នំពេញ ក្នុងអំឡុងពេលដែលកម្លាំងខ្មែរក្រហមទទួលបានជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ បន្ទាប់ពីនោះភ្លាមៗ ខ្ញុំបានឃើញប្រជាជនទូលបង្វេចដើរតាមថ្នល់មុខផ្ទះខ្ញុំ ដែលស្ថិតនៅម្តុំស្ទឹងមានជ័យ។ ដោយសារការងឿងឆ្ងល់ ខ្ញុំក៏ដើរចេញទៅសាកសួរ ចម្លើយតបមកវិញគឺ «កងទ័ពរំដោះបានដេញប្រជាជនដែលកំពុងរស់នៅម្តុំផ្សារថ្មីចេញ ឱ្យផុតរយៈពេលបីថ្ងៃសិនដើម្បីបោសសម្អាតទីក្រុងភ្នំពេញ»។ ចម្លើយដែលខ្ញុំបានឮ ធ្វើឱ្យចិត្តខ្ញុំមិនទាន់អស់ចម្ងល់ ក៏ចាំស្ទាក់សួរកងទ័ពពាក់អាវខ្មៅ ស្ពាយកាំភ្លើង និងមានវ័យប្រហែលជា១៣ឆ្នាំថា «សមមិត្ត គេនាំគ្នាចេញ លន់ៗ ហ្នឹងគេទៅណាវិញ?» កងទ័ពខ្មែរក្រហមបានតបខ្ញុំថា «មិត្តបង មិនបាច់ចេញទៅណាទេ ព្រោះមិត្តបងស្ថិតក្នុងវណ្ណៈអធន» ការឆ្លើយតបរបស់កងកម្លាំងខ្មែរក្រហមស្របទៅនឹងខ្សែភ្នែកកំពុងសម្លឹងផ្ទះរបស់ខ្ញុំ ដែលមានសមាជិកស្នាក់នៅរហូតទៅដល់១៣នាក់។ ពាក្យអធន វាថ្មីសម្រាប់ខ្ញុំ ប៉ុន្តែកាលដែលខ្ញុំចេះប្រើពាក្យថា សមមិត្ត ព្រោះខ្ញុំបានដឹងស្រាប់ទៅហើយថា ជាកងទ័ពរំដោះខ្មែរក្រហមជាអ្នកគ្រប់គ្រងតំបន់មូលដ្ឋានតាំងពីឆ្នាំ១៩៧០នៅឯស្រុកកំណើតរបស់ខ្ញុំ។ ទោះបីជាកងទ័ពខ្មែរក្រហមមិនឱ្យខ្ញុំចេញពីទីក្រុង តែខ្ញុំដឹងខ្លួនថាខ្ញុំជាគ្រូបង្រៀន ប្តីខ្ញុំជាគ្រូបង្រៀន គឺសុទ្ធតែមុខសញ្ញារបស់កងទ័ពអាវខ្មៅ។



សុខ គីមស្រឿង អាយុ៧១ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិទី៤ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សុខ គីមស្រឿង អាយុ៧១ឆ្នាំ (២០២០) កើតនៅភូមិខ្សង់ ឃុំពពឹស ស្រុកព្រៃវែង (បច្ចុប្បន្នស្រុកស្វាយអន្ទរ) ខេត្តព្រៃវែង។ សព្វថ្ងៃខ្ញុំរស់នៅក្នុងភូមិទី៤ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ សុខ ស៊ាម និងម្តាយឈ្មោះ ភូច ស្រីប។ ឪពុករបស់ខ្ញុំចេះជំនាញ

ខាងគ្រឿងម៉ាស៊ីន និងចូលចិត្តបើករថយន្តឈ្នួលចុះឡើងពីភូមិកំណើតទៅកាន់ទីរួមខេត្តព្រៃវែង ហើយគាត់មិនសូវចូលចិត្តនៅស្រុកស្រែទេ។ ចំណែកម្ដាយខ្ញុំជាកសិករធ្វើស្រែចម្ការ និងចិញ្ចឹមមើលថែកូនស្រីៗនៅស្រុកកំណើត។ ខ្ញុំមានប្ដីឈ្មោះ កែវ សាឡាត (ស្លាប់ក្នុងខែកុម្ភៈ ឆ្នាំ២០២០) កើតនៅខេត្តស្វាយរៀង។ ប្ដីរបស់ខ្ញុំមានតួនាទីជាគ្រូបង្រៀនតាំងពីជំនាន់សង្គមរាស្ត្រនិយម។ ខ្ញុំមានកូនចំនួន៤នាក់ ក្នុងនោះមានកូនស្រី២នាក់។ កូនៗរបស់ខ្ញុំបានការងារធ្វើ និងរៀបការមានគូរស្រករអស់ហើយ។ បច្ចុប្បន្នខ្ញុំរស់នៅជាមួយកូនស្រីពៅ ដែលជាគ្រូបង្រៀនផ្នែកភាសាអង់គ្លេសនៅក្នុងខេត្តព្រៃវែង។

រំពុកកាលពីកុមារភាព គឺខ្ញុំកើតក្នុងឆ្នាំ១៩៤៩ មុនប្រទេសកម្ពុជាទទួលបានឯករាជ្យជាតិពីអាណាព្យាបាលបារាំងរយៈពេល៥ឆ្នាំ។ ក្នុងអាយុ៥ឆ្នាំ គឺខ្ញុំធំដឹងក្ដី ចេះនិយាយ ចេះស្ដាប់សំដីចាស់ៗ ហេតុនេះម្ដាយខ្ញុំបានរៀបចំពិធីកោរជុកឱ្យ។ បន្ទាប់ពីនោះខ្ញុំបានឃើញ និងចងចាំថាយុវនារីក្នុងភូមិជាច្រើនបាននាំគ្នាទៅហ្វឹកហាត់ក្បួនយុទ្ធនា (សង្គ្រាម) ក្នុងវត្តភ្នៀត ដើម្បីឈានចូលទៅក្នុងក្រុមជីវពលនារីក្លាហានទាមទារឯករាជ្យជាតិមកវិញ។ យុវនារីទាំងអស់ក្នុងដៃមានកាន់កាំភ្លើងដែលធ្វើពីស្រទាប់ចេក ព្រមទាំងហាត់វាយម្ដងឆ្វេងម្ដងស្ដាំ។ ខ្ញុំ និងមិត្តភក្ដិឯទៀតក៏មានកាន់ធាងចេកម្នាក់មួយៗសម្រាប់លេងវាយគ្នាទៅវិញទៅមក។ ក្រោយពីនោះខ្ញុំត្រូវទៅសិក្សារៀនសូត្រជាធម្មតានៅសាលាបឋមសិក្សាក្នុងភូមិ។

នៅឆ្នាំ១៩៦៣ ខ្ញុំមានអាយុ១៨ឆ្នាំ ក៏ប្រឡងជាប់ថ្នាក់សិក្សាបឋមភូមិ។ ដោយហេតុខ្ញុំរៀនពូកែ និងមានការជំរុញពីគ្រូបង្រៀននៅក្នុងភូមិផង ឪពុកម្ដាយខ្ញុំក៏បញ្ជូនឱ្យមករៀនបន្តនៅសាលាអន្តរខ្ទង់ ដែលមានទាំងអនុវិទ្យាល័យ និងវិទ្យាល័យ ស្ថិតនៅទីតាំងតែមួយក្នុងក្រុងព្រៃវែង។ នាយកសាលាកាលនោះឈ្មោះ កែ សុខន ជាសាស្ត្រាចារ្យមកពីបារាំង និងអ្នកគ្រប់គ្រងវិន័យសាលាយ៉ាងតឹងរឹង ប៉ុន្តែខ្ញុំចូលចិត្តការគ្រប់គ្រងរបស់គាត់។ វិទ្យាល័យអន្តរខ្ទង់ មិនត្រឹមតែបង្រៀនអក្សរ តួលេខនោះទេ គឺថែមទាំងបង្រៀនខ្ញុំឱ្យចេះពីវិធីលក់ដូរ តួយ៉ាងដូចការដាំដំណាំក្នុងបរិវេណសាលា រួចយកទៅជួញដូរ និងការងារហត្ថកម្មផ្នែកមេផ្ទះទៀតផង។

ប្រហែលជាឆ្នាំ១៩៦៥ លោក ទីវ អុល បានផ្លាស់មកគ្រប់គ្រងវិទ្យាល័យអន្តរខ្ទង់ ចាប់ពីពេលនោះមកសិស្សានុសិស្សរួមទាំងខ្ញុំចាប់ផ្ដើមមិនពេញចិត្តចំពោះកំណែទម្រង់ការអប់រំ និងការគ្រប់គ្រងរបស់គាត់។ ជាបន្តបន្ទាប់សិស្សានុសិស្សចេះតែបាត់ចេញពីសាលា និងឈប់រៀនដោយគ្មានមូលហេតុក្រោយពីបានទៅហាត់រៀនសិល្បៈនៅផ្ទះគាត់។

នៅចុងឆ្នាំ១៩៦៦ របបដឹកនាំដោយសម្ដេចព្រះ នរោត្តម សីហនុ បានចូលមកចាប់ខ្លួនគ្រូបង្រៀនភាសាខ្មែរម្នាក់នៅវិទ្យាល័យអន្តរខ្ទង់ ដោយជាប់ចោទថាជាចលនាខ្មែរក្រហម។ ខ្ញុំមិនបានដឹងរឿងចាប់ខ្លួនគ្រូនេះឡើយ។ ឪពុកខ្ញុំឃើញភាពមិនប្រក្រតីនៅក្នុងក្រុងព្រៃវែង ក៏សុំផ្លាស់ប្ដូរខ្ញុំឱ្យទៅរៀននៅខេត្តស្វាយរៀងវិញ។ នៅទីរួមខេត្តស្វាយរៀងខ្ញុំត្រូវមកស្នាក់នៅជាមួយឪពុកមារបស់ខ្ញុំ និងមួយទៀតងាយស្រួលឱ្យខ្ញុំជួយមើលប្អូនៗជីដូនមួយដែលនៅតូចៗ។

នៅឆ្នាំ១៩៦៩ ខ្ញុំប្រឡងជាប់ច្បាប់គ្រូ ហេតុនេះត្រូវឡើងមករៀននៅក្រុងភ្នំពេញ។ នៅខែវិច្ឆិកាឆ្នាំដដែល ឪពុកមារបស់ខ្ញុំបានលើកខ្ញុំឱ្យរៀបការជាមួយប្ដីឈ្មោះ កែវ សា ឡាត ដែលជាគ្រូបង្រៀននៅពាមរក៍។ ក្រោយពីរៀបការហើយ ប្ដីខ្ញុំត្រូវទៅបង្រៀនវិញ ចំណែកខ្ញុំក៏ឡើងមកភ្នំពេញរៀនច្បាប់គ្រូបន្ត។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំធ្វើដំណើរដោយថ្មើរជើងពីម្ដុំផ្សារដេប៉ូទៅរៀននៅសាលាជាតិអប់រំក្បែរវិមានឯករាជ្យដូចសព្វមួយដង ប៉ុន្តែមិនបានដឹងថាមានការធ្វើរដ្ឋប្រហារអ្វីឡើយ។ ដល់ពេលខ្ញុំត្រឡប់មកដល់ផ្ទះវិញ បើកវិទ្យុស្ដាប់ក៏ស្រាប់តែដឹងដំណឹងថា លោកសេនាប្រមុខ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ចេញពី

ដំណែង។ បន្ទាប់មកប្រទេសក៏ត្រូវផ្លាស់ប្តូររបបថ្មីទៅជារបបសាធារណរដ្ឋខ្មែរ។ ដល់ខែមេសា ឆ្នាំ១៩៧០ សាលារៀនកងតូច ខ្ញុំក៏ត្រូវទៅលេងឪពុកម្តាយខ្ញុំ និងប្តីខ្ញុំនៅស្រុកកំណើត។ ខ្ញុំមកដល់ស្រុក ទើបដឹងថាមានកងទ័ពរំដោះចូលមកគ្រប់គ្រងតាមស្រុកភូមិមួយចំនួន។ ផ្ទះរបស់ខ្ញុំក៏ត្រូវកងទ័ពរំដោះសុំស្នាក់នៅផ្នែកខាងក្រោម។ កងទ័ពរំដោះម្នាក់ៗមានអាកប្បកិរិយាសមរម្យ និងមិនប៉ះពាល់សម្ភារផ្ទះខ្ញុំ សូម្បីតែម្ជុលមួយគ្រាប់។ ដល់មួយខែក្រោយមកទៀតក៏ឃើញមានទាហានវៀតណាម (មិនដឹងថាវៀតកុង ឬ ធីវគី) ចូលមកស្នាក់នៅក្នុងភូមិម្តងខណៈកងទ័ពខ្មែររំដោះចេញផុតទៅហើយ។ កងទ័ពវៀតណាមទាំងនោះ មានអាកប្បកិរិយាមិនសមរម្យថែមទាំងបំពារបំពានលើកូនក្រមុំអ្នកភូមិជាច្រើន។

ចាប់ពីខែមិថុនា ឆ្នាំ១៩៧០ គឺចាប់ផ្តើមឃើញមានការចាប់ខ្លួនគ្រូបង្រៀន និងអ្នកមានចំណេះដឹងដឹកតាមម៉ូតូយកទៅមួយៗ និងមិនឃើញត្រឡប់មកវិញ។ នៅពេលនោះ អ្នកភូមិមានភាពស្រពេចស្រពិល និងមិនអាចជឿជាក់លើគ្នាទៀតបានឡើយ។ ប្តីប្រពន្ធរបស់ខ្ញុំត្រូវមេភូមិចោទថាបក្ខពួកទាហានលន់ នល់ និងត្រូវបានឆែកឆេរផ្ទះ និងសម្ភារជាច្រើនសារ។ ហេតុនេះខ្ញុំនិងប្តីត្រូវរកវិធីសាស្ត្រចាកចេញពីភូមិជាប្រញាប់ ទោះបីរបបសាធារណរដ្ឋបិទច្រកចេញចូលក៏ដោយ។ ខែសីហា ឆ្នាំ១៩៧០ ទើបប្តីប្រពន្ធខ្ញុំអាចលួចចេញពីភូមិឆ្ពោះទៅកាន់ទីក្រុងភ្នំពេញបានដោយជោគជ័យ។

នៅចន្លោះពីឆ្នាំ១៩៧១ ដល់១៩៧៣ ខ្ញុំចេញទៅបង្រៀននៅវិទ្យាល័យកំពង់ត្របែក និងវិទ្យាល័យពាមរក៍ ចំណែកប្តីរបស់ខ្ញុំត្រូវចូលធ្វើជាកុម្ម៉ង់ដូរប្រចាំខេត្តព្រៃវែង។ កុម្ម៉ង់ដូរនៅសម័យនោះ គឺត្រូវបែកវេនគ្នាយាមសាលារៀន ព្រោះស្ថានភាពស្រុកទេសលែងមានសុវត្ថិភាព ដោយសារការវាយប្រយុទ្ធគ្នាចុះឡើង និងការទម្លាក់គ្រាប់បែក។ នៅពេលនោះគ្រាប់បែកបានធ្លាក់ចំផ្សារកំពង់ត្របែក និងបណ្តាលឱ្យប្រជាជនស្លាប់និងរងរបួសជាច្រើន។ ទីតាំងកំពង់ត្របែកក្លាយជាទីលានប្រយុទ្ធស្លាប់រស់រវាងកងទ័ពរំដោះ និងទាហាន លន់ នល់។ ហេតុនេះខ្ញុំក៏ផ្លាស់មកបង្រៀននៅវិទ្យាល័យពាមរក៍វិញ។ ក្នុងឆ្នាំ១៩៧៣ គ្រាប់បែកបានធ្លាក់ចំការិយាល័យវិទ្យាល័យពាមរក៍ ហេតុនេះប្តីប្រពន្ធរបស់ខ្ញុំក៏សម្រេចចិត្តរត់មកទីក្រុងភ្នំពេញ។

នៅឆ្នាំ១៩៧៤ នៅទីក្រុងភ្នំពេញ ក្រសួងចាត់តាំងឱ្យខ្ញុំទៅបង្រៀននៅសាលាជាស៊ីម សាមគ្គី។ ខ្ញុំត្រូវបង្រៀនតែមួយវេនប៉ុណ្ណោះ ព្រោះខ្វះបន្ទប់បង្រៀន។ ហេតុនេះខ្ញុំឆ្លៀតទៅលក់ដូរបន្ទែបន្ថែម ព្រោះត្រូវការប្រាក់ចំណូល សម្រាប់ទ្រទ្រង់គ្រួសារដែលមានសមាជិកច្រើន។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះលើរបប លន់ នល់។ ខ្ញុំគិតថាសង្គ្រាមបានបញ្ចប់ហើយ គ្រួសាររបស់ខ្ញុំអាចរស់នៅជុំគ្នាដោយមានសេចក្តីសុខ។ ប៉ុន្តែមិនបានប៉ុន្មានម៉ោងផង ស្រាប់តែមានប្រជាជនជាច្រើនដើរកាត់មុខខ្ទមរបស់ខ្ញុំ នៅម្តុំស្ទឹងមានជ័យ ដើម្បីធ្វើការចាកចេញពីទីក្រុងភ្នំពេញ តាមបញ្ជារបស់កងទ័ពខ្មែររំដោះ។ ការចាកចេញនេះ គឺជាគោលការណ៍របស់កម្លាំងខ្មែរក្រហម ដោយប្រើពាក្យកុហកថាបោសសម្អាតទីក្រុង។ គ្រួសាររបស់ខ្ញុំអង្គការមិនតម្រូវឱ្យចាកចេញពីក្រុងនោះទេ ដោយអង្គការគិតថាគ្រួសារខ្ញុំស្ថិតក្នុងវណ្ណៈអធន។ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំនិងបងប្អូនសាច់ញាតិខាងប្តីចំនួន ១៣នាក់ សម្រេចចិត្តចាកចេញពីទីក្រុងភ្នំពេញ ព្រោះដឹងថា គ្រូបង្រៀន និងអ្នកមានចំណេះដឹងសុទ្ធតែជាមុខសញ្ញាដែលអង្គការស្វែងរក។ ក្រុមគ្រួសារខ្ញុំត្រូវធ្វើដំណើរចេញតាមផ្លូវជាតិលេខ២ ព្រោះអង្គការមិនអនុញ្ញាតឱ្យដើរបញ្ច្រាសទិសដៅរបស់អង្គការ។ ខ្ញុំមិនដឹងពីគោលការណ៍ជម្លៀសនេះពិតប្រាកដទេ ប៉ុន្តែពេលខ្ញុំទៅចុះឈ្មោះឃើញក្នុងបញ្ជីរបស់កងទ័ព សរសេរថាត្រូវបញ្ជូនទៅតំបន់រំដោះ។ ចុះឈ្មោះរួច ខ្ញុំត្រឡប់មកយកសម្ភារនិងបង្គាប់ឱ្យប្តី និង បងប្អូនខ្ញុំកុំឱ្យប្រាប់ថាខ្លួនជាគ្រូបង្រៀន ដោយជំនួសមកវិញជាកម្មករ និងជាអ្នកធាក់ស៊ីក្លូ។ ជាសំណាងល្អ ដែលកូនៗរបស់ខ្ញុំ

ចេះ ហៅថាម៉ែពុកៗ តាមផ្លូវធ្វើដំណើរគឺកងទ័ពសុំឆែកឆេរអ៊ីវ៉ាន់ ដើម្បីស្វែងរករបស់មានតម្លៃ និងប្រកាស ស្វែងរកអ្នកដែលធ្លាប់ធ្វើការជាមន្ត្រីរដ្ឋការ អ្នកមានចំណេះដឹងឱ្យចូលទៅតម្រង់ជួរផ្សេងទៀតៗ

គ្រួសាររបស់ខ្ញុំជម្លៀសមកដល់ស្រុកត្រាំខ្នារ ម្តាយក្មេករបស់ខ្ញុំដែលមានជំងឺពោះវៀនប្រចាំកាយចាប់ផ្តើមឈឺខ្លាំង ដោយសារថ្នាំលេបប្រចាំថ្ងៃរបស់គាត់អស់ៗ ខ្ញុំគិតថា ប្រសិនបើត្រូវធ្វើដំណើរទៅមុខទៀត គ្រួសារខ្ញុំអាចនឹងស្លាប់ទាំងអស់គ្នាៗ ខ្ញុំបានទៅស្នើកងទ័ពរំដោះ ដើម្បីធ្វើដំណើរត្រឡប់មករកផ្លូវជាតិលេខ១១ ឆ្ពោះមកកាន់ខេត្តព្រៃវែង និងស្វាយរៀងវិញៗ ជាសំណាងល្អ អង្គការបានអនុញ្ញាតទើបគ្រួសារខ្ញុំដើរកាត់មកតាមស្រុកព្រៃកប្បាស ឆ្លងមកស្រុកកោះធំ រួចបន្តមករកផ្លូវជាតិលេខ១១ ត្រង់ចំណុចប្រសព្វតំបន់ដីឥដ្ឋៗ ម្តាយក្មេករបស់ខ្ញុំទប់ទល់លែងរួច ហើយក៏បានបាត់បង់ជីវិតនៅស្រុកកញ្ចៀនស្វាយៗ ក្រោយពីបញ្ចុះសពម្តាយរួច គ្រួសារខ្ញុំបានបន្តដំណើរមកអ្នកលឿងៗ មកដល់អ្នកលឿង ខ្ញុំនិងប្តី សម្រេចចិត្តថាមករស់នៅខាងម្តាយខ្ញុំស្ថិតនៅភូមិខ្សង ឃុំពពឺស ស្រុកព្រៃវែង ខេត្តព្រៃវែង ចំណែកគ្រួសារ បងថ្លៃខ្ញុំទាំងពីរក៏សម្រេចចេញទៅខាងខេត្តស្វាយរៀង ដោយភាពស្ងប់ស្ងាត់ ដូចបានដឹងជាមុនថាយើងមិនអាចជួបគ្នារហូតមកដល់បច្ចុប្បន្នៗ ខ្ញុំចំណាយពេលធ្វើដំណើររយៈពេលពីរខែ ទម្រាំមកដល់ស្រុកកំណើតៗ

ពេលមកដល់ភូមិភ្លាម កម្មាភិបាលភូមិ ចាប់ផ្តើមមកចុះឈ្មោះ និងស្វែងរករបស់របរ ដែលជាប់នឹងខ្លួនយើងរួចប្រមូលយកទៅដាក់ជារបស់រួមៗ បន្ទាប់មក អង្គការចាត់តាំងខ្ញុំឱ្យធ្វើការងារក្នុងសហករណ៍ ចំណែកប្តីខ្ញុំត្រូវទៅធ្វើការងារជីកទំនប់ប្រឡាយ និងដឹកស្បៀងទៅដាក់តាមព្រំដែនវៀតណាមៗ ខ្ញុំ និងប្តីជាមុខសញ្ញាដែលអង្គការតាមដានៗ ជារៀងរាល់យប់ ឈ្លបតែងតែមកលួចស្តាប់ប្តីប្រពន្ធខ្ញុំនិយាយគ្នារួចលើកករណីរបស់ពួកខ្ញុំទៅរាយការណ៍រាល់ពេលមានអង្គប្រជុំៗ

ប្រហែលជាពាក់កណ្តាលឆ្នាំ១៩៧៨ ក្រោយពីមានព្រឹត្តិការណ៍កងទ័ពលោក សោ ភឹម ក្បត់អង្គការបក្សមជ្ឈិម ការរស់នៅក្នុងភូមិចាប់ផ្តើមប្រែប្រួលៗ ថ្នាក់ដឹកនាំក្នុងភូមិត្រូវដកចេញ ដោយជំនួសមកវិញនៅកងទព័ភូមិភាគនិរតីចូលមកគ្រប់គ្រងៗ បន្ទាប់មកប្រធានភូមិ អនុភូមិ កម្មាភិបាលចាស់ៗក្នុងភូមិត្រូវកងទ័ពភូមិភាគនិរតីដឹកតាមរថយន្តថា «យកទៅរៀនសូត្រ»ៗ មិនយូរប៉ុន្មាន គ្រួសារខ្ញុំត្រូវអង្គការចាត់តាំង ឱ្យជម្លៀសទៅខាងតំបន់ដីខ្លាញ់ គឺខេត្តបាត់ដំបង តាមរយៈរថភ្លើងៗ

ស្ថិតនៅក្នុងតំបន់ថ្មី គឺជារឿងរ៉ាវដែលខ្ញុំមិនអាចបំភ្លេចបានពីបទពិសោធន៍រស់នៅក្នុងរបបខ្មែរក្រហមរហូតមកដល់ពេលបច្ចុប្បន្នៗ អង្គការបានប្រើប្រាស់កម្លាំងយុវជនដើម្បីប្រមូលផលជូនអង្គការៗ ពេលប្រមូលផលរួចអង្គការចាប់អ្នកកម្លាំងយុវជនពីភូមិភាគបូព៌ាយកទៅសម្លាប់ចោលៗ ព្រៃជុំវិញសហករណ៍ គឺមានសុទ្ធតែឈាមប្រឡាលពេញៗ ការរស់នៅរបស់ខ្ញុំ កាន់តែមានអារម្មណ៍ភ័យខ្លាច ព្រោះក្នុងសហករណ៍ស្ងាត់ទៅៗៗ ខ្ញុំភ័យខ្លាចមិនដឹងថ្ងៃណាដល់វេនក្រុមគ្រួសារខ្ញុំៗ

នៅដើមឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា សហការជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាម បានវាយរំដោះប្រទេសកម្ពុជាពីទិសខាងកើត និងសង្គ្រោះប្រជាជនបានជាបន្តបន្ទាប់ៗ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពបានវាយរំដោះទីក្រុងភ្នំពេញ ហើយថ្ងៃនេះបានក្លាយជាថ្ងៃប្រវត្តិសាស្ត្រនៃការរំដោះជាតិៗ រណសិរ្សនេះបានបង្កើតរបបថ្មីឈ្មោះថា «សាធារណរដ្ឋប្រជាមានិតកម្ពុជា»ៗ ប៉ុន្តែការវាយប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហម និង កងទ័ពវៀតណាម ធ្វើឱ្យខ្ញុំលែងមានអារម្មណ៍ភ័យខ្លាចទៀតហើយៗ ទំព័រជីវិតចុងក្រោយរបស់ខ្ញុំ ដែលធ្លាប់បានឆ្លងកាត់ការស្លាប់រស់កន្លងមកគឺមានតែការប្រណិប័តន៍សាសនា និងការធ្វើទានបង្រៀនដល់លោកនេននៅវត្តបុញ្ញខេត្តារាម (ហៅវត្តថ្មី)ៗ

# សុខ ងួន ៖ អតីតឈ្លបសង្កាត់

**ចាន់ ណារិទ្ធិ**

សុខ ងួន ភេទប្រុស អាយុ៦០ឆ្នាំ កើតនៅភូមិអ្នកវាំង ឃុំស្រឡៅ ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ បច្ចុប្បន្ន ងួន រស់នៅភូមិស៊ីងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ងួន មានឪពុកឈ្មោះ នៅ សួង និងម្តាយឈ្មោះ អ៊ុក យឹម (ស្លាប់ដោយសារជំងឺ)។ ងួន មានបងប្អូនចំនួន៧ នាក់ ក្នុងនោះមានប្រុសចំនួន៤ នាក់។ ងួន ជាកូនទី១នៅក្នុងគ្រួសារ។ ងួន មានប្រពន្ធឈ្មោះ ស៊ឹម ឃៀង អាយុ៥៩ឆ្នាំ សព្វថ្ងៃប្រកបមុខរបរដាំបន្លែ។ ក្រោយពីរៀបការ ងួន មានកូនចំនួន៩ នាក់ ក្នុងនោះមានកូនស្រីចំនួន៦ នាក់។



សុខ ងួន បច្ចុប្បន្នរស់នៅភូមិស៊ីងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីក្មេង ងួន រៀនបានត្រឹមថ្នាក់ទី២ នៅសាលាបឋមភូមិស្វាយមាស ឃុំលំពង់ជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ ងួន ឈប់រៀនដោយសារតែម្តាយបាននាំទៅលេងយាយតា នៅភូមិដើមពោធិស្មៀង ឃុំសណ្តែក ស្រុកបាធាយ ខេត្តកំពង់ចាម។ ងួន រស់នៅជាមួយតាយាយ បានប្រហែលមួយឆ្នាំ កងទ័ពខ្មែរក្រហមបានវាយចូលមកដល់ទីរួមខេត្តកំពង់ចាម។ នៅពេលដែលខ្មែរក្រហមចូលមកកាន់កាប់ក្នុងភូមិដំបូង គឺមិនទាន់បង្ខិតបង្ខំឱ្យប្រជាជនធ្វើការងារធ្ងន់ធ្ងរទេ គ្រាន់តែប្រាប់ឱ្យប្រជាជនខិតខំប្រឹងធ្វើស្រែប្រវាស់ដៃគ្នា ដើម្បីចែកស្រូវគ្នាហូប។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនចេញពីភូមិដើមពោធិស្មៀងឱ្យទៅរស់នៅភូមិស្វាយមាស។ បន្ទាប់មកកងទ័ពខ្មែរក្រហមបានប្រាប់ឱ្យប្រជាជនប្រមូលសម្ភាររបស់របរផ្សេងៗដាក់រួម ហើយខ្មែរក្រហមបានបង្កើតជាសហករណ៍នៅក្នុងភូមិស្វាយមាស ដើម្បីឱ្យប្រជាជនស្នាក់នៅរួមហូបរួម និងធ្វើការងាររួមគ្នា។ ខ្មែរក្រហមចាប់ផ្តើមបែងចែកឱ្យមានក្រុមកុមារ ក្រុមយុវជន យុវនារី និងក្រុមមនុស្សចាស់។ នៅពេលនោះ ងួន អាយុប្រហែល១០ឆ្នាំ ត្រូវបានខ្មែរក្រហមជ្រើសរើសឱ្យចូលធ្វើការងារនៅក្នុងកងកុមារ។ នៅក្នុងកងកុមារដែល ងួន ស្នាក់នៅមានគ្នាប្រហែល៣០នាក់។ ងួន បាននិយាយបន្តថា ពេលចូលក្នុងកងកុមារដំបូង ខ្មែរក្រហមមិនទាន់បង្ខិតបង្ខំឱ្យកុមារធ្វើការងារធ្ងន់ធ្ងរទេ គ្រាន់តែប្រាប់ឱ្យខំប្រឹងរៀន និងដើរកាប់ទន្ទ្រានខែត្រក្នុងមួយថ្ងៃឱ្យបានពីរបាច់ និងដើររើសអាចម៍គោសម្រាប់លាយបញ្ចូលគ្នាធ្វើជីដាក់ស្រែ។ ចំណែកឪពុក ងួន ត្រូវបានខ្មែរក្រហមប្រើឱ្យធ្វើជាជាងធុង និងម្តាយត្រូវបានខ្មែរក្រហមប្រើឱ្យធ្វើការងារនៅក្នុងកងចល័ត។

នៅឆ្នាំ១៩៧៧ ងួន ត្រូវបានខ្មែរក្រហមជ្រើសរើសឱ្យចូលធ្វើការងារនៅក្នុងកងចល័ត។ ការងារដែល ងួន ត្រូវធ្វើជាប្រចាំថ្ងៃគឺត្រូវរែកដី ជីកប្រឡាយ

ដើម្បីយកទឹកដាក់ស្រែ។ ក្នុងមួយថ្ងៃ ធួន ត្រូវធ្វើការងារចំនួន៨ម៉ោង។ ម៉ោង៦កន្លះ ធួន ត្រូវធ្វើដំណើរចេញពីសហករណ៍ទៅរណ្ដៅដី ម៉ោង៧:០០នាទីចាប់ផ្ដើមធ្វើការងារ ម៉ោង១១ថ្ងៃត្រង់ទើបឈប់សម្រាកហូបបាយបុកហូបបបរ។ ម៉ោង១រសៀល ធួន ចុះធ្វើការងារបន្តរហូតដល់ម៉ោង៥ល្ងាច ទើបឈប់សម្រាកត្រឡប់មកសហករណ៍វិញ។

នៅដើមឆ្នាំ១៩៧៨ ធួន និងយុវជន៩នាក់ទៀតត្រូវបានខ្មែរក្រហមជ្រើសរើសឱ្យចូលធ្វើជាឈ្លបសង្កាត់ ដែលគ្រប់គ្រងដោយឈ្មោះ លួត។ ការងារដែល ធួន ត្រូវធ្វើគឺត្រូវដើរមើលចានឆ្នាំងដែលប្រជាជនបានលាក់ទុក និងជួយធ្វើការងារនៅក្នុងឃុំសង្កាត់។ ធួន ធ្វើឈ្លបសង្កាត់បានរយៈពេលប្រហែលបីខែ ក៏ត្រូវឪពុកម្ដាយ នាំយកទៅលេងដីដូននៅស្រុកចម្ការលើ ខេត្តកំពង់ចាម។ នៅពាក់កណ្ដាលឆ្នាំ១៩៧៨ ខ្មែរក្រហមចាប់ផ្ដើមស្រាវជ្រាវប្រវត្តិរូបអ្នកភូមិយកទៅសម្លាប់។ ទីតាំងដែលខ្មែរក្រហមតែងតែយកប្រជាជនទៅសម្លាប់គឺស្ថិតនៅខាងលិចភូមិត្រពាំងវែង គឺទីតាំងវត្តកណ្ដាល។ ធួន រស់នៅស្រុកចម្ការលើបានប្រហែល២ខែ កងទ័ពវៀតណាមវាយចូលមករំដោះ។ នៅពេលនោះ ធួន បានឃើញកងទ័ពខ្មែរក្រហមជាច្រើនដែលដឹកនាំដោយ កែ ពក និងតា អឿន បានប្រមូលកម្លាំងដើម្បីទៅឈប់ទល់ជាមួយកងទ័ពវៀតណាមនៅស្រុកចម្ការលើ។ ដោយកងទ័ពវៀតណាមមានកម្លាំងច្រើនមិនអាចទប់ទល់បាន កែ ពក បានបញ្ជាឱ្យកងទ័ពទាំងអស់ដកថយ។ ពេលនោះ ធួន និងកងទ័ព កែ ពក ទាំងអស់បានរត់ចេញពីស្រុកចម្ការលើ សំដៅទៅចាក់ល្ហុងប្រឹសមាស រួចបានបន្តដំណើររហូតទៅដល់ព្រំដែនកម្ពុជា- ឡាវ។ នៅឆ្នាំ១៩៨៤ ធួន បានស្ម័គ្រចិត្តចូលរួមជាមួយកងទ័ព កែ ពក ហើយបានរស់ជាមួយកងទ័ពនៅព្រំដែនឡាវបានរយៈពេល៥ឆ្នាំ ដោយប្រកបរបរធ្វើស្រែចិញ្ចឹមជីវិត។ នៅពាក់កណ្ដាលឆ្នាំ ១៩៨៤ កែ ពក បានបញ្ជាឱ្យកងទ័ពទាំងអស់ផ្លាស់ចេញពីព្រំដែនឡាវ ដើម្បីទៅចាប់ដៃជាមួយកងពលតាម៉ុក ដែលមានទីតាំងនៅលើភ្នំដងរែក រួចរួមបញ្ចូលកម្លាំងគ្នាបង្កើតបានជាកងពល៧៨៥ ដើម្បីទៅវាយជាមួយកងទ័ពវៀតណាមនៅស្រុកអន្លង់វែង។

បន្ទាប់ពីវាយជាមួយកងទ័ពវៀតណាម តាម៉ុក បានបញ្ជាឱ្យកងទ័ពទាំងអស់ដកថយចេញពីភ្នំដងរែក ដោយធ្វើដំណើរចុះមកខាងកើតខេត្តកំពង់ឆ្នាំងរហូតមកដល់ស្រុកកំពង់លែង ហើយបានបោះទីតាំង និងឈរជើងនៅទីនោះ។ ធួន រស់នៅស្រុកកំពង់លែងបានរយៈពេល៣ឆ្នាំ តាម៉ុក បានរៀបចំកម្លាំងឡើងទៅវាយនៅអន្លង់វែងម្ដងទៀត រហូតទទួលបានជ័យជម្នះ និងបោះទីតាំងឈរជើងនៅទីនោះ។ បន្ទាប់ពីទទួលបានជ័យជម្នះ ធួន និងកងទ័ពមួយវរសេនាធំ ដែលមានគ្នាប្រហែល១០០នាក់ ដែលគ្រប់គ្រងដោយឈ្មោះ ផន ត្រូវបាន តាម៉ុក បញ្ជូនចេញពីអន្លង់វែងមកជំរំសាយខេដែលស្ថិតក្នុងដីថៃ។ រស់នៅជំរំសាយខេបានប្រហែល១ឆ្នាំ ធួន បានរៀបការជាមួយប្រពន្ធឈ្មោះ ស៊ឹម យៀង ហើយបានឈប់ពីកងវរសេនាធំ ចេញមកធ្វើការងារនៅស្រុកបាណន់ ខេត្តបាត់ដំបង។ ធួន រស់នៅស្រុកបាណន់បានប្រហែល១ខែ អង្គការចាប់ផ្ដើមមានការជ្រើសរើសកម្លាំងដើម្បីបង្កើតអង្គភាពថ្មី ដែលគ្រប់គ្រងដោយឈ្មោះ តាឃឹម។ បន្ទាប់មកទៀត តាឃឹម បានជ្រើសរើស ធួន ធ្វើជាប្រធានក្រុមកងទ័ពពិសេស ដែលមានគ្នា១២នាក់ ដើម្បីទៅឈរជើងនៅស្រុកគាស់ក្រឡ។

នៅចុងឆ្នាំ១៩៩៣ តាឃឹម បានបញ្ជាឱ្យកងទ័ពពិសេស និងកងទ័ពគឹម ពៅ ដែលមានគ្នាប្រហែល៥០នាក់ត្រូវបានផ្លាស់ចេញពីគាស់ក្រឡ បញ្ជូនឱ្យមករស់នៅស្រុកវាលវែង ខេត្តពោធិ៍សាត់។ បន្ទាប់ពីសាងសង់ផ្ទះហើយ និងរស់នៅបានមួយរយៈ ធួន និងកងទ័ពគឹម ពៅ ប្រហែល៤០នាក់ត្រូវបានបញ្ជូនឱ្យទៅធ្វើការងារនៅក្នុងខេត្តកោះកុង ដោយធ្វើដំណើតាមត្រាក់ទ័រចេញពីស្រុកវាលវែងចុះទៅអូរសោម។ បន្ទាប់ពីបញ្ចប់ការងារនៅក្នុងខេត្តកោះកុង ធួន និងកងទ័ពគឹម ពៅ ទាំងអស់បានចុះមករស់នៅស្រុកវាលវែងវិញ ហើយបានបន្តរស់នៅរហូតដល់សមាហរណកម្មក្នុងឆ្នាំ១៩៩៦។

# អែម សេង ៖ ខ្ញុំជឿលើការមិនប្រមាថ

**លី សុខឃាង**

សេង បាននិយាយអំពីរឿងរ៉ាវផ្ទាល់ខ្លួនជាមួយចលនាតស៊ូខ្មែរក្រហមថា៖ «នៅក្នុងឆ្នាំ១៩៧២ ខ្ញុំមានអាយុ១៦ឆ្នាំ។ ខ្ញុំបានចូលព្រៃម៉ាគី តបតាមការអំពាវនាវរបស់សម្តេចព្រះ នរោត្តម សីហនុ ដែលត្រូវបាន លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់នាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ខ្ញុំបានចូលបម្រើការនៅក្នុងមន្ទីររបស់ខេត្ត រយៈពេលមួយឬពីរឆ្នាំ។ បន្ទាប់មក ខ្ញុំក៏ទទួលបានការបំពាក់អាវុធ និងចូលសមរភូមិបណ្តើរៗ។



អែម សេង (រូបខាងឆ្វេង)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងឆ្នាំ១៩៧៥ តំបន់ក្រចេះត្រូវបានរំដោះ ហើយមន្ទីរអង្គភាពផ្សេងៗត្រូវបានរៀបចំឡើង។ អង្គភាពរបស់ខ្ញុំបានទទួលភារកិច្ចប្រចាំការនៅក្នុងតំបន់ស្វយ័តក្រចេះ។ នៅចន្លោះឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧ ការប៉ះទង្គិចជាមួយវៀតណាមក៏ចាប់ផ្តើមកើតឡើង។ អង្គភាពជាច្រើនត្រូវបានបញ្ជូនទៅព្រំដែន ហើយកងពល៤១៧ ដែលជាអង្គភាពរបស់ខ្ញុំ ក៏បានឈរជើងនៅតាមផ្លូវលេខ១៣ ដែលជាផ្លូវឆ្ពោះទៅព្រំដែនវៀតណាម។

នៅក្រោយឆ្នាំ១៩៧៩ ខ្ញុំបានបន្តបម្រើការជាកងទ័ពខ្មែរក្រហមនៅតាមព្រំដែន និងនៅតាមខេត្តមួយចំនួនដែរ។ នៅគ្រប់ទីកន្លែងដែលខ្ញុំបានចូលដល់ និងធ្វើសកម្មភាព ខ្ញុំតែងតែចូលជម្រាបអ្នកស្រុកនៅតាមផ្ទះរបស់គាត់ជាមុនថា៖ «អ៊ំពូមីង សូមសុខ សូមរស់ផងៗ។ ពេលគាត់ឃើញម្រាមដៃដប់ ក៏អត់ធ្វើអីយើងកើតទេ»។ ខ្ញុំបានដឹងខ្លះថា មេអង្គភាពមួយចំនួនក៏មានទំនាក់ទំនង និងសហការជាមួយឈ្លបខាងរដ្ឋាភិបាលដែរ ដើម្បីចេញចូលភូមិឋានរបស់អ្នកស្រុក។ ឧទាហរណ៍ ក្រុមរបស់ខ្ញុំផ្ទាល់ប្រាប់ជាមុនថាត្រូវចូលភូមិនេះ នៅក្នុងយប់នេះ។ ការធ្វើបែបនេះអាចទប់ស្កាត់ការភ្ញាក់ផ្អើល ដែលនាំឱ្យប៉ះទង្គិចគ្នាជាយថាហេតុផ្នែកប្រដាប់អាវុធ និងអាចប៉ះពាល់ដល់អាយុជីវិតប្រជាជននៅក្នុងភូមិ។

នៅក្នុងអំឡុងពេលនោះ ខ្ញុំនៅចងចាំបានថា ខ្ញុំធ្លាប់បានស្តាប់វិទ្យុ ដែលចាក់ផ្សាយកម្មវិធី «សំឡេងអំពាវនាវមាតុភូមិ»។ ខ្ញុំស្រក់ទឹកភ្នែក ដោយសារតែសំឡេងដ្លិស្នែង និងទ្រយ៉ាងលន្ទង់លន្លោចរបស់កម្មវិធីវិទ្យុនេះ។ ខ្លឹមសារនៃការអំពាវនាវនេះនាំឱ្យខ្ញុំនឹករឭកយ៉ាងខ្លាំងដល់ឪពុកម្តាយ ខណៈដែលការរស់នៅក្នុងព្រៃជួបប្រទះនូវការលំបាក ទាក់ទងនឹង

ការហូបចុកនិងការស្នាក់នៅ។ ការប្រយុទ្ធគ្នានៅលើសមរភូមិបានបន្តមិនចេះចប់ មិនចេះហើយសោះ។

ប៉ុន្តែខ្ញុំសម្រេចចិត្តមិនដាច់សោះ។ ខ្ញុំនិយាយមួយម៉ាត់ថា ខ្ញុំអត់ហ៊ានត្រឡប់ចូលជាមួយរដ្ឋាភិបាលទេនៅពេលនោះ ដោយសារតែមានការឃោសនាថាប្រាកដជាស្លាប់។ ខ្ញុំហាក់ដូចជាអត់មើលឃើញពន្លឺណាមួយ ដែលថាខ្ញុំនឹងអាចរស់រានមានជីវិតទេ។

ដូច្នេះហើយ ខ្ញុំត្រូវតែបន្តបម្រើក្នុងជួរកងទ័ពខ្មែរក្រហម នៅក្នុងកងពល៤១៧ ដែលផ្តោតលើសមរភូមិទាំងឡាយនៅក្នុងខេត្តកំពង់ចាម ព្រមទាំងស្រុកបារាយ និងស្រុកសន្ទុកនៃខេត្តកំពង់ធំ។ កងកម្លាំងខ្មែរក្រហមបានបែងចែកកម្លាំងនៅតាមគោលដៅ ដើម្បីធ្វើសកម្មភាពសង្គ្រាមឈ្លបនៅតាមស្រុក និងឃុំ។ ឧទាហរណ៍ កងកម្លាំងខ្មែរក្រហម ១៥នាក់ ឬ២០នាក់ធ្វើសកម្មភាពនៅក្នុងស្រុកមួយ ឬឃុំចំនួនពីរនៃស្រុកមួយជាដើម។

យុទ្ធសាស្ត្រសង្គ្រាមឈ្លបនេះទាមទារនូវការប្រយ័ត្នប្រយែងខ្ពស់ លាក់ការណ៍ ចល័តយ៉ាងរហ័ស និងមិនត្រូវបន្សល់ដាន ដែលនាំឱ្យមានការតាមប្រមាញ់ក្រុមតូចៗរបស់យើងឡើយ។ ទាក់ទងនឹងរបៀបនៃការដើរឆ្លងកាត់ភូមិសាស្ត្រណាមួយ សមាជិកក្រុមចំនួន ៧ ឬ ១៥នាក់ ត្រូវដោះស្បែកជើង ដើម្បីបន្លំដានជើង ដែលមានសណ្ឋានដូចដានជើងអ្នកស្រុកដែរ នៅពេលដែលយើងដើរឆ្លងកាត់ផ្លូវដី។ បន្ទាប់មក យើងអាចពាក់ស្បែកជើងវិញ។ ម្យ៉ាងទៀត យើងតែងតែប្រើស្លឹកចេកឬវល្លិ៍ ដើម្បីលុបដានជើងរបស់យើងនៅលើផ្លូវដីនោះ នៅពេលដែលយើងធ្វើដំណើរនៅក្បែរៗភូមិ។ ចំណែកឯការឆ្លងកាត់អូរវិញ ក្រុមរបស់យើងត្រូវដើរតាមបណ្តោយអូរ ដោយលុយទឹកត្រឹមជង្គង់។ យើងត្រូវដើរឱ្យបានចម្ងាយ១០០ម៉ែត្រ ទៅ២០០ម៉ែត្រសិន មុននឹងគេចឡើងគោកវិញ។ ក្រុមតូចៗរបស់ខ្ញុំស្ថិតនៅចម្ងាយប្រមាណជា៣០០ម៉ែត្រប៉ុណ្ណោះពីភូមិអ្នកស្រុក ដែលខ្ញុំអាចស្តាប់ឮមាន់រងាវ និងទទួលព័ត៌មានពីប្រជាជនជាប្រចាំ។

ក្រុមនីមួយៗត្រូវម្ចាស់ការដោយខ្លួនឯងអំពីស្បៀងអាហារ ថ្នាំពេទ្យ និងសេដ្ឋកិច្ចជាដើម។ ក្រុមខ្ញុំក៏បានទទួលលុយខ្លះ និងមាសសន្លឹកសញ្ញារូបចាប ដែលមានទម្ងន់៤ជីក្នុងមួយសន្លឹក ដើម្បីទិញស្បៀងអាហារ។ ប៉ុន្តែ បើខ្វះខាត យើងត្រូវចេះសុំអ្នកស្រុកបន្ថែម។ ជាក់ស្តែង ខ្ញុំបានលើកដៃសំពះសុំប្រជាជននៅតាមភូមិស្រុកផ្សេងៗ។ ខ្ញុំមិនគាំទ្រទេ ដែលអ្នកខ្លះឬក្រុមប្រដាប់អាវុធខ្លះមានគំនិតឆក់ប្លន់ប្រជាជន។ ខ្ញុំតែងតែហាមប្រាមដាច់ខាតនៅក្នុងក្រុមតូចៗរបស់ខ្ញុំ ដោយសារ «ខ្ញុំទឹកឃើញ ម៉ែគេ ម៉ែខ្ញុំ ទៅក្លួងយកមាន់ ទៅក្លួងយកគោយ៉ាងម៉េច»។

ខ្ញុំនៅចងចាំរឿងរ៉ាវមួយមិនភ្លេចសោះ។ បើទោះជាខ្ញុំមានតួនាទីជាប្រធានកងតូចក៏ដោយ ក៏ខ្ញុំហ៊ានប្រកែកគ្នាយ៉ាងខ្លាំងជាមួយ រ៉ាន់ ដែលមានតួនាទីជាប្រធានកងធំ។ យើងបានឈ្លោះគ្នារហូតដល់ចង់បាញ់គ្នាឯង។

«កាលណោះ ទៅវាយខ្លាំង ដល់ពេលអត់បានវាយខ្លាំង ក៏ត្រឡប់មកវិញ កាត់ព្រៃសាគូ នៅស្រុកបារាយ បានប៉ះរទេះគោអ្នកស្រុក ដែលគេកំពុងតាមប្រមាញ់ពីនោះមក ហើយនាំគ្នារត់កាត់ទឹក កាត់ស្រូវ



ផ្លូវពីខេត្តឧត្តរមានជ័យទៅស្រុកអន្លង់វែង ឆ្នាំ១៩៨៥។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ហើយគ្នាខ្ញុំមានប្រាំពីរនាក់ រួចក៏ប៉ះរទេះគោពីរគ្រឿង ដោយមានឈ្មោះ ខ្មោច អាវ៉ាន់ ចឹងបានវាអាយុខ្ញី តាមមើល... វាថាចាប់រទេះគោ យកគោទៅស៊ី ហើយបាញ់ម្ចាស់ចោល។ ហើយខ្ញុំថា យី...! បើហ្អែងបាញ់ អញបាញ់ហ្អែងឥឡូវ..! ហ្អែងធ្វើចឹង គាត់ដឹងអី។ គាត់បររទេះទៅផ្ទះគាត់តើ។ បើហ្អែងហ៊ានធ្វើ អញបាញ់។ បើហ្អែងហ៊ានទៅចាប់ អញបាញ់។ ខ្ញុំឈ្លោះគ្នា ដោយគេកងធំ ខ្ញុំកងតូច។ ខ្ញុំក្លាហានជាងអ្នកឯង តែហ៊ាន ខ្ញុំដាក់មែន។ ខ្ញុំអត់ខ្លាចទេ តែខ្ញុំថាម៉េចគឺចឹង ហើយ។ យើងទៅបាញ់ធ្វើអី មនុស្សមានដឹងអី។ គេបាញ់យើងឯណោះមិនគិត។ គាត់មិនមែនទៅបានរាយការណ៍អីគាត់។ គាត់បើកដឹកខុស ដឹកគ្រឿងអីរបស់គាត់។ ខ្ញុំឈ្លោះគ្នា។ ខ្ញុំនិយាយពីប្រវត្តិរបស់ខ្ញុំរឿងពិត។ ក្រោយមកបានរយៈពេលតែពីរខែ គេបាញ់វាដួលស្លាប់បាត់ទៅ ឈ្មោះ អាវ៉ាន់។ អង្គុយជុំខ្ញុំចឹង អង្គុយនៅនឹងកន្លែង ក្រោយត្រឡប់មកពីវាយមួយកន្លែងដែលអង្គុយជជែកកោកកាក។ ហើយខ្ញុំអង្គុយឱ្យមុខអញ្ចេះ ហើយគេមិនបាញ់ខ្ញុំ ទៅបាញ់ត្រូវវាមកពីនោះ។...ចឹងបានខ្ញុំថា ប្រមាថគេមិនបានទេក្នុងសង្គ្រាម»។

តែទោះជាយ៉ាងណាក៏ដោយ នៅពេលដែលខ្ញុំបានជាន់មីនដាច់ជើងនៅតាមបណ្ដោយព្រំដែនថៃនៅក្នុងឆ្នាំ១៩៨៨ សេចក្ដីសង្ឃឹមផ្សេងៗក៏បានរលាយបាត់បង់ ហើយខ្ញុំលែងទៅណារួចទៀត។ ខ្ញុំគិតថា៖ «ខ្ញុំខុសដែរ ណាក្មួយ បានខ្ញុំដាច់ជើង ខុសត្រង់ថា ខ្ញុំធ្វើមីនដាក់យកគេ បានវាដាច់ជើងខ្លួនឯងតាមមើលទំ វាបាបណា។ ខ្ញុំនិយាយអំពីការជឿលើធម៌ព្រះវិញចុះ»។



ផ្លូវពីខេត្តឧត្តរមានជ័យទៅស្រុកអន្លង់វែង ឆ្នាំ១៩៨៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាម ហ៊ិ

## មេបញ្ជាការរងកងទ័ពជើងគោក បានរួមចំណែកអនុវត្ត នយោបាយឈ្នះឈ្នះ និងការងារប្រវត្តិសាស្ត្រយោធា

អេង សុខម៉េង



ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាម ហ៊ិ មេបញ្ជាការរងកងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាម ហ៊ិ មេបញ្ជាការរងកងទ័ពជើងគោក កាលនៅជាអនុបញ្ជាការយោធាខេត្តតាកែវ និងជាមេបញ្ជាការយោធាប្រចាំទិសត្រពាំងអណ្ដើក ស្រុកត្រាំកក់ បានប្រថុយជីវិតឡើងភ្នំឱរ៉ាល់អនុវត្តនយោបាយឈ្នះ ឈ្នះ ដោយទៅបញ្ចុះបញ្ចូលមេទ័ពខ្មែរក្រហមនៃកងពលលេខ១១៨ ឱ្យបញ្ចប់ការតស៊ូ និងចូលរួមជីវភាពនយោបាយជាមួយរដ្ឋាភិបាលកម្ពុជា។

អំឡុងឆ្នាំ១៩៩៦ ឯកឧត្តម បានទទួលសំបុត្រមួយច្បាប់ពី ឯកឧត្តម ប៉ុល សារឿន កាលនោះជាអគ្គបញ្ជាការរងកងយោធពលខេមរភូមិន្ទ ទទួលបន្ទុកសមរភូមិទិសនិរតី (បច្ចុប្បន្នឯកឧត្តមកិត្តិឧទ្ទេសបណ្ឌិត ប៉ុល សារឿន ជាឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើឧបនាយករដ្ឋមន្ត្រី)។ ខ្លឹមសារសំបុត្រនោះ ឯកឧត្តម ស៊ាម ហ៊ិ ត្រូវធ្វើប្រតិបត្តិការពិសេសមួយដើម្បីអនុវត្តនយោបាយឈ្នះ ឈ្នះ ហើយត្រូវនាំសំបុត្រទៅកាន់ឯកឧត្តម កែវ ពង្ស ជាមេបញ្ជាការកងពលលេខ១១៨



ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាម ហ៊ា មេបញ្ជាការរងកងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

"ឱរ៉ាល់-កំពង់ស្ពឺ" (បច្ចុប្បន្ន ឯកឧត្តម កែវ ពង្ស ជារដ្ឋលេខាធិការក្រសួងការពារជាតិ) ហើយប្រសិនបើកងទ័ពខ្មែរក្រហមយល់ព្រមដាក់អាវុធចុះចូលជាមួយរដ្ឋាភិបាល រាជរដ្ឋាភិបាលនឹងរក្សាសុវត្ថិភាព, អាយុជីវិត, ទ្រព្យសម្បត្តិ និងមុខតំណែង [ក្នុងរាជរដ្ឋាភិបាល]។ កងយោធពលខេមរភូមិន្ទ បានអនុវត្តកាតព្វកិច្ចដ៏សំខាន់ក្នុងការជួយកសាងប្រទេសជាតិឡើងវិញ។

កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៦ សម្តេចនាយករដ្ឋមន្ត្រីទី២ បានអញ្ជើញទៅកាន់តំបន់ប៉ៃលិនជាលើកដំបូង។ សម្តេច បញ្ជាក់ថា "ការចុះចូលជាមួយរាជរដ្ឋាភិបាលនេះមិនមែនជាការចុះចាញ់ ឬការសារភាពនោះទេ ប៉ុន្តែជាកាតព្វកិច្ចកូនខ្មែរដែលត្រូវខិតខំបញ្ចប់ជម្លោះដែលអ្នកជំនាន់មុនបង្កើត ហើយអ្នកជំនាន់ក្រោយត្រូវខិតខំរំលត់។ យោងតាមនយោបាយ ឈ្នះ ឈ្នះ បានបញ្ជាក់យ៉ាងច្បាស់ថា ការបញ្ចប់ជម្លោះប្រដាប់អាវុធគឺមិនអាចធ្វើទៅបាននោះទេ លុះត្រាតែមានការជួបពិភាក្សាគ្នារវាងភាគីទាំងពីរគឺរវាងខ្មែរ និងខ្មែរដើម្បីស្វែងរកដំណោះស្រាយដោយសន្តិវិធី។ ប្រវត្តិសាស្ត្របានបង្ហាញថា កងយោធពលខេមរភូមិន្ទមានកាតព្វកិច្ចយ៉ាងសំខាន់ក្នុងការឈានទៅដល់ការបញ្ចប់សង្គ្រាមក្រោមការដឹកនាំ ដោយសម្តេចតេជោ ហ៊ុន សែន និងបានឈានទៅដល់ការបញ្ចប់ទាំងស្រុងនៃរបបខ្មែរក្រហមនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាម ហ៊ា មេបញ្ជាការរងកងទ័ពជើងគោកបានឡើងទៅភ្នំឱរ៉ាល់ដើម្បីទៅជួបផ្ទាល់ជាមួយ ឯកឧត្តម កែវ ពង្ស ដែលពេលនោះជាមេបញ្ជាការកងពលលេខ១៨។ ឯកឧត្តមបញ្ជាក់ថាការឡើងទៅភ្នំឱរ៉ាល់នៅគ្រានោះ "ខ្ញុំត្រូវប្រថុយគ្រោះថ្នាក់ និងហានិភ័យដែលអាចកើតមានដល់អាយុជីវិត ព្រោះជាតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហម"។ ទោះបីជាយ៉ាងណាក៏ដោយនៅពេលនោះ ក្នុងជួរមេដឹកនាំខ្មែរក្រហមកំពុងមានបញ្ហាផ្ទៃក្នុងមួយចំនួន និងនាំឱ្យការសន្ទនារវាងឯកឧត្តម ស៊ាម ហ៊ា និង ឯកឧត្តម កែវ ពង្ស ទទួលបានជោគជ័យរហូតការអនុវត្ត នយោបាយ ឈ្នះ ឈ្នះ ប្រព្រឹត្តទៅបានយ៉ាងរលូន។ ឯកឧត្តម លើកឡើងបន្តថា ការជួបចរចាដំបូងបានទទួលលទ្ធផលល្អទើប



ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាម ហ៊ា មេបញ្ជាការរងកងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ ទទួលឯកសារពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឈានដល់ជំនួបជាមួយថ្នាក់ដឹកនាំដទៃៗទៀតរហូតបានរួមចំណែកជួយដល់ការអនុវត្ត នយោបាយ ឈ្នះ ឈ្នះ ហើយ ឈានដល់ការផ្សះផ្សាជាតិរវាងកងកម្លាំងខ្មែរក្រហម ជាមួយកងទ័ពនៃកងយោធពលខេមរភូមិន្ទ នាំមកនូវសន្តិភាពពេញលេញដល់ប្រជាជនកម្ពុជា។ ជាបន្តបន្ទាប់នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ ឯកឧត្តម បានចូលរួមចំណែកជាច្រើនក្នុងការអនុវត្ត នយោបាយ ឈ្នះ ឈ្នះ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដែលបានបញ្ចប់ជាស្ថាពរសង្គ្រាមនៅកម្ពុជា ហើយសម្រេចបាននូវការបង្រួបបង្រួមជាតិ ឯកភាពជាតិ និងនាំមកជូនជាតិ និងប្រជាជនកម្ពុជា នូវសុខសន្តិភាពពេញផ្ទៃប្រទេសនៅកម្ពុជា។

ខាងក្រោមនេះជាប្រវត្តិរូបសង្ខេបឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាម ហ៊ា មេបញ្ជាការរងកងទ័ពជើងគោក៖

ឯកឧត្តម ស៊ាម ហ៊ា កើតនៅថ្ងៃទី១ ខែមីនា ឆ្នាំ១៩៥៤ នៅភូមិវាល ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ ហើយបច្ចុប្បន្ន ឯកឧត្តម រស់នៅ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ឯកឧត្តម មានបងប្អូនចំនួនប្រាំនាក់ ក្នុងនោះស្រីម្នាក់ (ស្លាប់ក្នុងរបបខ្មែរក្រហមអស់បីនាក់)។ កាលពីកុមារភាពក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ឯកឧត្តម បានចូលរៀននៅសាលាបឋមសិក្សាសាបាត និងបន្តទៅអនុវិទ្យាល័យក្រាំងស្លា ក្នុងឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ នៅឆ្នាំ១៩៧០ ឯកឧត្តម បានផ្លាស់មករស់នៅសង្កាត់ចាក់អង្រែ ក្រុងភ្នំពេញ ជាមួយបងស្រីដែលជាគ្រូបង្រៀន ហើយ ឯកឧត្តម បន្តរៀនថ្នាក់ទី១ (សង្គមចាស់ បច្ចុប្បន្នថ្នាក់ទី១២) នៅវិទ្យាល័យចាក់អង្រែ។ នៅគ្រានោះ ឯកឧត្តម មានបំណងចង់ក្លាយជាគ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមឡើងកាន់អំណាច ការសិក្សាត្រូវបានបញ្ចប់ ហើយខ្មែរក្រហមបានជម្លៀសដោយបង្ខំឯកឧត្តម និងគ្រួសារចេញពីក្រុងភ្នំពេញ។ គ្រួសារឯកឧត្តម បានចាកចេញពីភ្នំពេញឆ្ពោះទៅកាន់ស្រុកកំណើតឯខេត្តតាកែវ។ បន្ទាប់ពីធ្វើដំណើរដោយថ្មើរជើងអស់ជាច្រើនថ្ងៃ គ្រួសារឯកឧត្តម បានមកដល់

ភូមិវាល ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ នៅពេលនោះ ឯកឧត្តម មានអាយុប្រហែល ២០ឆ្នាំ ក្នុងនាមជាប្រជាជនថ្មី "ប្រជាជន១៧ មេសា" ត្រូវបានអង្គការចាត់តាំងឱ្យធ្វើស្រែ, ជីកប្រឡាយ និងរែកដី ដើម្បីកសាងទំនប់ឈ្មោះ "ទំនប់សែនភៀស" ក្បែរបឹងក្បាលពោធិ៍ ខេត្តតាកែវ។ ពេញរបបខ្មែរក្រហម ឯកឧត្តម ក៏ដូចប្រជាជនផ្សេងទៀតដែរបានជួបប្រទះទុក្ខលំបាក ធ្វើការហួសកម្លាំង និងហូបមិនគ្រប់គ្រាន់ជាហេតុនាំឱ្យរាងកាយស្គមកំព្រឹង។ ក្នុងរបបខ្មែរក្រហមបងប្រុសឯកឧត្តម បីនាក់ត្រូវបានខ្មែរក្រហមសម្លាប់ គឺបងប្រុសម្នាក់ជាគ្រូបង្រៀន និងពីរនាក់ទៀតដែលជាទាហាន លន់ នល់។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ របបខ្មែរក្រហមត្រូវបានរំដោះដោយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា សហការជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាមបានវាយរំដោះប្រទេសកម្ពុជាពីទិសខាងកើត និងសង្គ្រោះប្រជាជនបានជាបន្តបន្ទាប់។ គ្រួសារឯកឧត្តម និងប្រជាជនទាំងអស់បានរស់នៅជួបជុំសមាជិកគ្រួសាររៀងៗខ្លួនវិញ។

ចាប់ពីចុងឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៨៥ ឯកឧត្តម បានបម្រើការងារជាគណៈកម្មាការឃុំ និងជាប្រធានក្រុមឃោសនាឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ការងារឯកឧត្តម គឺធ្វើការផ្ទាល់ជាមួយប្រជាជននៅតាមមូលដ្ឋានដែលគាត់បញ្ជាក់ថាជាការងារដែលគាត់ចូលចិត្តព្រោះមានការប្រាស្រ័យទាក់ទងយ៉ាងជិតស្និទ្ធ និងបានដឹងពីសុខទុក្ខប្រជាជន។ នៅឆ្នាំ១៩៨៦ ឯកឧត្តម ត្រូវបានតែងតាំងជាអនុប្រធានមន្ទីរនយោបាយយោធាខេត្តតាកែវ។ រហូតដល់ឆ្នាំ១៩៩៣ ឯកឧត្តម ត្រូវបានដំឡើងជាអនុបញ្ជាការយោធាខេត្តតាកែវ។ ចាប់ពីឆ្នាំ១៩៩៧ រហូតដល់ឆ្នាំ២០០១ ឯកឧត្តម ត្រូវបានដំឡើងឋានន្តរស័ក្តិជាវរសេនីយ៍ឯក នាយរងសេនាធិការភូមិភាគទី៣។ ចាប់ពីឆ្នាំ២០០១ ដល់ឆ្នាំ២០១៣ ឯកឧត្តម ជានាយរងការិយាល័យការពារព្រំដែនគោក និងជានាយរងសេនាធិការ កងទ័ពជើងគោក។ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ ឯកឧត្តម ត្រូវបានតែងតាំងជាឧត្តមសេនីយ៍ទោ មេបញ្ជាការកងទ័ពជើងគោក។ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ រហូតមកដល់បច្ចុប្បន្ន ឯកឧត្តម ជាឧត្តមសេនីយ៍ឯក មេបញ្ជាការរងកងទ័ពជើងគោក ហើយ ឯកឧត្តមជាប្រធានគណៈកម្មការប្រវត្តិសាស្ត្រយោធា នៃកងទ័ពជើងគោក ដែលបានរួមចំណែកកសាងវិមានឈ្នះ ឈ្នះ និងសួនតេជោ សន្តិភាព។ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣ ឯកឧត្តម ទទួលបាននូវគ្រឿងឥស្សរិយយស «ជាតូបការ» ពីព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ប្រគល់ជូនសម្រាប់ការបម្រើជាតិដ៏វិសេសវិសាល។

ឯកឧត្តម ក៏ធ្លាប់ទៅបំពេញទស្សនកិច្ចផ្លូវការ និងចូលរួមការបណ្តុះបណ្តាល ស្តីពីយុទ្ធសាស្ត្រសមរភូមិ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋប្រជាមានិតចិន។ ឯកឧត្តម ក៏បានដឹកនាំការស្រាវជ្រាវ និងចងក្រងប្រវត្តិសាស្ត្រយោធាជាការងារមួយដែលឯកឧត្តមពេញចិត្តយ៉ាងខ្លាំងព្រោះពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រ។ ជាងនេះទៅទៀត នៅឆ្នាំ២០១៣ ឯកឧត្តម បានចូលរួមចំណែកក្នុងការកសាងវិមានឈ្នះ ឈ្នះ និងសួនតេជោ សន្តិភាព។ នៅសួនតេជោ សន្តិភាព មានការដាក់តាំងបង្ហាញផែនទី និងផ្ទាំងថ្មជារូបភ្នំ ដែលបង្ហាញពីកន្លែងអតីតសមរភូមិប្រយុទ្ធរវាងកងទ័ពខ្មែរក្រហម និងកងទ័ពរដ្ឋាភិបាល ព្រមទាំងពិពណ៌នាអំពីទីតាំងនានាដែលបានអនុវត្ត នយោបាយឈ្នះ ឈ្នះ។ ការចូលរួមឯកឧត្តម ក្នុងប្រវត្តិសាស្ត្រយោធាបានរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាចំណេះដឹងប្រវត្តិសាស្ត្រដោយធានាថាក្មេងជំនាន់ក្រោយយល់ពីបរិបទពិតនៃជម្លោះអតីតកាល។

ឯកឧត្តម ក៏បានកោតសរសើរដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានធ្វើកិច្ចការងារស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរក្រហមសម្រាប់ទុកឱ្យមនុស្សជំនាន់ក្រោយបានដឹង និងរៀនសូត្រ។ ឯកឧត្តម ក្នុងនាមជាមេបញ្ជាការរងកងទ័ពជើងគោក បានសហការយ៉ាងល្អជាមួយ មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការរៀបចំ

សន្និសីទស្តីពី“អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍” នៅសាលយុត្តិតេជោ អតីតសាលសវនាការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ដោយមានការអញ្ជើញបើកសន្និសីទដ៏ខ្ពង់ខ្ពស់បំផុតពីសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងបិទអង្គសន្និសីទដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ។

ថ្វីត្បិតតែមានវ័យចំណាស់ និងមានបញ្ហាសុខភាពមួយចំនួនផង ប៉ុន្តែ ឯកឧត្តម នៅតែបន្តបណ្តុះបណ្តាល និងចែករំលែកបទពិសោធន៍ដ៏មានតម្លៃទាក់ទងនឹងប្រវត្តិសាស្ត្រយោធា និងបទពិសោធន៍នៃការរួមចំណែកក្នុងការអនុវត្តនយោបាយ ឈ្នះ ឈ្នះ នាពេលកន្លងមក ទៅកាន់មនុស្សជំនាន់ក្រោយដើម្បីឱ្យការងារប្រវត្តិសាស្ត្រយោធាកាន់តែរីកចម្រើនទៅមុខបន្តទៀត។



ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាម ហ៊ិ មេបញ្ជាការរងកងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# ខ្សែភាពយន្តឯកសារ «កុមារកម្ពុជា»
## រំឭកក្មេងៗជំនាន់ក្រោយពីទុក្ខវេទនាមកលើកុមារក្នុងរបបខ្មែរក្រហម

**ផេង ពង្សរ៉ាស៊ី**



សិស្សានុសិស្សវ័យក្មេង៤នាក់ដែលមានអាយុតិចជាង ១៥ឆ្នាំ បានមកទស្សនាខ្សែភាពយន្តឯកសារមានចំណងជើង «កុមារកម្ពុជា» នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សិស្សានុសិស្សវ័យក្មេង៤នាក់ដែលមានអាយុតិចជាង១៥ឆ្នាំ បានមកទស្សនាខ្សែភាពយន្តឯកសារមានចំណងជើង «កុមារកម្ពុជា» នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ ខ្សែភាពយន្តនេះ បង្ហាញពីដំណើរឥតគោលដៅរបស់កុមារតូចៗដែលឪពុកម្តាយបានស្លាប់ចោលអស់ បន្ទាប់ពីការដួលរលំរបបខ្មែរក្រហមនៅដើមឆ្នាំ១៩៧៩។ លោក ផេង ពង្សរ៉ាស៊ី ជានាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានពន្យល់អំពីសាច់រឿងនៅក្នុងខ្សែភាពយន្ត និងបានរៀបរាប់ពីខ្សែជីវិតក្មេងៗរស់នៅក្រោមរបបខ្មែរក្រហមប្រាប់ដល់សិស្សទាំង៤នាក់ ដើម្បីជាជំនួយដល់ការស្វែងយល់ពីខ្សែភាពយន្តបន្ថែមទៀត។ លោក ផេង ពង្សរ៉ាស៊ី ក៏បានលើកទឹកចិត្តសិស្សឱ្យត្រិះរិះពិចារណាអំពីរឿងរ៉ាវដែលបានកើតឡើងចំពោះកុមារនៅក្នុងរបបខ្មែរក្រហម និងប្រៀបធៀបជីវិតរស់នៅនាពេលបច្ចុប្បន្នទៅនឹងរឿងរ៉ាវដែលបានកើតឡើងកាលពី៥០ឆ្នាំមុន ព្រមទាំងបានបណ្តុះស្មារតីក្មេងជំនាន់ក្រោយឱ្យចេះអាណិតអាសូរចំពោះជីវិតលំបាកដែលក្មេងៗបានជួបប្រទះក្នុងរបបខ្មែរក្រហម។ ខ្សែភាពយន្តខ្លីដែលមានរយៈពេលត្រឹមជាង៦នាទីនេះ បានធ្វើឱ្យសិស្សទាំងនោះនឹកគិតដល់រឿងរ៉ាវដែល

បានកើតឡើងកាលពីអតីតកាលនៅក្នុងប្រទេសរបស់ខ្លួន និងបានបង្ហាញឱ្យឃើញពីការបាត់បង់អ្វីៗគ្រប់យ៉ាង ប្រសិនជាអ្នកទាំងនោះរស់នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម។ មិនតែប៉ុណ្ណោះ ខ្សែភាពយន្តកុមារកម្ពុជា បានបណ្តុះគំនិតសិស្សឱ្យមានចិត្តអាណិតអាសូរចំពោះរឿងរ៉ាវដែលបានកើតឡើងលើកុមារតូចៗកម្ពុជាកាលពីរបបខ្មែរក្រហម។

សិស្សឈ្មោះ **សុវណ្ណ គីមលាង** ភេទស្រី អាយុ១៣ឆ្នាំ រៀនថ្នាក់ទី៥ នៃសាលាបឋមសិក្សា ព្រំ សុនក្តីកណ្តាល បាននិយាយថា៖ «ប្រសិនជាជីវិតខ្ញុំស្ថិតនៅក្នុងរបបខ្មែរក្រហមដូចក្មេងៗនៅក្នុងភាពយន្តនេះ ជីវិតខ្ញុំពិតជាលំបាកវេទនាជាមិនខានឡើយ។ ជួនកាលត្រូវខ្មែរក្រហមយកទៅសម្លាប់ និងជួនកាលត្រូវស្លាប់ដោយសារជំងឺគ្មានថ្នាំព្យាបាល»។

សិស្សឈ្មោះ **ខេង សុខលាភ** ភេទស្រី អាយុ១២ឆ្នាំ រៀនថ្នាក់ទី៦ នៃសាលាបឋមសិក្សាជាមួយគ្នា បានលើកឡើងថា ជីវិតគាត់នឹងជួបប្រទះទុក្ខវេទនាជាខ្លាំង និងអាចឈានដល់ការបាត់បង់ជីវិតដោយសារតែការសម្លាប់ដោយបោកក្បាលនឹងដើមឈើ ឬស្លាប់ដោយសារការអត់អាហារ និងគ្មានថ្នាំព្យាបាល។ សុខលាភ និយាយបន្តដូច្នេះថា៖ « ប្រសិនជាខ្ញុំស្ថិតនៅក្នុងរបបខ្មែរក្រហមដូចក្មេងៗនៅក្នុងភាពយន្តនេះ ជីវិតខ្ញុំនឹងវេទនា ព្រោះមិនមានបាយហូបគ្រប់គ្រាន់ និងត្រូវខ្មែរក្រហមយកទៅសម្លាប់ដោយបោកក្បាលនឹងដើមឈើ។ រីឯពេលមានជំងឺ គឺគ្មានថ្នាំព្យាបាល ក៏ត្រូវស្លាប់ទៀត។ ពេលខ្លះអត់បាយហូបក៏ហូបស្លឹកឈើ ហើយពេលខ្លះទៀត ដោយសារតែឃ្លានពេក ក៏លួចបេះដំណាំអង្គការហូប ហើយក៏ត្រូវខ្មែរក្រហមបាញ់សម្លាប់ ហើយឪពុកម្តាយខ្ញុំ ក៏ត្រូវសម្លាប់ទៀត»។

សិស្សឈ្មោះ **អៀង ស្រីធីន** ភេទស្រីអាយុ១២ឆ្នាំ រៀនថ្នាក់ទី៦ បាននិយាយស្រដៀងនឹង សុខលាភ និង គីមលាង ដែរថា ប្រសិនជាខ្ញុំរស់នៅក្នុងរបបខ្មែរក្រហម ជីវិតរបស់ខ្ញុំនឹងជួបប្រទះការលំបាកជាច្រើន ហើយទាំងខ្ញុំ និងឪពុកម្តាយ អាចស្លាប់ដោយអត់អាហារ ឬអាចត្រូវខ្មែរក្រហមសម្លាប់ទៀត។ ចំណែកសិស្សម្នាក់ទៀតដែលមានវ័យក្មេងជាងគេ ឈ្មោះ ថន មុីមុី ភេទស្រី អាយុ១១ឆ្នាំ រៀនថ្នាក់ទី៥ បានប្រាប់ថា ជីវិតគាត់ប្រាកដជាស្លាប់ជាក់ជាមិនខាន ប្រសិនជាគាត់រស់នៅក្នុងរបបខ្មែរក្រហម។ មុីមុី និយាយដូច្នេះថា៖ «ប្រសិនជាខ្ញុំរស់នៅក្នុងរបបខ្មែរក្រហមដូចក្មេងៗនៅក្នុងភាពយន្តនេះ ខ្ញុំដឹងតែស្លាប់ហើយ»។

**ស្រីធិន, សុខលាភ, គីមលាង និង មុីមុី** បានបង្ហាញពីអារម្មណ៍អាណិតអាសូរចំពោះជីវិតក្មេងៗទាំងនោះ និងសោកស្តាយចំពោះរឿងរ៉ាវលំបាកៗដែលបានកើតឡើងលើជីវិតកុមារក្មេងៗរស់នៅក្នុងរបបខ្មែរក្រហម។ គីមលាង, ស្រីទីន និង មុីមុី និយាយដូចគ្នាថា៖ «បន្ទាប់ពីបានមើលភាពយន្តនេះរួច ខ្ញុំមានអារម្មណ៍អាណិតចំពោះក្មេងៗ ទាំងអស់នោះណាស់»។ សុខលាភ បានបន្ថែមថា៖ «ខ្ញុំមានអារម្មណ៍អាណិត និងសោកស្តាយចំពោះក្មេងទាំងនោះជាខ្លាំង»។

ស្ថិតនៅក្នុងខែមិថុនា ជាខែដែលពិភពលោកកំណត់ពីការលើកកម្ពស់ និងការប្រឆាំងនឹងការធ្វើពលកម្មលើកុមារក្នុងពិភពលោក មានសិស្សានុសិស្សវ័យក្មេងជាច្រើននាក់បានមកកាន់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ដើម្បីសិក្សារៀនសូត្រពីប្រវត្តិសាស្ត្រខ្មែរក្រហម។ នេះជាអ្វីដែលក្មេងៗទាំងនោះគួរទទួលបាននាពេលបច្ចុប្បន្ន ដើម្បីឆ្លើយតបទៅនឹងកិត្តិយសរបស់កុមារ និងដើម្បីលើកកម្ពស់ការយល់ដឹង និងការចូលរួមលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។ នៅឆ្នាំ១៩២៥ ទិវាកុមារអន្តរជាតិត្រូវបានប្រកាសជាលើកដំបូងនៅទីក្រុងហ្សឺណែវ ក្នុងអំឡុងពេលសន្និសីទពិភពលោកស្តីពីសុខុមាលភាពកុមារ។ នៅក្នុងប្រទេសកម្ពុជា ទិវាកុមារអន្តរជាតិ ថ្ងៃទី១ ខែមិថុនា ត្រូវបានប្រារព្ធធ្វើជារៀងរាល់ឆ្នាំ ដើម្បីជាកិត្តិយសដល់កុមារ។ នៅថ្ងៃទី១២ ខែមិថុនា ខាងមុខនេះ គឺជាទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ។ ប្រទេសកម្ពុជា ក៏ប្រារព្ធពិធីនេះជារៀងរាល់ឆ្នាំដែរ ដើម្បីលើកកម្ពស់ការយល់ដឹង និងការចូលរួមលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

នៅក្នុងរបបខ្មែរក្រហម កុមារទាំងអស់ត្រូវបានបំបែកចេញពីឪពុកម្ដាយឱ្យទៅរស់នៅក្នុងកងកុមារ បង្ខំឱ្យធ្វើការងារហួសកម្លាំង និងបំបិទការសិក្សារៀនសូត្រដែលជាតម្រូវការចាំបាច់សម្រាប់កុមារក្នុងការកសាងប្រទេស។ ក្រោយរបបខ្មែរក្រហមដួលរលំ កុមារកម្ពុជារាប់សែននាក់បានបាត់បង់ឪពុកម្ដាយ ក្លាយជាកុមារកំព្រា និងបាត់បង់ចំណេះដឹង។ វាសនារបស់អ្នកទាំងនោះ បានលិចបាត់ទៅក្នុងស្រមោលនៃអំពើប្រល័យពូជសាសន៍ខ្មែរក្រហម។

កុមារកម្ពុជាសព្វថ្ងៃ មិនដូចកុមារកម្ពុជាកាលពី៥០ឆ្នាំមុនឡើយ។ អ្នកទាំងនោះ ទទួលបានការអប់រំល្អ ការរស់នៅសមរម្យ សិទ្ធិសេរីភាពប្រសើរឡើង ទាំងការបញ្ចេញមតិ និងការគិតគូរពីអនាគត និងប្រទេសជាតិខ្លួន។ នៅដើមឆ្នាំ២០២៥នេះ ក្រសួងអប់រំ យុវជន និងកីឡា បានបោះពុម្ពសៀវភៅប្រវត្តិវិទ្យាថ្នាក់ទី៦ថ្មី ដោយរួមបញ្ចូលទាំងមេរៀន «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដើម្បីផ្ដល់ដល់សិស្សកម្រិតបឋមសិក្សានូវការយល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ការរើបម្រាស់ចេញពីរបបនេះ និងការតស៊ូដើម្បីប្រជាជាតិ និងប្រទេសជាតិទទួលបានសុខសន្តិភាព។

ជារៀងរាល់ថ្ងៃ មជ្ឈមណ្ឌលឯកសារកម្ពុជាបាននិងកំពុងផ្ដល់ការអប់រំពីប្រវត្តិសាស្ត្រនេះ ដល់សិស្សានុសិស្សគ្រប់កម្រិត នៅតាមមូលដ្ឋាននានាក្នុងទូទាំងប្រទេសកម្ពុជា ដើម្បីជាជំនួយដល់ការសិក្សា ការស្វែងយល់ ការស្រាវជ្រាវ និងការចូលរួមអភិវឌ្ឍន៍ប្រទេសដោយគ្មានអំពើប្រល័យពូជសាសន៍។

នៅរសៀលថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានទទួលស្វាគមន៍សិស្សានុសិស្សដែលកំពុងសិក្សានៅថ្នាក់ទី៥ និងទី៦ នៃសាលាបឋមសិក្សា ព្រុំ សុន ក្ដីកណ្ដាល និងបានផ្ដល់នូវការជួបពិភាក្សា រៀនសូត្រ និងបណ្ដុះគំនិតពីភាពអាណិតអាសូរដល់ជីវិតរស់នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ជាពិសេសកុមារតូចៗដែលខ្មែរក្រហមបង្អត់អាហារ ការបំបែកចេញពីឪពុកម្ដាយ ការបង្ខាំងការសិក្សារៀនសូត្រ ការបង្ខំឱ្យធ្វើការហួសកម្លាំង ការធ្វើទារុណកម្ម និងការសម្លាប់ដោយអយុត្តិធម៌។ ជាដំបូង អ្នកទាំងនោះទទួលបានការណែនាំឱ្យទស្សនាពិព័រណ៍រូបថតអចិន្ត្រៃយ៍ស្ដីពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការស្វែងរកសន្តិភាព និងយុត្តិធម៌នៅកម្ពុជា។ បន្ទាប់មក សៀវភៅ និងឯកសារជាច្រើនស្ដីពីប្រវត្តិសាស្ត្រនេះ ក៏ត្រូវបានបង្ហាញ។

មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ទទួលស្វាគមន៍ជានិច្ចចំពោះភ្ញៀវទាំងឡាយ ដែលចង់សិក្សាស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ខ្សែភាពយន្តឯកសារស្ដីពីប្រវត្តិសាស្ត្រខ្មែរក្រហមជាច្រើនរឿង ដែលមាននៅក្នុងបណ្ណសារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ត្រៀមនឹងចាក់បញ្ចាំងជូនភ្ញៀវដែលមានចំណាប់អារម្មណ៍ចង់ទស្សនាដើម្បីស្វែងយល់ និងស្រាវជ្រាវ។





សិស្សានុសិស្សវ័យក្មេង៤នាក់ដែលមានអាយុតិចជាង១៥ឆ្នាំ បានមកទស្សនាខ្សែភាពយន្តឯកសារមានចំណងជើង «កុមារកម្ពុជា» នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សមកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន

## ក្តុលផ្សារ មកទស្សនកិច្ចសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅ មជ្ឈមណ្ឌលឯកសារកោះធ្នង់

*ឃុំ រ៉ា និង ទី ស៊ីថា*



*សិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្តុលផ្សារ មកទស្សនកិច្ចសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅ មជ្ឈមណ្ឌលឯកសារកោះធ្នង់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅរសៀលថ្ងៃទី៥ ខែមិថុនា ឆ្នាំ ២០២៥ សិស្សានុសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្តុលផ្សារ ចំនួន៧ នាក់បានមកទស្សនកិច្ចសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលឯកសារកោះធ្នង់។ ជាកិច្ចចាប់ផ្តើមនៃដំណើរទស្សនកិច្ច លោក ឃុំ រ៉ា បានធ្វើការណែនាំខ្លួន រួចហើយដឹកនាំសិស្សានុសិស្សទៅទស្សនាពិព័រណ៍រូបថត រូបគំនូរ និងផែនទី ដែលបានដាក់តាំងបង្ហាញនៅបរិវេណនៃមជ្ឈមណ្ឌលឯកសារកោះធ្នង់។ បន្ទាប់មកសិស្សានុសិស្សបានអានសៀវភៅ ប្រវត្តិសាស្ត្រ ដែលបានតម្កល់នៅក្នុងការិយាល័យ។

កម្មវិធីបន្ទាប់គឺលោក ឃុំ រ៉ា បានលើកយកសៀវភៅរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះនៃរបបខ្មែរក្រហម(១៩៧៥-១៩៧៩) ដែលបង្ហាញពីប្រវត្តិរូបអ្នកទោសនៅមន្ទីរសន្តិសុខស-២១ បូករួមទាំងរូបថតចំនួន២៣៩៧ នាក់។ យោងតាមបញ្ជីអ្នកទោសនៅមន្ទីរសន្តិសុខស-២១ ដែលធ្វើបច្ចុប្បន្នភាពដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅក្នុង

ខែមករា ឆ្នាំ២០១៨ គឺមានអ្នកទោសសរុបចំនួន ១៨០៦៣នាក់ ត្រូវបានចាប់ខ្លួន និងបញ្ជូនមកឃុំឃាំងនៅមន្ទីរសន្តិសុខស-២១។ ដើម្បីជាការសិក្សាស្វែងយល់បន្ថែមលោក ឈុំ វ៉ា បានលើកករណីឈ្មោះ ព្រុំ ធុច គឺជាអ្នកទោសក្នុងមន្ទីរសន្តិសុខស-២១ និង យាន ប៊ីស គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកអានដើម្បីបន្តការពិភាក្សា។

ខាងក្រោមនេះគឺជាការប្រៀបធៀបរឿងរ៉ាវរបស់អ្នកទាំងពីរ៖

**១) ឈ្មោះ ព្រុំ ធុច** ភេទប្រុស អាយុ៤២ឆ្នាំ (ក្នុងឆ្នាំ១៩៧៦)។ នៅមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ព្រុំ ធុច គឺជាវេជ្ជបណ្ឌិតនៅមន្ទីរពេទ្យព្រះកេតុមាលា។ ព្រុំ ធុច មានស្រុកកំណើតនៅភូមិស្វាយពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង។ ព្រុំ ធុច មានឪពុកឈ្មោះ ព្រុំ ថៃ និងម្តាយឈ្មោះ ពេញ ប៉ិច។ ព្រុំ ធុច មានប្រពន្ធឈ្មោះ ហោ វណ្ណា មានស្រុកកំណើតនៅភូមិមោងឫស្សី ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ ព្រុំ ធុច មានកូន៥នាក់ (ប្រុស៣ និង ស្រី២នាក់)។ ព្រុំ ធុច ត្រូវបានខ្មែរក្រហម ចាប់ខ្លួននៅបាត់ដំបង នៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៦ និងបញ្ជូនទៅឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ក្នុងផ្ទះក០៣ បន្ទប់ធំ៧។ យោងតាមឯកសារនៅបណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានរកឃើញថា ព្រុំ ធុច ត្រូវបានខ្មែរក្រហមបញ្ជូនមកដល់មន្ទីរសន្តិសុខស-២១ នៅថ្ងៃទី ១១ ខែមករា ឆ្នាំ១៩៧៦ និងសម្លាប់ថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល១០៧ថ្ងៃ។

**២) ឈ្មោះ យាន ប៊ីស** ភេទស្រី អាយុ៥៨ឆ្នាំ មានស្រុកកំណើតនៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន យាន ប៊ីស រស់នៅភូមិឃុំដដែល។ យាន ប៊ីស មានឪពុកឈ្មោះ កុល យាន និង ម្តាយឈ្មោះ ម៉ែន ប្រាញ់។ ឪពុក ប៊ីស បានស្លាប់នៅក្នុងរបបខ្មែរក្រហមដោយសារអត់អាហារ។ ប៊ីស មានបងប្អូនចំនួន៦នាក់ ក្នុងនោះមានស្រីចំនួន៤នាក់ ហើយគាត់ជាកូនទីបួននៅក្នុងគ្រួសារ។ នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីភូមិក្តុលលើឱ្យទៅនៅអាលចម្ងេច (អាលច និងម្ងេច គឺជាទីតាំងដែលខ្មែរក្រហមជម្លៀសប្រជាជនក្តុលលើទៅស្នាក់អាស្រ័យ និងកន្លែងការងារក្នុងរបបខ្មែរក្រហម) ដែលស្ថិតនៅក្នុងឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ។ ប្រជាជនស្ទើរពាក់កណ្តាលត្រូវស្លាប់ដោយសារអត់អាហារ និងខ្មែរក្រហមសម្លាប់។ កុល យាន មានរាងកាយស្គមស្គាំង ភ្នែករូងជ្រៅ សល់តែស្បែកនិងឆ្អឹង រហូតដល់គាត់ស្លាប់នៅម្ងេច ឃុំស្វាយជ្រះ។

ជាចុងក្រោយក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បាក់បញ្ចាំងខ្សែភាពយន្តឯកសារមានចំណងជើង "កម្ពុជា ៣+៤" មានក្នុងឆាណែលយូធូបរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឈ្មោះ Documentation Center of Cambodia។ បន្ទាប់ពីទស្សនាកុនចប់ សិស្សានុសិស្ស ទទួលបានសៀវភៅទស្សនាវដ្តីស្វែងរកការពិតម្នាក់មួយច្បាប់ដើម្បីសិក្សាស្វែងយល់បន្ថែម។

មុនចប់កម្មវិធីទស្សនកិច្ចសិក្សា សិស្សបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម៖

**អ៊ឹម ថាវី** ភេទស្រី រៀននៅវិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែន ក្តុលជ្វារ បានរៀបរាប់ថា ខ្ញុំពិតជាមានអារម្មណ៍តក់ស្លុត និងរន្ធត់ចិត្តជាខ្លាំងនៅពេលឃើញសកម្មភាពឃោរឃៅកើតឡើងលើប្រជាជនខ្មែរ។ បន្ទាប់ពីខ្ញុំបានទស្សនាខ្សែភាពយន្តឯកសាររួចមក ខ្ញុំបានទទួលការពន្យល់ពីបងៗដែលធ្វើការនៅមជ្ឈមណ្ឌលឯកសារកោះថ្មបន្ថែមទៀត។ ខ្ញុំបានយល់ដឹងច្រើនពីសម័យកាលដ៏ឃោរឃៅនេះ តាមរយៈការបង្ហាញហេតុការណ៍ រូបភាព និងសៀវភៅ។ ខ្ញុំមិនចង់ឱ្យកើតមានរបបខ្មែរក្រហមម្តងទៀតទេ ព្រោះមានភាពលំបាកក្នុងការរស់នៅព្រមទាំងគ្មានសេរីភាព និងគួរឱ្យខ្លាច។

**គ្រី សិទ្ធីជាលីស** ភេទស្រី គឺជាសិស្សវិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែន ក្តុលជ្វារ លើកឡើងថា បន្ទាប់ពីខ្ញុំបានស្តាប់ការពន្យល់ និងបានទស្សនាវីដេអូឯកសាររួចមក ខ្ញុំមានអារម្មណ៍សោកស្តាយចំពោះប្រជាជនដែលស្លាប់ដោយភាពអយុត្តិធម៌ ការរស់

នៅរងទុក្ខវេទនា ដោយសារភាពឃោរឃៅ និងការជិះជាន់កាប់សម្លាប់គ្មានចិត្តមេត្តាចំពោះជនរងគ្រោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ខ្ញុំពិតជាអាណិតដល់ជនរងគ្រោះខ្លាំងណាស់។ ចុងក្រោយ ខ្ញុំសូមអរគុណដល់បងៗក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្មដែលបានចំណាយពេលវេលាដើម្បីពន្យល់ណែនាំបន្ថែម និងបានចាក់ខ្សែភាពយន្តនៅសម័យខ្មែរក្រហមឱ្យខ្ញុំបានទស្សនា។

**វ៉យ៉ម រិទ្ធី** ភេទប្រុស គឺជាសិស្សវិទ្យាល័យប៊ុនរ៉ានី ហ៊ុន សែន ក្តុលដង្ហារ ឱ្យដឹងថា ថ្ងៃនេះខ្ញុំនិងមិត្តភក្តិបានមកសិក្សាស្វែងយល់បន្ថែមនៅអំពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ ខ្ញុំបានសិក្សាស្វែងយល់ដោយខ្លួនឯងខ្លះ និងបងៗដែលធ្វើការនៅមជ្ឈមណ្ឌលឯកសារកោះថ្មបានពន្យល់ណែនាំបន្ថែមទៀត។ នៅថ្ងៃនេះបងៗបានឱ្យខ្ញុំទស្សនាខ្សែភាពយន្តខ្លីមួយដែលបង្ហាញពីការរស់នៅរបស់ប្រជាជនក្នុងរបបខ្មែរក្រហម និងការសម្លាប់រង្គាលដោយមិនមានការខ្លាចរអា។ ក្មេងអាយុត្រឹមតែ១៧ឆ្នាំ ត្រូវបានអង្គការបញ្ជាឱ្យសម្លាប់មនុស្សជាង៣០០នាក់ មិនដល់មួយសប្តាហ៍។ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ការបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ និងការយកឆ្អឹងមនុស្សដែលស្លាប់ទៅដុតយកធ្វើជីកសិកម្ម។ការសម្លាប់មនុស្សដែលមានចំណេះដឹង ដើម្បីកុំឱ្យមកទាមទារសិទ្ធិសេរីភាពឬប្រកែកតវ៉ា ដោយទុកមនុស្សមិនមានចំណេះដឹងឱ្យនៅធ្វើការ។ កុមារ និងមនុស្សចាស់ជាច្រើនបានស្លាប់ដោយសារការបរិភោគមិនគ្រប់គ្រាន់ និងជំងឺផ្សេងៗ។ ខ្ញុំមានអារម្មណ៍រីករាយនៅពេលដែលប្រទេសជាតិរួចផុតពីរបបខ្មែរក្រហម និងចូលរួមសោកស្តាយដល់ជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម។ ខ្ញុំពិតជាសោកស្តាយចំពោះសង្គមជាតិយ៉ាងខ្លាំង ដែលបានបាត់បង់ធនធានមនុស្សយ៉ាងច្រើន។ ទោះជាយ៉ាងណាក្តី ក្នុងនាមខ្ញុំជាយុវជន ខ្ញុំនឹងខិតខំសិក្សារៀនសូត្រដើម្បីក្លាយខ្លួនជាធនធានមួយដែលសង្គមត្រូវការ និងចូលរួមអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានការរីកចម្រើន។





លោក ឈុំ វ៉ា ធ្វើបទបង្ហាញដល់សិស្សដែលមកទស្សនកិច្ចមជ្ឈមណ្ឌលឯកសារកោះថ្ម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សអនុវិទ្យាល័យថ្លាត មកអានឯកសារ និងស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

ស្ងួត វិចិត្រ




*សិស្សានុសិស្សនៃអនុវិទ្យាល័យថ្លាតចំនួន៦នាក់ បានមកសិក្សាស្វែងយល់ពីឯកសារប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥ សិស្សានុសិស្សនៃអនុវិទ្យាល័យថ្លាតចំនួន៦នាក់ បានមកសិក្សាស្វែងយល់ពីឯកសារប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង គឺជាទីកន្លែងដែលមានតម្កល់ឯកសារ សៀវភៅ បទសម្ភាសន៍របស់អ្នករស់រានមានជីវិតរបបខ្មែរក្រហម សម្រាប់សាធារណជនធ្វើការសិក្សាស្រាវជ្រាវ ជាពិសេសឯកសារប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ កន្លងមកនេះ មានសិស្សានុសិស្ស អ្នកស្រាវជ្រាវជាតិ អន្តរជាតិ បានធ្វើដំណើរមកកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដើម្បីមកសិក្សាស្វែងយល់រឿងរ៉ាវដែលបានកើតឡើងនៅតំបន់អន្លង់វែងកាលពីអតីតកាល។

នៅក្នុងថ្ងៃនេះ សិស្សានុសិស្សនៃអនុវិទ្យាល័យថ្លាត បានធ្វើដំណើរមកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ ក្រុមការងារមជ្ឈមណ្ឌលសន្តិភាព

អន្លង់វែងបានទទួលស្វាគមន៍ និងឱ្យសិស្សអង្គុយលើកៅអីជុំវិញតុឈើវែងមួយ ទល់មុខទូរទស្សន៍ដែលនឹងចាក់បញ្ចាំង «ប្លង់គោលស្រុកអន្លង់វែង»។ បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង គឺជាអ្នកធ្វើបទបង្ហាញ និងពិភាក្សាជាមួយសិស្សានុ-សិស្សជុំវិញប្លង់គោលស្រុកអន្លង់វែង។ ទន្ទឹមនឹងនេះ បណ្ឌិត លី សុខឃាង បានលើកយកតំបន់ប្រវត្តិសាស្ត្រទាំង១៨កន្លែងដែលជាទីកន្លែងសំខាន់ៗដែលអាចទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិមកសិក្សាស្រាវជ្រាវ និងមកកម្សាន្ត។ ចំណុចសំខាន់មួយទៀតគឺការកែប្រែតំបន់អន្លង់វែងឱ្យក្លាយទៅជាទីក្រុងតូចមួយ ដោយមានការរៀបចំបង្កើតទីកន្លែងទេសចរណ៍ផ្សារភ្ជាប់ទៅតំបន់ប្រវត្តិសាស្ត្រ ភោជនីយដ្ឋាន ប្រព័ន្ធទឹក ផ្លូវ សំណង់អគារ រោងចក្រ និងប្រជាជនជាដើម។ តាមរយៈខ្សែអំបោះនៃផ្លូវដើរថ្មើរជើង គឺជាព្រំដែនការពារពីអំពើអាក្រក់ពីការឈ្លានពាន និងព្រាយបិសាច។ ការអភិវឌ្ឍន៍តំបន់អន្លង់វែង ភ្ជាប់ទៅតំបន់អូរស្មាច់ ដែលស្ថិតនៅតាមបណ្ដោយជួរភ្នំដងរែក។ ទន្ទឹមនឹងនេះ ការផ្សារភ្ជាប់តំបន់ប្រវត្តិសាស្ត្រអន្លង់វែងទៅកាន់ខេត្តសៀមរាប ទាក់ទងទៅនឹងផ្នែកវប្បធម៌ ដែលបានឆ្លុះបញ្ចាំងពីអរិយធម៌ខ្ពស់បំផុត និងដុនដាបបំផុតរបស់ប្រទេសកម្ពុជា។ ចំណុចទាំងអស់នេះ នឹងទាក់ទាញភ្ញៀវទេសចរណ៍ឱ្យមកដល់ស្រុកអន្លង់វែងដើម្បីកម្សាន្ត និងចងចាំមិនភ្លេច។ ចំណែកប្រជាជននៅមូលដ្ឋានក៏អាចទទួលបានកម្រៃពីភ្ញៀវទេសចរណ៍ ធ្វើឱ្យប្រជាជនមានជីវភាពធូរធារជាងមុនមួយកម្រិត។

ក្នុងការពិភាក្សានេះ បណ្ឌិត លី សុខឃាង បានផ្ដល់ឱកាសឱ្យសិស្សានុសិស្សបញ្ចេញមតិយោបល់ផ្ទាល់ខ្លួនទាក់ទងអំពី «តើត្រូវធ្វើយ៉ាងណាដើម្បីធ្វើឱ្យតំបន់អន្លង់វែងមានភ្ញៀវទេសចរណ៍ស្គាល់ច្រើន និងមានសក្ដានុពលខ្លាំង»។ ក្នុងចំណោមសិស្សទាំង៦នាក់ បានលើកឡើងពីគំនិតផ្សេងៗពីគ្នាដូចតទៅ៖ ត្រូវខិតខំរៀនសូត្រ ដើម្បីមានឱកាសរកការងារធ្វើ, ត្រូវស្វែងយល់ពីវប្បធម៌ ទំនៀមទម្លាប់ការរស់នៅក្នុងសង្គម, ខិតខំស្រាវជ្រាវទាក់ទងពីប្រវត្តិសាស្ត្រដែលកើតមាននៅតំបន់អន្លង់វែង ដើម្បីជួយផ្សព្វផ្សាយទៅដល់ភ្ញៀវទេសចរណ៍ដែលបានមកកម្សាន្ត, ត្រូវធ្វើជាយុវជនគំរូ មិនឆ្មើងឆ្មៃ ចេះគោរពអ្នកដទៃ ដើម្បីក្លាយជាពលរដ្ឋល្អនៅក្នុងសហគមន៍របស់ខ្លួន, ថែរក្សាតំបន់ប្រវត្តិសាស្ត្រដែលនៅសេសសល់ពីរបបខ្មែរក្រហម និង ត្រូវខិតខំអភិវឌ្ឍន៍ខ្លួនឯងដើម្បីថ្ងៃមុខមានលទ្ធភាពជួយផ្សព្វផ្សាយពីសហគមន៍របស់ខ្លួនទៅកាន់មហាជនឱ្យបានស្គាល់។

បន្ទាប់ពីទស្សនា «ប្លង់គោលស្រុកអន្លង់វែង» សិស្សានុសិស្សទាំង៦នាក់ក៏បានសម្ដែងការយល់ឃើញរបស់ខ្លួនដូចខាងក្រោម៖

**ព្រុំ វែដន** ភេទស្រី អាយុ១៥ឆ្នាំ បានលើកឡើងថា «ខ្ញុំពិតជាចង់ឃើញស្រុកអន្លង់វែងមានការអភិវឌ្ឍន៍ និងមានកំណើនប្រជាជនរស់នៅច្រើនជាងពេលបច្ចុប្បន្ន។ ទន្ទឹមនឹងនេះ ខ្ញុំក៏ចង់ឱ្យមានអាគារធំៗកើតមានជាបន្តបន្ទាប់នៅក្នុងស្រុកអន្លង់វែងដែរ។ ខ្ញុំពិតជាមានអារម្មណ៍រីករាយដែលបានមកចូលរួមស្ដាប់ការបកស្រាយពន្យល់ទាក់ទងជាមួយប្លង់គោលស្រុកអន្លង់វែង»។

**ឈុន ពិសិដ្ឋ** ភេទប្រុស អាយុ១៥ឆ្នាំ បានរៀបរាប់ថា «ក្រោយពីខ្ញុំបានស្ដាប់ការបកស្រាយពន្យល់យ៉ាងក្បោះក្បាយអំពីតំបន់ភូមិសាស្ត្រនៅក្នុងស្រុកអន្លង់វែងរួចមក ខ្ញុំបានដឹងថាតំបន់អន្លង់វែងមានទីកន្លែងប្រវត្តិសាស្ត្រដល់ទៅ១៨ទីតាំង ដែលអាចទាក់ទាញភ្ញៀវទេសចរណ៍មកកម្សាន្ត។ ស្រុកអន្លង់វែង គឺជាទីកន្លែងកំណើតរបស់ខ្ញុំ។ នៅថ្ងៃអនាគតខ្ញុំសង្ឃឹមថានឹងអាចប្រែក្លាយអន្លង់វែងទៅជាទីក្រុងតូចមួយដែលមានអាគារខ្ពស់ៗ មានកន្លែងទស្សនាច្រើនជាងនេះ ដើម្បីឱ្យភ្ញៀវមកកម្សាន្តកាន់តែច្រើនកុះករ»។

**អាន សៀងហ៊ួយ** ភេទស្រី អាយុ១៥ឆ្នាំ យល់ឱ្យដឹងថា «បន្ទាប់ពីបានទស្សនាប្លង់គោលស្រុកអន្លង់វែង ខ្ញុំចាប់អារម្មណ៍តំបន់លើភ្នំដងរែក ដែលបង្ហាញឱ្យឃើញពីទេសភាពដ៏ស្រស់ស្អាត ដែលធ្វើឱ្យខ្ញុំមានអារម្មណ៍ចង់ទៅកម្សាន្តថតយករូបភាពស្អាតទុកជាអនុស្សាវរីយ៍។ ជាពិសេសក្នុងពេលបច្ចុប្បន្នឃើញថានៅលើភ្នំដងរែកប្រជាជនដាំដំណាំហូបផ្លែជាច្រើនរួមមានទុរេន សាវម៉ាវ មៀន ស្វាយចន្ទី ហើយ

នេះក៏ជាផ្នែកដ៏សំខាន់មួយក្នុងការទាក់ទាញភ្ញៀវមកទស្សនាបានជារៀងរាល់ឆ្នាំ។ នៅថ្ងៃខាងមុខ ខ្ញុំចង់ឃើញស្រុកអន្លង់វែង មានការអភិវឌ្ឍន៍ជឿនលឿនជាងនេះថែមទៀត»។

**វឿន រចនា** ភេទស្រី អាយុ១៨ឆ្នាំ និយាយថា «ខ្ញុំចាប់អារម្មណ៍ទៅលើប្លង់គោលស្រុកអន្លង់វែង ត្រង់ចំណុចការអភិវឌ្ឍន៍ឱ្យមានសំណង់អាគារនៅតាមផ្លូវភ្នំដងរែក ការដាំដើមឈើនៅតាមផ្លូវធ្វើដំណើរ និងការបង្កើតឱ្យមានប្រព័ន្ធទឹក។ ចំណុចខាងលើនេះគឺជាតម្រូវការដ៏សំខាន់មួយ សម្រាប់ការរីកមុខមាត់ថ្មីនៅតំបន់អន្លង់វែង។ នៅថ្ងៃខាងមុខ ខ្ញុំពិតជាចង់ក្លាយខ្លួនទៅជាយុវជនល្អមួយរូបដែលអាចជួយលើការអភិវឌ្ឍន៍ស្រុកកំណើតរបស់ខ្លួនទៅជា ទីកន្លែងមនុស្សម្នាស្គាល់ច្រើន»។

**ញ៉ាន់ សៀវម៉ី** ភេទស្រី អាយុ១៨ឆ្នាំ យល់ឃើញថា «នៅពេលខ្ញុំបានស្ដាប់ការពន្យល់អំពីការអភិវឌ្ឍន៍ស្រុកអន្លង់វែងរួចមក ខ្ញុំចាប់អារម្មណ៍ទៅលើទីកន្លែងប្រវត្តិសាស្ត្រទាំង១៨កន្លែង ដែលបានបន្សល់ទុកពីសម័យខ្មែរក្រហម។ ទីតាំងទាំង១៨ បានធ្វើឱ្យអន្លង់វែងក្លាយទៅជាតំបន់ដ៏សំខាន់ទាក់ទងជាមួយប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ ទន្ទឹមនឹងនេះ ខ្ញុំពិតជាត្រេកអរខ្លាំង ដែលមានមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ជួយបង្ហាត់បង្រៀនអំពីប្រវត្តិសាស្ត្រ និងបានរក្សាទុកទីកន្លែងសំខាន់ៗទាំង១៨ទីតាំង ដើម្បីឱ្យសិស្សនិស្សិតអ្នកស្រាវជ្រាវជំនាន់ក្រោយបានសិក្សាស្វែងយល់។ នៅថ្ងៃខាងមុខ ខ្ញុំសង្ឃឹមថា អន្លង់វែងនៅតែទទួលបានសុខសន្តិភាព និងការអភិវឌ្ឍន៍លើគ្រប់វិស័យ»។

**ថុល ធារី** ភេទប្រុស អាយុ១៥ឆ្នាំ លើកឡើងថា «ខ្ញុំចាប់អារម្មណ៍ទៅលើទីតាំងទាំង១៨កន្លែងដែលសេសសល់ពីរបបខ្មែរក្រហម។ ខ្ញុំឆ្ងល់ថាហេតុអ្វីបានជាមានការបង្កើតនូវរបបផ្ដាច់ការនេះឡើង ហើយបង្កើតមកដើម្បីអ្វី។ ខ្ញុំក៏ចង់ដឹងថាតើការសាងសង់ផ្ទះតាម៉ុក (បច្ចុប្បន្នសារមន្ទីរផ្ទះតាម៉ុក) បានដោយរបៀបណា ព្រោះខ្ញុំឃើញមានសសរធំៗ ហើយតើធ្វើយ៉ាងណាទើបអាចយកឈើទាំងនោះមកធ្វើជាសសរផ្ទះបាន។ ជាចុងក្រោយ ខ្ញុំចង់ឱ្យមានការរក្សាទុក និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រទាំង១៨កន្លែង ដើម្បីឱ្យយុវជនជំនាន់ក្រោយបានឃើញពីទីតាំងនីមួយៗដោយផ្ទាល់»។







នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥ សិស្សានុសិស្សនៃអនុវិទ្យាល័យថ្លាតចំនួន៦នាក់ បានមកសិក្សាស្វែងយល់ពីឯកសារប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាសាធារណៈស្តីពីដំណើរឆ្ពោះទៅរកភាពជាអ្នកដឹកនាំរបស់ក្មេងស្រី

ស្រេង លីដា





យុវជន យុវនារី ចូលរួមវេទិកាសាធារណៈស្តីពីដំណើរឆ្ពោះទៅរកភាពជាអ្នកដឹកនាំរបស់ក្មេងស្រី រៀបចំដោយក្រសួងកិច្ចការនារី សហការជាមួយ រដ្ឋបាលស្រុកបុរីអូរស្វាយ សែនជ័យ នៅអគាររមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥ ក្រសួងកិច្ចការនារី សហការជាមួយ រដ្ឋបាលស្រុកបុរីអូរស្វាយសែនជ័យ រៀបចំវេទិកាសាធារណៈស្តីពីដំណើរឆ្ពោះទៅរកភាពជាអ្នកដឹកនាំរបស់ក្មេងស្រីដោយមានការចូលរួមពីអ្នកស្រី បួរ ខាំតង ប្រធានក្រុមប្រឹក្សាស្រុកបុរីអូរស្វាយ សែនជ័យ, លោកស្រី សម្បត្តិរចនា អភិបាលរងនៃគណៈអភិបាលស្រុកបុរីអូរស្វាយសែនជ័យ, លោកស្រី ចេង ធិនណោត ប្រធាននាយកដ្ឋាននៃក្រសួងកិច្ចការនារី, លោកស្រី មៀកសុទ្ធារី អនុប្រធាននាយកដ្ឋាន, ឪពុកម្តាយ, លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សមកពីវិទ្យាល័យបុរីអូរស្វាយសែនជ័យ។

វេទិកាសាធារណៈសម្រាប់ស្ត្រី ធ្វើឡើងក្នុងគោលបំណងដើម្បីលើកកម្ពស់សមត្ថភាព, ការយល់ដឹង និងទំនុកចិត្តរបស់ក្មេងស្រី និងស្ត្រី ក្នុងកិច្ចការសង្គម និងការដឹកនាំផ្សេងៗ។ វេទិកាសាធារណៈសម្រាប់ស្ត្រីបញ្ចូលកម្មវិធីរួមមានការធ្វើបទបង្ហាញ, ការនិយាយចែករំលែកអំពីបទពិសោធន៍ផ្ទាល់ខ្លួន និងការពិភាក្សាជាក្រុម ដើម្បីស្វែងរកដំណោះស្រាយច្បាស់លាស់ចំពោះបញ្ហាប្រឈមនានាក្នុងជីវិតប្រចាំថ្ងៃ ដូចជា ការសិក្សា, ទំនៀមទម្លាប់ និងភាពអន់ខ្សោយក្នុងការចូលរួមសកម្មភាពសង្គម។

វេទិកាសាធារណៈសម្រាប់ស្ត្រី ប្រព្រឹត្តឡើងនៅអគាររមរតកសង្គមរាស្ត្រនិយម សម្តេចឪ- សម្តេចម៉ែ

(បុរីអូរស្វាយ-សែនជ័យ), មជ្ឈមណ្ឌលសហគមន៍របស់ព្រះរាជបណ្ណាល័យ ហ្វូនម៉ៃ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលដើរតួនាទីមិនត្រឹមតែជាមជ្ឈមណ្ឌលអប់រំ, ស្រាវជ្រាវ និងផ្សព្វផ្សាយអំពីប្រវត្តិសាស្ត្រ និងវប្បធម៌ នោះឡើយ ប៉ុន្តែថែមទាំងជាមជ្ឈមណ្ឌលសហគមន៍ឬសាលសហគមន៍ដែលអាចឱ្យប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ប្រើប្រាស់ក្នុងកម្មវិធីជួបជុំ, គាំទ្រសហគមន៍ និងវេទិកាអប់រំសាធារណៈ និងផ្សព្វផ្សាយសហគមន៍ផ្សេងៗទៀតផងៗ









យុវជន យុវនារី ចូលរួមវេទិកាសាធារណៈស្តីពីដំណើរឆ្ពោះទៅរកភាពជាអ្នកដឹកនាំរបស់ក្មេងស្រី រៀបចំដោយក្រសួងកិច្ចការនារី សហការជាមួយរដ្ឋបាលស្រុកបុរីអូរស្វាយ សែនជ័យ នៅអគាររមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥ៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)









# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៤២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org

សូមអរគុណ!










# បាត់ដំណឹងកូនដោយសារចូលធ្វើបដិវត្តន៍

**អេង សុខម៉េង**

ប៊ី សុន អាយុ៧៩ឆ្នាំ រស់នៅភូមិហាន់ជ័យ ឃុំហាន់ជ័យ ស្រុកឆ្លូង ខេត្តក្រចេះ បានផ្តល់ព័ត៌មានទាក់ទងនឹងកូនរបស់គាត់ ឈ្មោះ គ្រប់ សុង ហៅ រួន មានអាយុ២៣ឆ្នាំ ធ្លាប់ជាយោធាកងធំ, កងពល៣១០, ភូមិភាគបូព៌ា(២០៣) ដែលបានបាត់ខ្លួន និងគ្មានដំណឹងកូនរហូតមកដល់សព្វថ្ងៃ។

ម្តាយរបស់សុង និយាយថា៖ សុង មានស្រុកកំណើតនៅភូមិហាន់ជ័យ ឃុំហាន់ជ័យ ស្រុកឆ្លូង ខេត្តក្រចេះ និងមានឪពុក ឈ្មោះ តន់ គ្រប់ (ស្លាប់ឆ្នាំ២០០៣)។ សុង គឺជាកូនទីប្រាំ ក្នុងគ្រួសារដែលមានបងប្អូនប្រាំមួយនាក់ ឈ្មោះ គ្រប់ គីមស្រីម, គ្រប់ ស៊ាន, គ្រប់ ស៊ុន, គ្រប់ សាន, គ្រប់ សុង និង គ្រប់ សីម។ ក្នុងចំណោមបងប្អូនទាំងនេះគឺមានស្រីចំនួនបីនាក់។

កាលពីកុមារភាព សុង រៀនបានត្រឹមថ្នាក់ទី៩ (សង្គមចាស់) នៅសាលាបឋមសិក្សាឆ្លូង ហើយបន្ទាប់ពីឈប់រៀនគាត់បានមកជួយធ្វើស្រែចម្ការឪពុកម្តាយ និងជួយមើលថែទាំប្អូនពៅប្រុសម្នាក់។ នៅខែមីនា ឆ្នាំ១៩៧០ ម្តាយរបស់ សុង បានឃើញព្រឹត្តិការណ៍នៅស្រុកឆ្លូងមានការដង្ហែក្បួនបាតុកម្មទ្រង់ទ្រាយធំប្រឆាំងនឹងរបប លន់ នល់ ដែលបានធ្វើរដ្ឋប្រហារទម្លាក់ សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែងកាលពីថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០។ តំបន់គាត់រស់នៅចាប់ផ្តើមកើតមានសង្គ្រាម និងការទម្លាក់គ្រាប់បែក ហើយបាតុករមួយចំនួនត្រូវបានចាប់ខ្លួន និងរត់គេចពីការតាមចាប់របស់ទាហាន លន់ នល់។



ប្រវត្តិរូបរបស់ គ្រប់ សុង ដែលបាត់ខ្លួន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅឆ្នាំ១៩៧១ មានការប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងចលនាបដិវត្តន៍ខ្មែរក្រហម ជាញឹកញាប់ ហើយតំបន់មួយចំនួនបានធ្លាក់ក្រោមការគ្រប់គ្រងរបស់ចលនាបដិវត្តន៍ខ្មែរក្រហម។ ការរស់នៅរបស់ប្រជាជនបានជួបប្រទះការលំបាក ដោយសារមិនអាចចេញទៅប្រកបរបររកស៊ី និងធ្វើស្រែចម្ការបានទៀតនោះឡើយ។ នៅពេលនោះម្តាយរបស់ សុង បានឃើញ សុង និងយុវជនក្នុងភូមិហាន់ជ័យ ដទៃទៀតនាំគ្នាទៅចូលរួមជាមួយចលនាបដិវត្តន៍ខ្មែរក្រហមដើម្បីប្រយុទ្ធប្រឆាំងជាមួយទាហាន លន់ នល់។

នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧២ សុង បានចូលបដិវត្តន៍ខ្មែរក្រហម ដោយមានអ្នកខ្ទេសនាម ឈ្មោះ ជុំ ជាលេខាវរសេនាតូច៧១០ និងជុន ជាលេខាវរសេនាតូច៧១០។ ដល់ថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៦ គាត់ត្រូវបានឈ្មោះ សឹន ជាលេខាវរសេនាតូច១២២, ឈ្មោះ វ៉ាន់ ជាលេខាវរសេនាតូច១២១ និងឈ្មោះ ណន ជាអនុលេខាវរសេនាធំ១២ បានខ្ទេសនាមឱ្យ សុង ចូលជាបក្ខជនពេញសិទ្ធិដែលមានឈ្មោះ ដេង ជាលេខាវរសេនាធំ៥៥ ទទួលស្គាល់។ តួនាទីក្នុងរបបខ្មែរក្រហម សុង ធ្លាប់ជាយោធាកងអនុសេនាធំទី១, វរសេនាតូច១២២, វរសេនាធំ១២, កងពល៣១០ ភូមិភាគបូព៌ា។

ម្ដាយរបស់សុង និយាយថា ខ្លួនគ្មានលទ្ធភាពឃាត់ឃាំងកូនមិនឱ្យចូលធ្វើបដិវត្តន៍ទេ ព្រោះនេះជាតម្រូវការរបស់ប្រធានភូមិ និងគណៈឃុំ។ អាជ្ញាធរតែងតែអប់រំយុវជនថា ប្រទេសជាតិកំពុងកើតមានសង្គ្រាម និងការជិះជាន់ពីបរទេស ដូច្នេះត្រូវធ្វើការតស៊ូរំដោះប្រទេសមិនត្រូវសំងំសុខនៅផ្ទះនោះទេ។ ក្រោយមកបងប្អូនរបស់សុង ពីរនាក់ទៀត ក៏បានចូលរួមជាមួយកងទ័ពបដិវត្តន៍ និងបានបាត់ដំណឹងរហូតដល់សព្វថ្ងៃ។ បន្ទាប់មកម្ដាយរបស់សុង ដឹងថាខ្មែរក្រហមបានបញ្ជូន សុង និងយុវជនក្នុងភូមិចំនួនប្រាំនាក់ឱ្យទៅធ្វើជាយោធាតំបន់២១។ សុង ក្នុងនាមជាយោធាតំបន់២១ បានទៅប្រយុទ្ធជាមួយទាហាន លន់ នល់ នៅតំបន់ផ្សេងៗក្នុងខេត្តកំពង់ចាម។ អំឡុងពេលនោះម្ដាយរបស់ សុង បានឃើញកូនមកលេងផ្ទះម្ដងម្កាល។ សុង បានប្រាប់ម្ដាយថា អង្គការបានចាត់តាំងឱ្យគាត់បើកបរ ឡានធំៗដឹកជញ្ជូនស្បៀងអាហារ, គ្រាប់កាំភ្លើង និងសម្ភារទ័ព។ នៅគ្រានោះម្ដាយរបស់សុង មើលឃើញថាកូនជឿជាក់ខ្លាំងទៅលើបដិវត្តន៍ថាពិតជាអាចបញ្ចប់សង្គ្រាម និងការឈប់ទម្លាក់គ្រាប់បែកដែលកំពុងកើតឡើងក្នុងភូមិ។ សុងបានទៅសមរភូមិប្រយុទ្ធជាមួយកងទ័ព លន់ នល់ ជាច្រើនកន្លែងក្នុងនាមជាយោធាតំបន់២១ភូមិភាគបូព៌ា រហូតវាយចូលទីក្រុងភ្នំពេញ និងទទួលបានជ័យជម្នះ។

ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលរបបខ្មែរក្រហមឡើងកាន់អំណាច សុង បានបាត់ដំណឹងរហូតដល់ឆ្នាំ១៩៧៨ ទើបម្ដាយរបស់សុងបានឃើញសុង និងយុវជនម្នាក់មានកាំភ្លើងជាប់នឹងខ្លួនមកលេងគាត់នៅ ឃុំមេសរជ្រៃ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ នៅពេលនោះ សុង បានប្រាប់ម្ដាយថាកុំផ្ដល់ដំណឹងទៅប្រធានសហករណ៍ ខ្លាចគេនាំគាត់ និងមិត្តភក្តិ ទៅសម្លាប់ចោល។ ម្ដាយបានសួរសុខទុក្ខកូន និងបានដឹងថាកូនកំពុងធ្វើជាយោធានៅភូមិភាគបូព៌ា ប៉ុន្តែ សុង មិនបានប្រាប់រឿងរ៉ាវច្រើនទៅដល់ម្ដាយនោះទេ។ នៅព្រឹកថ្ងៃបន្ទាប់ សុង និងមិត្តភក្តិនោះបានធ្វើដំណើរចេញទៅ។ ចាប់តាំងពីពេលនោះមកម្ដាយបានបាត់ដំណឹង សុង រហូតដល់បច្ចុប្បន្ន។ ម្ដាយរបស់សុង គិតថា សុង បានស្លាប់បាត់ទៅហើយ ព្រោះរយៈពេលយូរឆ្នាំមិនឃើញត្រឡប់មកផ្ទះវិញ។ ជារៀងរាល់ពេលពិធីបុណ្យទានម្ដងៗ ម្ដាយរបស់សុង តែងតែឧទ្ទិសកុសលផលបុណ្យដល់កូនៗដែលបានបាត់ដំណឹង។

## ស្ថានភាពរស់នៅ ម្ដាយឪពុករបស់សុង ក្នុងរបបខ្មែរក្រហម

ក្រោយខ្មែរក្រហមចូលកាន់អំណាច ម្ដាយឪពុករបស់សុង ត្រូវបានកងឈ្លបខ្មែរក្រហមជម្លៀសពីភូមិហាន់ជ័យ ឱ្យទៅរស់នៅ ឃុំមេសរជ្រៃ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ ម្ដាយរបស់សុង ត្រូវបានកងឈ្លបខ្មែរក្រហមនៅទីនោះ ប្រើឱ្យជម្រះស្មៅចម្ការចេក ចម្ការអំពៅ និងមើលថែទាំក្មេងនៅក្នុងកងកុមារ។ ចំណែកឪពុករបស់សុង ត្រូវបានអង្គការប្រើឱ្យចាំចម្ការចេក និងចម្ការអំពៅ។ របបអាហារគឺទទួលបានបបរមួយកូនចាន ស្ទើរតែគ្មានគ្រាប់អង្ករ ចំនួនពីរពេលក្នុងមួយថ្ងៃ (ថ្ងៃត្រង់ និងល្ងាច)។ ទោះបីឪពុករបស់ សុង ជាអ្នកចាំចម្ការចេក និងចម្ការអំពៅ ក៏មិនហ៊ានបេះចេក និងកាច់អំពៅ របស់អង្គការហូបដែរ។ នៅឃុំមេសរជ្រៃ ម្ដាយរបស់សុង ធ្លាប់ឃើញខ្មែរក្រហមចង និងបណ្ដើរប្រជាជនថ្មី១៧ មេសា ដែលជម្លៀសមកពីភ្នំពេញជាច្រើនគ្រួសារយកទៅសម្លាប់ នៅតំបន់ភ្នំមួយឈ្មោះថា «ភ្នំតាលី»។ ម្ដាយរបស់សុង ក៏ឃើញកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានចូលមកគ្រប់គ្រងសហករណ៍ និងឃុំជំនួសកម្មាភិបាលភូមិភាគបូព៌ា។ ការបាត់ខ្លួន និងការកាប់សម្លាប់ប្រជាជននៅសហករណ៍ កាន់តែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។

នៅចុងឆ្នាំ១៩៧៨ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា សហការជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាម បានវាយរំដោះប្រទេសកម្ពុជាពីទិសខាងកើត និងសង្គ្រោះប្រជាជនបានជាបន្តបន្ទាប់។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពបានវាយរំដោះទីក្រុងភ្នំពេញ និងបណ្ដាខេត្តនានាជាបន្តបន្ទាប់ ម្ដាយឪពុករបស់សុង ក៏មានសេរីភាពបានមករស់នៅស្រុកកំណើតឯស្រុកឆ្លូង ខេត្តក្រចេះ រហូតដល់សព្វថ្ងៃ។

# អែម សុត ៖ នៅតែនឹករឃើញកូនស្រីដែលបានបាត់ខ្លួន

ភា រស្មី

អែម សុត អាយុ៦៥ឆ្នាំ (២០០៣) កើតនៅភូមិតាសូរ ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ។ បច្ចុប្បន្ន សុត រស់នៅភូមិតាសូរ ឃុំខ្ទត្តមសុរិយា ស្រុកត្រាំកក់ ខេត្តតាកែវ។ សុត មានប្រពន្ធឈ្មោះ កែវ សាន ស្លាប់នៅឆ្នាំ១៩៨៤ និងមានកូនចំនួន៥នាក់ (ស្រី៣នាក់)។ កូនរបស់ សុត ឈ្មោះ អែម សំ បានបាត់ដំណឹងនៅក្នុងរបបខ្មែរក្រហម។ ខាងក្រោមនេះគឺជាការរៀបរាប់របស់ សុត អំពីកូនស្រីដែលបានបាត់ខ្លួន និងភាពភ័យខ្លាចរបស់គាត់នៅក្នុងសម័យខ្មែរក្រហម៖



ប្រវត្តិរូបរបស់ អែម សំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅឆ្នាំ១៩៧៥ បន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុងលើរបបសាធារណរដ្ឋខ្មែរ អង្គការបានបញ្ជូន សំ ឱ្យទៅរស់នៅ និងធ្វើការងារក្នុងកងកុមារ។ នៅក្នុងកងកុមារ សំ អាចត្រឡប់មកលេងឪពុកម្ដាយបានក្នុងមួយអាទិត្យម្ដង ប៉ុន្តែក៏យូរជាងនេះ។ ការងាររបស់ សំ គឺផ្លាស់ប្ដូរទឹកខ្ទែងជាញឹកញាប់ជូនកាលទៅរែកដីនៅអង្គរំពាក់ និងពេលខ្លះទៅធ្វើវប្បកម្មនៅភូមិអង្គរសូរ។ សំ ធ្វើការងារនៅក្នុងកងកុមារបាន២ឆ្នាំ ទើបអង្គការបញ្ជូនឱ្យចូលទៅក្នុងកងយុវជន និងក្រោយមកបញ្ជូនឱ្យទៅទីក្រុងភ្នំពេញដើម្បីធ្វើពេទ្យ នៅមន្ទីរពេទ្យ ៧មករា។ មុនពេលចេញដំណើរទៅភ្នំពេញ សំ បានមកប្រាប់ដំណឹងដល់ឪពុកម្ដាយ និងបានសំពះលាឪពុកម្ដាយជាលើកចុងក្រោយ។ នៅពេលដែលកូនមកប្រាប់ដំណឹង សុត មិនហ៊ានហាមឃាត់កូនមិនឱ្យទៅនោះទេ ព្រោះខ្លាចអង្គការធ្វើបាប ឬយកទៅសម្លាប់ចោល។

សុត មិនបានដឹងពីមូលហេតុអ្វីបានអង្គការជ្រើសរើសកូនស្រីរបស់គាត់ទៅភ្នំពេញឡើយ។ បើនិយាយថាកូនរបស់គាត់មានចំណេះចេះដឹងច្រើនក៏មិនត្រូវ ព្រោះ សំ ចេះអានអក្សរតែបន្តិចបន្តួចប៉ុណ្ណោះ។ ចាប់តាំងពី សំ ចេញទៅភ្នំពេញ សុត មិនដែលឮដំណឹងអំពីកូនទៀតទេ។ រហូតដល់ខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ សុត បានឮអ្នកដែលទៅធ្វើការងារនៅទីក្រុងភ្នំពេញថា សំ បានធ្វើដំណើរតាមរថភ្លើងទៅខេត្តបាត់ដំបង ហើយចាប់តាំងពីពេលនោះមកគឺបាត់ដំណឹងតែម្ដង។

សុត គិតក្នុងចិត្តថាកូនរបស់

គាត់បានស្លាប់នៅក្នុងព្រៃ ហើយប្រហែលជាត្រូវសត្វហែកសាច់ស៊ីក៏មិនដឹង និងនឹកគិតសព្វគ្រប់បែបយ៉ាងអាណិតចំពោះកូនស្រី។ បើទោះយ៉ាងណា សុត នៅតែមិនអស់ចិត្ត ទើបទៅរកហោរាទាយជាច្រើនដង។ ហោរទាយថាកូនរបស់គាត់រស់នៅទិសខាងជើង ហើយខ្លះទៀតថានៅទិសខាងត្បូង ប៉ុន្តែ សុត មិនមានសង្ឃឹមថាកូនរបស់គាត់អាចនៅរស់រានមានជីវិតនោះឡើយ ព្រោះគាត់គិតថាប្រសិនបើកូនរបស់គាត់នៅរស់ពិតមែន នឹងត្រឡប់មករកឪពុកម្ដាយវិញ។ សុតបានបន្តទៀតថាគាត់នៅតែនឹកឃើញកូនស្រីរបស់គាត់ព្រោះ សំ គឺជាកូនល្អ ស្ដាប់បង្គាប់ឪពុកម្ដាយ ស្គាល់ចាស់ព្រឹទ្ធាចារ្យ និងដឹងខុសដឹងត្រូវ សូម្បីមុនពេលចេញទៅភ្នំពេញក៏គាត់មកថ្វាយបង្គំលាឪពុកម្ដាយមុនពេលចេញដំណើរទៅដែរ។

សុត យល់ថាការបែកគ្នារវាងគាត់ និងកូនស្រីគឺជាកំហុសរបស់ប៉ុល ពត ប៉ុន្តែគាត់មិនបានបន្ទោសទៅលើប្រធានកងដែលបញ្ជូនកូនស្រីរបស់គាត់ឱ្យចេញទៅឆ្ងាយនោះទេ ព្រោះប្រធានកងក៏ត្រូវស្ដាប់បញ្ជារបស់ថ្នាក់លើដែរ។ អ្វីដែល សុត អាចធ្វើឱ្យកូនស្រីបានគឺធ្វើបុណ្យឧទ្ទិសកុសលជូន សំ។ មួយវិញទៀត សុត គិតថាការកាត់ទោសលើមេដឹកនាំខ្មែរក្រហមធ្វើឱ្យគាត់ទទួលបានយុត្តិធម៌មួយផ្នែក។ លើសពីនេះទៅទៀត សុត បានយករឿងរ៉ាវរបស់ខ្លួនប្រាប់ទៅក្មេងៗជំនាន់ក្រោយដែលកើតមិនទាន់របបខ្មែរក្រហមឱ្យបានដឹង ហើយត្រូវចេះសាមគ្គីគ្នា និងការពារកុំឱ្យរបបខ្មែរក្រហម ត្រឡប់មកវិញ។

ចំពោះ សុត ផ្ទាល់ការរស់នៅក្នុងរបបខ្មែរក្រហម ក៏គាត់មានការភិតភ័យ ខ្លាចក្រែងធ្វើការខុសឆ្គងអ្វីមួយ ត្រូវបានអង្គការយកទៅធ្វើទារុណកម្ម ឬ វាយសម្លាប់ចោលជាដើម។ ជារៀងរាល់ថ្ងៃ សុត ខិតខំប្រឹងប្រែងធ្វើការងារ បើទោះបីជាការហូបអាហារមិនបានគ្រប់គ្រាន់ក៏ដោយ។ រឿងរ៉ាវដែល សុត ចងចាំ និងមិនអាចបំភ្លេចបានគឺ អង្គការប្រើគាត់ឱ្យឡើងលើភ្នំកែប កាប់ឈើយកមកធ្វើជាសសរ។ ក្រោយពីកាប់ឈើជូនអង្គការរួច សុតបានកើតជំងឺគ្រុនចាញ់ ឈឺញាក់សន្លប់មួយយប់មួយថ្ងៃ។ បន្ទាប់ពីជាពីជំងឺ អង្គការប្រើគាត់ឱ្យទៅកាត់ស្មៅនៅក្នុងព្រៃកស្ដៅ ដែលកាលនោះមានអាកាសធាតុត្រជាក់ខ្លាំង។ សុតរងាផង ខ្លាចសត្វពស់ និងឈ្លើងផង ប៉ុន្តែមិនដឹងធ្វើយ៉ាងណា ព្រោះខ្លាចអង្គការយកទៅសម្លាប់ចោល។



ក្រុមគ្រួសារនៅក្នុងរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របមុខ៖

ពិធីសម្ពោធអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្មាច់-សែនជ័យ) នៅថ្ងៃអាទិត្យ ទី១ ខែមិថុនា ឆ្នាំ២០២៥ ក្រោមអធិបតីភាព សម្តេចរាជបុត្រី ព្រះអនុជ នរោត្តម អរុណរស្មី ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ, សមាជិកាព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ, លោកជំទាវ អ៊ូយូ ខូចាអ៊ើសហ្វេ ឯកអគ្គរដ្ឋទូតសាធារណរដ្ឋតួកគី ប្រចាំកម្ពុជា, តំណាងទីភ្នាក់ងារសម្របសម្រួលនិងសហប្រតិបត្តិការ តួកគី, ឯកឧត្តម ដៃ ប៊ុនឈឿន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តស្ទឹងត្រែង, ឯកឧត្តមបណ្ឌិត នួន ពេជ្រនិមិត្ត រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ស្រុកបុរីអូរស្វាយសែនជ័យ, លោកជំទាវ ឡុង ភិរម្យ រដ្ឋលេខាធិការក្រសួងទេសចរណ៍, ឯកឧត្តម ឈាង ឡាក់ ប្រធានក្រុមប្រឹក្សាខេត្តស្ទឹងត្រែង, ឯកឧត្តម សរ សុពុត្រា អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង, លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងព្រះរាជបណ្ណាល័យ ហ្វូនម៉ែ, ឯកឧត្តមសមាជិកក្រុមប្រឹក្សា ចុះមូលដ្ឋាន ស្រុកបុរីអូរស្វាយសែនជ័យ, ឯកឧត្តមអភិបាលរង នៃគណៈអភិបាលខេត្ត ចុះមូលដ្ឋាន ស្រុកបុរីអូរស្វាយសែនជ័យ, លោកស្រី បួរ ខាំតង ប្រធានក្រុមប្រឹក្សាស្រុកបុរីអូរស្វាយសែនជ័យ, លោក លី មីណា អភិបាល នៃគណៈអភិបាល ស្រុកបុរីអូរស្វាយសែនជ័យ, ឯកឧត្តម លោក លោកស្រី ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ស្រុកបុរីអូរស្វាយសែនជ័យ, លោកស្នងការ មេបញ្ជាការ កងកម្លាំងប្រដាប់អាវុធទាំងបីប្រភេទ, លោកអភិបាលក្រុង ស្រុក នៃខេត្តស្ទឹងត្រែង។

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖

សម្តេចរាជបុត្រី ព្រះអនុជ នរោត្តម អរុណរស្មី ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ, សមាជិកាព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ, ឯកឧត្តម សរ សុពុត្រា អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង, លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងព្រះរាជបណ្ណាល័យ ហ្វូនម៉ែ ចែកអំណោយជូនសិស្សានុសិស្សនៅឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chaktomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 306, June 2025

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.